ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការបំពេញតួនាទីនិងទំនួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងការរៀននិងបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តត្បូងឃ្មុំ

# THE ROLE AND RESPONSIBILITIES OF SCHOOL PRINCIPAL IN MANAGING LEARNING AND TEACHING IN LOWER SECONDARY SCHOOL IN TBONG KHMUM PROVINCE

**ណាំ ពៅ**

NAM PEOU

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**

**ជំនាន់ទី៩**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២០-២០២២**

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការបំពេញតួនាទីនិងទំនួលខុសត្រូវរបស់នាយកសាលា ក្នុងការគ្រប់គ្រងការរៀននិងបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តត្បូងឃ្មុំ

THE ROLE AND RESPONSIBILITIES OF SCHOOL PRINCIPAL IN MANAGING LEARNING AND TEACHING IN LOWER SECONDARY SCHOOL IN TBONG KHMUM PROVINCE


**ណាំ ពៅ**

NAM PEOU


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២០-២០២២**


**គ្រូណែនាំគោល៖ លោក ចាន់ ធឿន**

**គ្រូណែនាំរង៖ បណ្ឌិត ឡាយ សុវិជ្ជា**

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **ណាំ ពៅ** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងការរៀន និងបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តត្បូងឃ្មុំ**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះឬនៅសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយណាត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃអាទិត្យ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**



**ណាំ ពៅ**

# លិខិតបញ្ជាក់

លោក **ចាន់ ធឿន** ជាសាស្ត្រាចារ្យដឹកនាំ

បណ្ឌិត **ឡាយ សុវិជ្ជា** ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ណាំ ពៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងការរៀន និងបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តត្បូងឃ្មុំ**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០២២

គ្រូណែនាំបង្គោល

**លោកគ្រូ ចាន់ ធឿន**

គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

គ្រូណែនាំរង

**បណ្ឌិត ឡាយ សុវិជ្ជា**

# លិខិតឧទ្ទេនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:..៣៦២៤..អយក.ឧ៤ន**

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា ២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ឆ្នាំសិក្សា២០២១-២០២២ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម-នាម និស្សិត |
|---|---|---|---|---|
| ១ | បណ្ឌិត អៃ សុងហ៊ាង | បណ្ឌិត ឈាង សង្វាត | ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាព បុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សា ធនធានក្នុងខេត្តកណ្តាល | លោក កង កុសល |
| ២ | បណ្ឌិត ឈាង សង្វាត | បណ្ឌិត អៃ សុងហ៊ាង | ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | លោកស្រី កុយ ពៅគង់ |
| ៣ | បណ្ឌិត អៃ សុងហ៊ាង | លោក ចាប រតនា | ទំនាក់ទំនងរវាងគណនេយ្យភាព សាលារៀន និងការចូលរួមរបស់សហគមន៍ នៅវិទ្យាល័យ មេសាង ចន្ទគ្រីស្នា និង វិទ្យាល័យអង្គរស ក្នុងស្រុកមេសាង | លោកស្រី គាន ជានី |
| ៤ | បណ្ឌិត ឡាយ សុវិជ្ជា | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ | លោក គាំ រ៉ាវី |
| ៥ | បណ្ឌិត សោន វណ្ណៈ | បណ្ឌិត ម៉ម ចាន់សៀន | ឥរិយាបថនាយកសាលា លើដំណើរការអធិការកិច្ចតាមកាលកំណត់ នៅមធ្យមសិក្សាបឋមភូមិ ក្នុងក្រុងស្ទឹងសែន ខេត្តកំពង់ធំ | លោក គូ វិសនា |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ៦ | លោក ប៉ូ ប៊ុន្នន | បណ្ឌិត សោន វណ្ណៈ | ការគ្រប់គ្រង ការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យ៖ ករណីសិក្សាស្រុកព្រៃកប្បាសខេត្តតាកែវ | លោក ឆេង ប៊ុល |
| ៧ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | ឯកឧត្តម នៀ សុផន | ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ | លោកស្រី ឈួន ស្រីនិត |
| ៨ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | លោក ឌី បុណ្ណា | ស្ថានភាពនៃការអនុវត្តភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ករណីសិក្សាខេត្តស្វាយរៀង | លោក ឈឿន សុភាព |
| ៩ | លោក ចាន់ រ៉ាដា | បណ្ឌិត កាង ស៊ុងឆាង | ស្ថានភាពនៃការអនុវត្តកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ក្នុងខេត្តកំពង់ធំ | លោក ដឹប ឌីន |
| ១០ | លោក ចាន់ ធឿន | បណ្ឌិត ឡាយ សុវិជ្ជា | ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងដំណើរការបង្រៀន និងរៀននៅមធ្យមសិក្សាបឋមភូមិក្នុងស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ | លោក ណាំ ពៅ |
| ១១ | បណ្ឌិត មឿន លិនណា | លោក ម៉ៅ សារឿន | បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ | លោក ទុយ សុខា |
| ១២ | បណ្ឌិត បូ ច័ន្ទគុលិកា | ឯកឧត្តមបណ្ឌិត សិត សេង | ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ របស់ការិយាល័យអប់រំ យុវជន និងកីឡា (ករណីសិក្សានៅក្រុងបាត់ដំបង និងក្រុងសំរោង) | លោក នេត សោភ័ណ្ឌ |
| ១៣ | បណ្ឌិត ឈាង សង្វាត | លោក ម៉ន មុនិន្ទ | ផលជះនៃបរិវត្តកម្មការអប់រំឌីជីថលលើការបំពេញការងាររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុង ខេត្តព្រៃវែង | លោក ផុន ស៊ិនគា |
| ១៤ | បណ្ឌិត ម៉ម ចាន់សៀន | លោក ចាន់ រ៉ាដា | ស្ថានភាពនៃការគ្រប់គ្រងថវិកានៅសាលាមធ្យមសិក្សាបឋមភូមិក្នុងស្រុកសំរោង ខេត្តតាកែវ | លោកស្រី ពុធ សុភ័ក្រ |
| ១៥ | បណ្ឌិត ឈន ថន | លោក ចាន់ ធឿន | ការអនុវត្តគោលនយោបាយSTEM របស់នាយកសាលាធនធាននៅកម្ពុជា | លោកស្រី កុំ ប៊ុន្នា |
| ១៦ | បណ្ឌិត មឿន លិនណា | បណ្ឌិត ឈន ថន | ការផ្ទេរសេវាអប់រំទៅបឋមសិក្សាសហគមន៍ក្នុងខេត្តសៀមរាប | លោក ម៉ាប់ ចន្ធី |
| ១៧ | ឯកឧត្តម នៀ សុផន | បណ្ឌិត គួយ សូគាន | ស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំនៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | លោក ម៉ុញ ណុយ |

| | | | | |
|---|---|---|---|---|
| ១៨ | បណ្ឌិត គួយ សុគាន | លោក ប៉ូ ប៊ុន្នន | ស្ថានភាពនៃការចូលរួមរបស់សហគមន៍ក្នុងការងារអភិបាលកិច្ចល្អសាលាមធ្យមសិក្សានៅខេត្តតាកែវ (ករណីសិក្សានៅវិទ្យាល័យ សុខ អានក្តីទន្ទឹម) | លោក យឹម សុភា |
| ១៩ | លោក ឡុច ចាន់ថន | បណ្ឌិត កាង ស៊ុងឆាង | យុទ្ធសាស្ត្រគ្រប់គ្រងថ្នាក់រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ ករណីសិក្សា៖ មុខវិជ្ជា សីលធម៌ពលរដ្ឋវិជ្ជា(ខេត្តកំពត) | លោកស្រី រស់ សុភក្តិ |
| ២០ | បណ្ឌិត ឡាយ សុវិជ្ជា | បណ្ឌិត ឈិញ ស៊ីថា | ការសិក្សាពីមុខសញ្ញាចំណាយការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ | លោក វ៉ាន់ សំរេច |
| ២១ | លោក ចាប រតនា | បណ្ឌិត អាន រ៉ូប្រាវ | ស្ថានភាពនៃការបង្រៀន និងរៀនតាមបែបបញ្ញត្តិលើមុខវិជ្ជាប្រវត្តិវិទ្យានៅកម្រិតវិទ្យាល័យក្នុងខេត្តតាកែវ | លោកស្រី វិត សាវ៉ាន់ |
| ២២ | ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម | បណ្ឌិត មាឃ ចាន់ថេង | ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងរបស់នាយកសាលាកម្រិតវិទ្យាល័យនៅរាជធានីភ្នំពេញប្រទេសកម្ពុជា | លោកស្រី រី កូលាភ |
| ២៣ | បណ្ឌិត អាន រ៉ូប្រាវ | បណ្ឌិត នី រដ្ឋា | ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម | លោក ស៊ិន ភារ័ក្ស |
| ២៤ | ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម | លោក ថៃ ហេង | តម្រូវការការអភិវឌ្ឍខ្លួនឯងរបស់មន្ត្រីអប់រំក្នុងអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការនៃក្រសួងអប់រំ យុវជន និងកីឡា | លោកស្រី ស៊ិន រចនា |
| ២៥ | បណ្ឌិត មាឃ ចាន់ថេង | លោកស្រី នូ ចន្ទី | ឥទ្ធិពលនៃភាពជាអ្នកដឹកនាំបែបបង្ហាត់បង្ហាញរបស់នាយកទៅលើភាពជឿជាក់លើសមត្ថភាពបង្រៀនរបស់គ្រូ | លោកស្រី សុខ សុវណ្ណារ័ត្ន |
| ២៦ | បណ្ឌិត ឈូក ច័ន្ទឆាយា | បណ្ឌិត មាឃ ចាន់ថេង | ទំនាក់ទំនងរវាងគំរូនៃភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនទៅលើការជំរុញទឹកចិត្តក្នុងការរៀន និងការគិតត្រិះរិះពិចារណារបស់និស្សិត | លោកស្រី ហ៊ាង ហុងឡាយ |
| ២៧ | លោក ថៃ ហេង | ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម | ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀន នៅកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ | លោកស្រី ហ៊ីម ម៉ាណា |
| ២៩ | បណ្ឌិត អ៊ុំ ចាន់ចំណាន | លោកស្រី សុខ វណ្ណា | ការរួមបញ្ចូលភាសាកំណើតក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា ក្នុងខេត្តកំពង់ចាម | លោក ហៀង ណេន |

| | | | | |
|---|---|---|---|---|
| ២៩ | លោកស្រី នូ ចន្នី | បណ្ឌិត អាន វ៉ូប្រាវ | កត្តាជះឥទ្ធិពលគម្លាតយេនឌ័រក្នុងការអប់រំស្នែមនៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | លោកស្រី ហេង សុគន្ធារី |
| ៣០ | លោក លឹម វ៉ាន់ | បណ្ឌិត នី វង្ខា | ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះនៅក្នុងរាជធានីភ្នំពេញ | លោក ហេង ស្រៀន |
| ៣១ | បណ្ឌិត ឡឹយ សុគា | បណ្ឌិត ឈន ថន | សមាហរណកម្មនៃការរៀនបែបចម្រុះសម្រាប់សិស្សវិទ្យាល័យ ករណីសិក្សានៅកម្ពុជា | លោក ឡុង រក្សា |
| ៣២ | លោក ម៉ៅ សារឿន | លោកស្រី សេង សច្ចា | កត្តាដែលធ្វើឱ្យមានភាពតានតឹងលើការនិយាយភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ | លោក អ៊ូ សុផាត |
| ៣៣ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត ឈូក ច័ន្ទឆាយា | កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា | លោក អាត សារ៉េត |
| ៣៤ | លោកស្រី ខែក សំណាង | លោក ឡុច ចាន់ថន | ការសិក្សាសៀវភៅសិក្សាគោលមុខវិជ្ជាអក្សរសាស្ត្រខ្មែរនៅកម្រិតមធ្យមសិក្សាទុតិយភូមិ | លោក ភ័ណ សុភា |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រដែអ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈាំ ពៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ។

**<u>សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ</u>**

-លោកឪពុក **អាន អេខ** និងអ្នកម្តាយ **ទេព ស្រ៊ុម** ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សារូបកូនដោយផ្តល់ដំបូន្មានល្អៗ ព្រមទាំងបានបញ្ជូនកូនឱ្យចូលសិក្សារៀនសូត្រតាំងពីថ្នាក់បឋមសិក្សារហូតមកដោយមិនគិតពីការនឿយហត់ ការចំណាយផ្សេងៗទោះបីជីវភាពក្រីក្រ និងតស៊ូដើម្បីកូនទទួលបានជោគជ័យមានអនាគតរុងរឿងជាបន្តបន្ទាប់។

-លោកឪពុកក្មេក **ឡុង ឌា** និងអ្នកម្តាយក្មេក **ចឹក សេងហ៊ន់** ដែលបានផ្តល់ការគាំទ្រលើកទឹកចិត្តដល់រូបខ្ញុំក្នុងការសិក្សានេះរហូតទទួលបានជោគជ័យ។

-ឧត្តមភរិយា **ឡុង ស្រីនាន** កូនស្រី**អេខ ពៅបញ្ញាពេជ្រ** ដែលបានគាំទ្រលើកទឹកចិត្តខ្ញុំ ក្នុងការសិក្សានេះ និងតស៊ូជំនះឧបសគ្គនានាជាមួយខ្ញុំដោយមិនគិតពីការនឿយហត់ ការលំបាកផ្សេងៗ ដើម្បីឱ្យការសិក្សារបស់ខ្ញុំបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទន។

-**ឯកឧត្តមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា** ដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំសម្រាប់បុគ្គលិកអប់រំនេះឡើង ក៏ដូចជាលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និង វិស័យអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាពស្របតាមបរិបទរីកចម្រើននៅកម្ពុជា។

-លោក **ចាន់ ធឿន** គ្រូបង្រៀនវិទ្យាស្ថានជាតិអប់រំ ជាសាស្ត្រាចារ្យដឹកនាំ ដែលបានឆ្លៀតពេលដ៏មានតម្លៃក្នុងការផ្តល់គំនិតណែនាំ និងផ្តល់ទាំង កម្លាំងចិត្ត បញ្ញាស្មារតី សម្ភារៈ បច្ចេកទេស វិធីសាស្ត្រផ្សេងៗ ឯកសារ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំ រហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាភស្តុតាងស្រាប់ ។

-បណ្ឌិត **ឡាយ សុវិជ្ជា** ជាសាស្ត្រាចារ្យដឹកនាំរង ដែលបានឆ្លៀតពេលដ៏មានតម្លៃរបស់លោកបណ្ឌិតក្នុងការផ្ដល់គំនិតណែនាំ និងផ្ដល់ទាំង កម្លាំងចិត្ត បញ្ញាស្មារតី សម្ភារៈ បច្ចេកទេស វិធីសាស្ត្រផ្សេងៗ។ មិនតែប៉ុណ្ណោះលោកបណ្ឌិត បានជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំ រហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាភស្តុតាងស្រាប់ ។

-ឯកឧត្តម បណ្ឌិត លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ ជាសាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត សម្ភារៈ ក្នុងការផ្ដល់ពុទ្ធិ ចំណេះធ្វើ ឥរិយាបថ ពិសេស ផ្ដល់ជាទ្រឹស្ដីបទពិសោធន៍ល្អៗ ដែលទាំងនេះជាចំណេះដឹងមួយដ៏សំខាន់ និងចាំបាច់បំផុតសម្រាប់ អនុវត្ត ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តការងារបច្ចុប្បន្ន និងបានសម្របសម្រួលដល់ដំណើរការនៃការ បណ្ដុះបណ្ដាលក្នុងវគ្គនេះប្រកបដោយជោគជ័យ។

-លោកនាយក នាយិកា នាយករង លោកគ្រូ អ្នកគ្រូ ដែលបានសហការ ចំពោះការចុះក្នុង ស្រាវជ្រាវប្រមូលទិន្នន័យរបស់ខ្ញុំ ដើម្បីយកមកសរសេរនិក្ខេបបទនេះរហូតទទួលបានជោគជ័យ។

ជាទីបញ្ចប់ខ្ញុំបាទ សូមគោរពបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោកប្រសិទ្ធិពរជ័យបវរមហាប្រសើរជូនចំពោះ អ្នកមានគុណទាំងអស់ខាងលើដែលបានជួយឧបត្ថមគាំទ្រដល់រូបខ្ញុំបាទ ជួបប្រទះតែពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ជំពូកទី១ ........................................ 4

សេចក្តីផ្តើម ........................................ 7

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ 7

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ 10

១.៣ គោលបំណងនៃការស្រាវជ្រាវ ........................................ 11

១.៤ សំណួរស្រាវជ្រាវ ........................................ 11

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........................................ 12

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........................................ 12

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ 13

ជំពូកទី២ ........................................ 14

រំលឹកទ្រឹស្តី ........................................ 14

២.១ លទ្ធផលនៃការស្រាវជ្រាវពីមុន ........................................ 14

២.២ មុខងាររបស់នាយកសាលារៀន ........................................ 16

២.៣ តួនាទីរបស់នាយក ឬនាយិកាសាលារៀន ........................................ 21

២.៤. នាយក ឬនាយិកាសាលារៀនល្អ ........................................ 26

២.៥ លក្ខណៈសម្បត្តិរបស់នាយកសាលាល្អ ........................................ 27

២.៦ សេចក្តីព្រាងស្តង់ដាវិជ្ជាជីវៈនាយកសាលារៀន ........................................ 29

២.៧ ភារកិច្ច និងការទទួលខុសត្រូវរបស់នាយកសាលា ........................................ 33

២.៨ សមត្ថភាពរបស់នាយកសាលានៅតំបន់អាស៊ី ........................................ 38

ជំពូកទី៣ ........................................ 41

វិធីសាស្ត្រស្រាវជ្រាវ ........................................ 41

៣.១ សំណាក ........................................ 41

៣.២ ការប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ ........................................ 43

៣.៣ ការវិភាគទិន្នន័យ ........................................ 43

ជំពូកទី៤ ........................................ 45

លទ្ធផល និងការពិភាក្សា ........................................ 45

៤.១ ការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា ........ 45
៤.២ ការងារអធិការកិច្ចអចិន្ត្រៃយ៍របស់នាយកសាលា ........ 47
៤.៣ ការគ្រប់គ្រងលើការអនុវត្តវិធីសាស្ត្របង្រៀន ........ 48
៤.៤ ការគ្រប់គ្រងលើការអនុវត្តការងាររដ្ឋបាលរបស់គ្រូបង្រៀន ........ 49
៤.៥ ការដឹកនាំនិងគ្រប់គ្រងលើការងារប្រជុំបច្ចេកទេស ........ 51
៤.៦ ការគ្រប់គ្រងលើលទ្ធផលនៃការសិក្សារបស់សិស្ស ........ 52
៤.៧ ការកៀរគរការចូលរួមគាំទ្រពីសហគមន៍លើដំណើរការបង្រៀននិងរៀន ........ 53
ជំពូកទី៥ ........ 56
សេចក្តីសន្និដ្ឋាន និងសំណូមពរ ........ 56
៥.១ សេចក្តីសន្និដ្ឋាន ........ 56
៥.២ សំណូមពរ ........ 59

# មូលន័យសង្ខេប

បច្ចុប្បន្ននេះការអប់រំគឺជាចំណុចសំខាន់ជាងគេបំផុតសម្រាប់របៀបវារៈនៃការអភិវឌ្ឍ និងនយោបាយរបស់ប្រទេសជាច្រើននៅក្នុងសកលលោក។

ជាទូទៅគ្រប់គ្រឹះស្ថានសិក្សាទាំងអស់បានខិតខំយកចិត្តទុកដាក់ពង្រឹងនូវគុណភាព និងប្រសិទ្ធភាពនៃការអប់រំជាពិសេសទៅលើការងារដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា ធ្វើយ៉ាងណាឱ្យសាលារៀនមានដំណើការល្អ មានការអភិវឌ្ឍ មានការចូលរួមផុសផុលពីសហគមន៍ ហើយលទ្ធផលសិក្សារបស់សិស្សមានគុណភាពខ្ពស់ផងដែរ។ ប៉ុន្តែទោះបីជាមានការខិតខំប្រឹងប្រែងពីគ្រប់ភាគីពាក់ព័ន្ធយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា នូវមានចំណុចខ្វះខាត និងភាពអសកម្មជាច្រើនបាន និងកំពុងតែកើតមានឡើងនៅតាមគ្រឹះស្ថានសិក្សាសាធារណៈមួយចំនួន ជាពិសេសនៅកម្រិតមធ្យមសិក្សា នាយកសាលាមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ មិនបានបំពេញតួនាទី និងទំនួលខុសត្រូវបានគ្រប់ជ្រុងជ្រោយ មិនមានគនេយ្យភាពលើដំណើការបង្រៀន និងរៀនដែលបង្ករឱ្យមានភាពមិនពេញចិត្ត ពីមជ្ឈដ្ឋានសហគមន៍ជុំវិញសាលាដែលជាហេតុធ្វើឱ្យពួកគាត់មិនបានចូលរួមពេញលេញក្នុងដំណើរការអភិវឌ្ឍសាលារៀន។ល។

ដោយមើលឃើញពីបញ្ហាទាំងអស់នេះ និងជាតម្រូវការចាំបាច់ផងនោះការសិក្សាស្រាជ្រាវមួយត្រូវបានធ្វើឡើងដើម្បីស្វែងយល់ពីសារៈសំខាន់ និងតួនាទីទំនួលខុសត្រូវរបស់នាយកសាលាលើដំណើរការបង្រៀន និងរៀន។ ដើម្បីធ្វើការសិក្សាស្រាវជ្រាវបាន អ្នកស្រាវជ្រាវបានកំណត់ចំនួនសាលារៀន និងក្រុមគោលដៅ និងកំណត់ចំនួនសំណាកដែលត្រូវធ្វើការសម្ភាស បន្ទាប់មកបង្កើតសំណួរសម្ភាសនិងបានចុះធ្វើការសម្ភាសទៅតាមពេលវេលាដែលបានកំណត់។ ក្នុងនោះដែរអ្នកស្រាវជ្រាវបានដាក់ចេញនូវគោលបំណងសំខាន់ពីរគឺ ១- ដើម្បីស្វែងយល់ពីទេពកោសល្យ ភាពប៉ិនប្រសព្វរបស់នាយកសាលាក្នុងការដឹកនាំការបង្រៀន និងរៀន ២- ដើម្បីស្វែងយល់ពីសារៈសំខាន់នៃទំនួលខុសត្រូវរបស់នាយកសាលាលើដំណើរការបង្រៀនរៀនឱ្យមានប្រសិទ្ធភាព។ ក្នុងការសិក្សានេះផងដែរអ្នកស្រាវជ្រាវបានធ្វើការចាប់ឆ្នោតក្នុងចំណោមអនុវិទ្យាល័យទាំង

អស់ក្នុងស្រុកអូរាំងឪចំនួន៥ ដោយជ្រើសរើសបានសាលាចំនួនបីមកធ្វើការសិក្សាស្រាវជ្រាវដោយយោងទៅតាមវិធីសាស្ត្រស្រាវជ្រាវ និងពេលវេលាដ៏មមាញឹករបស់អ្នកស្រាវជ្រាវផ្ទាល់។ ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវបានឱ្យដឹងថា វាពិតជាមានសារៈសំខាន់ណាស់ និងជាភាពមិនអាចខ្វះបានដែលនាយកសាលាទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវ មានតម្លាភាព និងគណនេយ្យភាពខ្ពស់លើដំណើការការបង្រៀន និងរៀនដែលក្នុងនោះរួមមានចំណុចមួយចំនួនដូចជា៖ ការអនុវត្តតួនាទី និងទំនួលខុសត្រូវក្នុងការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា ការគ្រប់គ្រងអនុវត្តការងារអធិការកិច្ចអចិន្ត្រៃយ៍ ទំនួលខុសត្រូវក្នុងការដឹកនាំការអនុវត្តវិធីសាស្តបង្រៀន ការដឹកនាំនិងគ្រប់គ្រងលើការអនុវត្តការងាររដ្ឋបាលរបស់គ្រូ ទំនួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រងលើការងារប្រជុំបច្ចេកទេស ទំនួលខុសត្រូវក្នុងការគ្រប់គ្រងលើលទ្ធផលសិក្សារបស់សិស្ស និងទំនួលខុសត្រូវក្នុងការងារកៀរការចូលរួមពីសហគមន៍។ លើសពីនេះទៅទៀតភាគសំណាកដែលជាគ្រូបង្រៀនដែលបានធ្វើការងារផ្ទាល់ជមួយនិងនាយកសាលាបានលើកឡើងរួមជាមួយនិងសំណូមពរដល់លោកនាយកសាលាឱ្យខិតខំពង្រឹងបន្ថែមទៀតលើការងារបង្រៀននិងរៀនពីព្រោះនូវមានចំណុចធកល្វែងជាច្រើនដែលនាយកសាលាមិនបានអនុវត្ត ទាំងការងារពិនិត្យតាមដានលើការបង្រៀននិងរៀនដែលនាយកសាលាមួយចំនួនមិនដែលធ្វើសោះ(ទាំងផែនការ និងការអនុវត្ត) ការពិនិត្យតាមដានលើការងារប្រជុំបច្ចេកទេស និងជាពិសេសទៅទៀតនោះគឺការងារទំនាក់ទំនងជាមួយនិងសហគមន៍ ដែលនាយកសាលាគ្រប់រូបត្រូវមានភាពឈ្លាសវៃ ភាពប៉ិនប្រសព្វក្នុងការធ្វើទំនាក់ទំនងជាមួយ សហគមន៍គឺជាតួអង្គដ៏សំខាន់បំផុតមួយក្នុងការចូលរួមលើកកម្ពស់គុណភាពសិក្សារបស់សិស្ស ប៉ុន្តែជាក់ស្តែងនាយកសាលានូវតែពុំទាន់ធ្វើបានល្អនៅឡើយលើការងារមួយនេះ។

ជាអនុសាសន៍និងជាសំណូមពរអ្នកស្រាវជ្រាវចំពោះនាយកសាលារៀនទាំងអស់គួរតែខិតខំពង្រឹង កែលម្អសមត្ថភាពបន្ថែមលើការងារគ្រប់គ្រងនិងដឹកនាំជាពិសេសលើដំណើការបង្រៀននិងរៀនដូចជា៖

- គួរពង្រឹងបន្ថែមទៅលើការពិនិត្យតាមដាន និវាយតម្លៃជាប្រចាំលើដំណើរការបង្រៀន និងរៀន ដោយត្រូវរៀបចំធ្វើផែនការអធិការកិច្ចឱ្យបានច្បាស់លាស់

- ពង្រឹងបន្ថែមលើការគ្រប់គ្រងនិងដឹកនាំការងារប្រជុំបច្ចេកទេសឱ្យបានត្រឹមត្រូវ និងមានភាពទៀងទាត់ក្នុងការអនុវត្តដើម្បីពង្រឹងប្រសិទ្ធភាពការងារ

- ពង្រឹងបន្ថែមលើការងារទំនាក់ទំនងជាមួយសហគមន៍ជុំវិញសាលាដើម្បីគៀគរការចូលរួមក្នុងដំណើរការអភិវឌ្ឍសាលារៀនឱ្យមានភាពរីកចម្រើន។

សរុបជារួមមកទំនួលខុសត្រូវខ្ពស់របស់នាយកសាលាពិតជាមានសារៈសំខាន់ និងមានភាពចាំបាច់ក្នុងការចូលរួមចំណែកលើកកម្ពស់គុណភាព ប្រសិទ្ធភាពនៃដំណើការបង្រៀន និងរៀន ព្រមទាំងរួមចំណែកលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធផងដែរ នូវមានតួនាទី និងទំនួលខុសត្រូវសំខាន់ៗជាច្រើនទៀតដែលនាយកសាលាគ្រប់រូបត្រូវយកចិត្តទុកដាក់ និងពង្រឹងសមត្ថភាពបន្ថែមលើការងារដឹកនាំនិងគ្រប់គ្រងដើម្បីឆ្លើយតបនិងការរីចម្រើននៃចំនេះដឹងដឹងនាស.វទី២១នេះ។

# Abstract

Today, education is at the forefront of the development and political agenda of many countries in the world.

In general, all educational institutions strive to strengthen the quality and effectiveness of education, especially on the leadership and management of principals, to ensure that the school is functioning well, developed, involved in the community and the results. Student learning is also high quality. However, despite the efforts of all stakeholders, we have observed that many shortcomings and inactions have been occurring in some public schools, especially at the secondary level. Insufficient capacity to fulfill all roles and responsibilities, lack of accountability in the teaching and learning process, which causes dissatisfaction from the community around the school, which is why they do not fully participate in the school development process. Etc.

Seeing all these issues and the need, a research study was conducted to understand the importance and role of the principal in the teaching and learning process. In order to conduct the study, the researcher determined the number of schools and target groups and determined the number of samples to be interviewed, then developed the interview questions and conducted the interviews according to the set time. In that, the researchers set two main objectives: 1 - To understand the talents and talents of principals in leading teaching and learning 2 - To understand the importance of the responsibilities of principals on the teaching

and learning process. Efficiency. In this study, the researchers were selected from all the secondary schools in 5 districts in Orang Ov district, selecting three schools to conduct research according to the research method and the busy time of the researchers themselves. As a result of the research, it is said that it is very important and indispensable for all principals to pay attention to the proper implementation, transparency and accountability of the teaching and learning process in These include: the implementation of roles and responsibilities in the management of curriculum implementation, performance management, permanent inspection, leadership responsibilities, implementation of teaching methods, leadership and management of administrative responsibilities of teachers. Must be in charge of technical meetings, responsible for managing student learning outcomes, and responsible for community involvement. In addition, a sample of teachers who have worked directly with the principal and requested the principal to further strengthen the teaching and learning work because there is a gap. Many of the principals did not carry out monitoring and learning activities that some principals never did ( both planning and implementation ), monitoring technical meetings, and especially community relations work. That all principals need to be smart, talented in communicating with the community is one of the most important players in contributing to improving the quality of students' education, but obviously the principal is still not doing well on This one job.

As a recommendation and request, researchers to all school principals should strive to strengthen their capacity for additional management and leadership, especially on the teaching and learning process, such as:

- Should be strengthened on a regular basis to monitor and evaluate the teaching and learning process by preparing a clear inspection plan.

- Strengthen the management and conduct of technical meetings properly and regularly in practice to strengthen work efficiency.

Strengthen communication with the community around the school to mobilize participation in the process of school development.

Overall, the high responsibility of the principal is very important and necessary to contribute to improving the quality and efficiency of the teaching and learning process, as well as to contribute to the participation of all stakeholders with roles and responsibilities. There are many important responsibilities that every principal must pay attention to and strengthen the capacity of leadership and management to respond to the growth of knowledge in the 21st century.

# ជំពូកទី១

## សេចក្តីផ្តើម

### ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងបរិបទថ្មីនៃការអភិវឌ្ឍរបស់ពិភពលោកបានទាមទារឱ្យមនុស្សបង្កើនការយកចិត្តទុកដាក់ខ្ពស់ទៅលើការងារអប់រំ។ ទន្ទឹមនឹងនោះសាលារៀន គឺជាថ្នាលបណ្តុះធនធានអប់រំមួយដែលចាំបាច់ត្រូវយកចិត្ត ទុកដាក់ និងធ្វើការកែលម្អមុនគេដើម្បីឱ្យជះឥទ្ធិពលទៅដល់ផ្នែកពាក់ព័ន្ធដទៃទៀត។ ស្របគ្នានេះខ្លឹមសារ «ការអប់រំប្រកបដោយចីរភាព និងធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»ត្រូវបានកំណត់ជាគោលនយោបាយរួមគ្នាមួយ ក្នុងឱកាសសន្និសិទ្ធនៅក្រុងអ៊ីនឈុន(Incheon)សាធារណរដ្ឋកូរ៉េក្នុងខែឧសភា ឆ្នាំ២០១៥។ (ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨)

ឈរលើគោលនយោបាយនេះរាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៥ បានដាក់ចេញនូវយុត្តិសាស្រ្តចតុកោណដំណាក់កាលទី៣ ដែលនោះវិស័យអប់រំស្ថិតនៅមុំទី៤ គឺការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សផ្អែកលើអភិបាលកិច្ចល្អជាស្នូល។ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើ « វិស័យអាទិភាព៤ » ដូចជា ការពង្រឹងគុណភាពវិស័យអប់រំ ការលើកកម្ពស់សេវាសុខាភិបាល ការអនុវត្តគោលនយោបាយសមភាពយេនឌ័រនិងការអនុវត្តគោលនយោបាយប្រជាជន។ ទន្ទឹមនឹងនោះការអភិវឌ្ឍធនធានមនុស្សដែលធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្ម ក្នុងតំបន់ដែលកាន់តែបើកចំហតាមរយៈ ១.ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់ តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃខ្ពស់ ២.ការរៀបចំក្របខណ្ឌគតិយុត្ត និងកសាងស្ថាប័ន អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងចំណុចទី១ខាងលើ ៣.ការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមក្នុងកិច្ចការនេះ និង៤.ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ។

ទន្ទឹមនឹងគ្នានេះក្រសួងអប់រំយុវជន និងកីឡាក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩ - ២០២៣ បានដាក់ចេញនូវគោលនយោបាយធំពីគឺ ១.ធានាការអប់រំប្រកបដោយ សមធម៌ បរិយាបន្ន និងទទួលបានឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ២.ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសម្រាប់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដែលគោលនយោបាយអប់រំទី២នេះមានគោលបំណងពង្រឹងសមត្ថភាពដល់គណៈគ្រប់គ្រងទាំងអស់ជាពិសេសនាយកសាលារៀនដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា។ ជាពិសេស ស្របនឹងទស្សនវិស័យអប់រំអភិវឌ្ឍន៍កម្ពុជាដែលនឹងប្រែក្លាយជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ (ក្រសួងអប់រំ យុវជន និងកីឡា,២០១៩)

ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាបច្ចុប្បន្នពុំទាមទារដាច់ខាតឱ្យបុគ្គលិកអប់រំនៅកម្រិតសាលារៀនមានគណនេយ្យភាពចំពោះគុណភាពនៃការអប់រំដែលផ្តល់ទៅឱ្យសិស្ស។ ប្រព័ន្ធអប់រំនៅកម្ពុជា ក៏ពុំទាន់តម្រូវឱ្យគ្រូបង្រៀនដែលមានវិជ្ជាជីវៈត្រូវមានអាជ្ញាប័ណ្ណនៅឡើយដែរ។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលាធ្វើឡើងយូរៗម្តង និងភ្លាមៗ ហើយស្តង់ដាវិជ្ជាជីវៈដែលត្រូវបានកំណត់ដោយប្រយោលក្នុងការវាយតម្លៃលើសមិទ្ធកម្ម (ស្នាដៃ) ប្រចាំឆ្នាំ ពុំត្រូវបានសាលារៀនជាច្រើនគោរព ឬអនុលោមតាម។

ក្រសួងកត់សម្គាល់ឃើញថាសិស្សថ្នាក់ទី៦រហូតដល់៣០% ទូទាំងប្រទេសពុំទាន់មានបំណិនអានសរសេរ និងលេខនិព្វន្តឱ្យដល់កម្រិតមូលដ្ឋានដែលចាំបាច់ដើម្បីឱ្យពួកគេអាចឆ្លងភូមិសិក្សាទៅកាន់កម្រិតមធ្យមសិក្សាបឋមភូមិប្រកបដោយជោគជ័យនៅឡើយ។ ដូចនេះការសំខាន់ គឺសិស្សថ្នាក់ទី៦ទូទាំងប្រទេសត្រូវមានបំណិនអាន សរសេរ និងលេខនិព្វន្តកម្រិតមូលដ្ឋានដែលចាំបាច់សម្រាប់ឱ្យពួកគេអាចឆ្លងទៅកម្រិតមធ្យមសិក្សាបឋមភូមិ។

ដូច្នេះវិស័យអប់រំត្រូវតែមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខ្ពស់ជាងមុនលើជោគជ័យរបស់សិស្សនៅគ្រប់កម្រិតភូមិសិក្សាទាំងអស់ និងត្រូវផ្តួចផ្តើមកម្មវិធីបំប៉នសម្រាប់សិស្សដែលប្រឡងឡើងថ្នាក់ ដើម្បីសម្រេចបាននូវលទ្ធផលសិក្សាដែលចង់បានមុននឹងឱ្យសិស្សឡើងថ្នាក់។ គោលដៅចម្បងមួយក្នុងចំណោមគោលដៅនានារបស់គោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាពគឺសហគមន៍ត្រូវចូលរួមផ្ទាល់ក្នុងការធានាថាសាលារៀនសម្រេចបានលទ្ធផលសិក្សាដែលចង់បាន តាមរយៈការរៀបចំផែនការកែលម្អសាលារៀន ការកៀរគរធនធាន ការពិនិត្យតាមដាន និងការគាំទ្រផ្នែកបច្ចេក។

យោងតាមទិន្នន័យពីការធ្វើវង្វាយតម្លៃថ្នាក់ជាតិសម្រាប់ថ្នាក់ទី៣ ទី៦ និងទី៨ក្នុងរយៈពេលពីឆ្នាំ ២០១៥-២០១៧ ផ្តោតលើមុខវិជ្ជាគោលពីរ គឺមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា បានបង្ហាញថាលទ្ធផលសិក្សានៅមានកម្រិតក្រោម៥០% និងពុំមានសញ្ញាដែលបង្ហាញពីនិន្នាការប្រសើរឡើងនោះទេ។

ការសិក្សាស្រាវជ្រាវប្រតិបត្តិនៅតាមសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តចំនួនបីក្នុងឆ្នាំ២០១៨ បានបង្ហាញឱ្យឃើញថា ចំណេះដឹង និងជំនាញអក្សរសាស្ត្រ និងលេខនិព្វន្ត មានកម្រិតទាបរបស់សិស្សថ្នាក់ទី៧ រួមចំណែកធ្វើឱ្យអត្រាធ្លាប់ចាកចេញពីសាលារៀនមានកម្រិតខ្ពស់។ ទិន្នន័យអាស៊ានបានបង្ហាថាកុមារកម្ពុជាជាមធ្យមរៀនបាន ៩,៥ ឆ្នាំ ប៉ុន្តែលទ្ធផលនៃការសិក្សារបស់ពួកគេជាមធ្យមសមមូលនិងថ្នាក់ទី៦។(ក្រសួងអប់រំយុវជននិងកីឡា, ២០២១b)

ក្រសួងអប់រំយុវជននិងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានបំណងប្រែក្លាយសាលារៀនក្លាយទៅជាកន្លែងផ្តល់សេវាអប់រំមួយប្រកបដោយគុណភាព បរិយាប័ន្ន ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន។ ការអនុវត្តការគ្រប់គ្រងតាមសាលារៀនផ្អែកលើគោលការចំនួនបីគឺ ទី១ ការពង្រឹងសមត្ថភាពប្រព័ន្ធអប់រំដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន ទី២ ការពង្រឹងប្រសិទ្ធភាពគ្រូបង្រៀនតាមរយៈការអនុវត្តការគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន និងទី៣ ការលើកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងស្វ័យភាពនិងគណនេយ្យភាពសាលារៀន។

ការគ្រប់គ្រងតាមសាលារៀនមានគោលបំណងពីរគឺ ១- រៀបចំសាលរៀនឱ្យបំពេញនូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដោយការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀន ដើម្បីធានាថាការគាំទ្រត្រូវបានផ្តល់ឱ្យសាលារៀនទាន់ពេលវេលា និង ២- កសាងសមត្ថភាបគ្រូបង្រៀន ដើម្បីអនុវត្តកម្មវិធីសិក្សារបស់ជាតិ។(ក្រសួងអប់រំយុវជននិងកីឡា, ២០១៨c)

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

បញ្ហាប្រឈមដែលក្រសួងកំពុងជួបប្រទះ ក្នុងពេលខិតខំជម្រុញការអនុវត្តគោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាពនៅតាមសាលាមធ្យមសិក្សា គឺការកសាងសមត្ថភាពនាយកសាលា និងគ្រូបង្រៀន ដើម្បីអាចបំពេញមុខនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធនិងប្រសិទ្ធផល។ ការវាយតម្លៃរហ័សមួយដែលធ្វើឡើងកាលពីខែកញ្ញា ឆ្នាំ២០១៩ បានរកឃើញថា ទោះជាបានទទួលការបណ្តុះបណ្តាលអំពីគោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាពរួចហើយ ក៏មាននាយកជិត៥០% ពុំអាចកំណត់ពីគោលការគ្រប់គ្រងតាមសាលារៀនឱ្យបានត្រឹមត្រូវឡើយ ចំណែកគ្រូបង្រៀនបានត្រឹមតែ៤០%ដែលអាចលើកឡើងបានត្រឹមត្រូវពីគោលការណ៍ទាំងនេះ។ នាយកសាលាមុនៗពុំមានទម្លាប់ក្នុងការទទួលខុសត្រូវចំពោះលទ្ធផលការងាររបស់សាលា ហើយកាន់តែពុំសូវមានការទទួលខុត្រូវចំពោះសិស្សលើលទ្ធផលសិក្សរបស់ពួកគេនិងការទាមទាពីសំណាក់មាតាបិតា/អាណាព្យាបាលដែលប្រាថ្នាចង់បានការសិក្សាដែលមានគុណភាព និងលទ្ធផលល្អ។ ការទាមទារប្រាថ្នាចង់បានរបស់មាតាបិតា/អាណាព្យាបាលបានក្លាយជាមូលហេតុមួយទៀតដែលជម្រុញនាយកសាលាមានការស្នោក់ស្ទើរក្នុងការជម្រុញលើកទឹកចិត្តឱ្យមាតាបិតា និងសហគមន៍ជុំវិញសាលារៀនចូលរួមនៅក្នុងគណៈកម្មការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព ហើយគណៈកម្មការនេះក៏ជាធានផ្សំមួយដ៏សំខាន់នៃអភិក្រមរបស់គោលវិធីគ្រប់គ្រងតាមសាលារៀមមានប្រសិទ្ធភាពទាំងមូល។ (ក្រសួងអប់រំយុវជននិងកីឡា, ២០២១b)

ការសិក្សាមួយធ្វើឡើងដោយក្រសួងអប់រំកាលពីឆ្នាំ២០១៨បានបង្ហាញថា ដើម្បីពង្រឹងការដឹកនាំតាមសាលារៀន និងដឹកនាំការបង្រៀននៅតាមសាលារៀន នាយកសាលាត្រូវឆ្លងកាត់កម្មវិធីបំពាក់បំប៉នតម្រង់ទិសមួយដែលមានគុណភាព និងទទួលបានការអភិវឌ្ឍជាប្រចាំក្នុងអំឡុងពេលបំពេញការងារ-អាជីពរបស់ពួកគេកន្លងមក វិទ្យាស្ថានជាតិអប់រំបានអនុវត្តកម្មវិធីបំប៉ននាយកសាលារៀន។ ប៉ុន្តែបញ្ហាប្រឈមក្នុងការរក្សានិរន្តរភាពកម្មវិធីនេះគឺដោយសារការតែងតាំងនាយកសាលាធ្វើឡើងដោយរដ្ឋបាលខេត្តដែលអាចនឹងពុំបានកត់សម្គាល់កម្មវិធីបំបាក់បំប៉នខាងលើ។ (ក្រសួងអប់រំយុវជននិងកីឡា, ២០២១c)

ដោយសង្កេតឃើញនូវបញ្ហាប្រឈមនានាដែលកើតមានឡើងនិងអាចនាំទៅដល់ការអប់រំមួយដែលមិនមានប្រសិទ្ធភាពការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **ការបំពេញការងារនិងការទទួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងការបង្រៀននិងរៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តត្បូងឃ្មុំ** ពិតជាមានសារសំខាន់និងចាំបាច់មួយដើម្បីកែលម្អបញ្ហាប្រឈមមួយចំនួនដែលបាន និងកំពុងកើតមានក្នុសាលារៀនមធ្យមសិក្សាបឋមភូមិនាពេលបច្ចុប្បន្ននេះ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការលើកយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវមានគោលបំណងចំនួនពីរគឺៈ

១. ដើម្បីស្វែងយល់ពីទេពកោសល្យក្នុងការបំពេញតួនាទីនិងទំនួលខុសត្រូវរបស់នាយកសាលារៀនលើការគ្រប់គ្រង ការបង្រៀន និងរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ។

២. ដើម្បីស្វែងយល់ពីសារៈសំខាន់នៃការទទួលខុសត្រូវរបស់នាយកសាលាក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀននិងរៀននៅមធ្យមសិក្សាបឋមភូមិ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ យើងមានសំណួរស្រាវជ្រាវចំនួនពីរដូចខាងក្រោមគឺៈ

១. តើនាយកសាលាត្រូវបំពេញតួនាទី និងទំនួលខុសត្រូវក្នុងការគ្រប់គ្រងលើការបង្រៀននិងរៀនដូចម្តេចខ្លះ ?

២. តើការបំពេញតួនាទី និងការទទួលខុសត្រូវរបស់នាយកសាលាមានសារៈសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន និងរៀនដូចម្តេចខ្លះ ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្តល់សារៈសំខាន់ ជាច្រើនដល់វិស័យអប់រំ ពិសេសគាំទ្រដល់ការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់នូវចំណេះដឹង និងបទពិសោធន៍ដល់អ្នកសិក្សាស្រាវជ្រាវនានាដែលមានបំណងចង់សិក្សា ជាបន្តបន្ទាប់ពាក់ព័ន្ធនឹងប្រធានបទខាងលើ។ ម្យ៉ាងទៀតវាបានផ្តល់ឱកាស ដល់នាយកសាលា លោកគ្រូ អ្នកគ្រូ ក្នុងការចូលរួមកែលម្អការងារ របស់ខ្លួនពាក់ព័ន្ធនឹងការដឹកនាំនិងគ្រប់គ្រង ការបង្រៀននិងរៀន រដ្ឋបាលថ្នាក់ រដ្ឋបាលគ្រូ បរិស្ថាន និងការតុបតែងលម្អនានា ព្រមទាំងបង្កើនទំនាក់ទំនងល្អរវាងគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន គ្រូបង្រៀននិងគ្រូបង្រៀន គ្រូបង្រៀននិងសិស្សានុសិស្ស សាលារៀន និងសហគមន៍ជាដើម។ តាមរយៈប្រធានបទនេះក៏ជាសូចនាករមួយក្នុងការជំរុញឱ្យ នាយកសាលា គ្រូបង្រៀន អាចមានឱកាសទទួលបានស្នាដៃ ជាសាលាស្អាត នាយកល្អ គ្រូល្អ គ្រូឆ្នើមជាដើម។ ម្យ៉ាងទៀតដើម្បីធានា ថាសាលារៀនមានប្រសិទ្ធភាពក្នុងការអនុវត្តការងារគ្រប់គ្រង ឆ្លើយតបនិងឯកសារគតិយុទ្ធផ្សេងៗ(SBM)និងធានាថាលទ្ធផលសិក្សារបស់សិស្សត្រូវបានយកចិត្តទុកដាក់ និងមានភាពរីចម្រើន។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

**ក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះ « ការបំពេញការងារនិងការទទួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងការបង្រៀននិងរៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តត្បូងឃ្មុំ** » ធ្វើការសិក្សាស្រាវជ្រាវឡើងដោយផ្តោតលើការបំពេញការងារ និងការទទួលខុត្រូវរបស់នាយកសាលាដើម្បីកៀគរការចូលរួមបំពេញ

ការងារពីសំណាក់លោកគ្រូអ្នកគ្រូ ក៏ដូចជាអ្នកពាក់ព័ន្ធផ្សេងៗ និងក្នុងគោលបំណងចង់ដឹងពីទេពកោសល្យក្នុងការសឹកនាំ និងគ្រប់គ្រងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន និងរៀននៅកម្រិតអនុវិទ្យាល័យដែលទិន្នន័យនិងត្រូវប្រមូលពីលោកនាយក លោកគ្រូអ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលា សហគមន៍នៅក្នុងសាលាអនុវិទ្យាល័យចំនួនបីដែលស្ថិតក្នុងស្រុក អូរាំងឪ ខេត្ត ត្បូងឃ្មុំ គឺ អនុវិទ្យាល័យ ពោធិ៍មាស អនុវិទ្យាល័យមៀន និងអនុវិទ្យាល័យចំការស្បូវ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងអត្ថបទស្រាវជ្រាវនេះ មានប្រាំជំពូក ហើយក្នុងជំពូកនីមួយៗមានដូចជា៖

**ជំពូកទី១** លើកឡើងពី សេចក្តីផ្តើមនៃការស្រាវជ្រាវ រួមមាន៖ លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងសំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធ ។

**ជំពូកទី២** លើកឡើងពី ការរំឭកទ្រឹស្តី ដែលក្នុងនោះរួមមាន៖ ការសិក្សាពាក្យគន្លឹះ ក្របខណ្ឌគោលនយោបាយ លទ្ធផលស្រាវជ្រាវពីមុន និងទ្រឹស្តីផ្សេងៗពាក់ព័ន្ធនិងគណនេយ្យភាពក្នុងសាលារៀន។

**ជំពូកទី៣** លើកឡើងពី វិធីសាស្ត្រនៃការស្រាវជ្រាវ ដែលក្នុងនោះរួមមាន៖ គម្រោងវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។

**ជំពូកទី៤** លើកឡើងពី លទ្ធផលនៃការស្រាវជ្រាវ រួមមាន៖ ឧបករណ៍វិភាគទិន្នន័យ ដំណាក់កាលនៃការវិភាគទិន្នន័យ ការវិភាគទិន្នន័យតាមសំណួរសម្ភាសជាបន្តបន្ទាប់។

**ជំពូកទី៥** លើកឡើងពី សេចក្តីសន្និដ្ឋាន និងសំណូមពរ ដែលក្នុងជំពូកចុងក្រោយនេះ យើងនឹងបង្ហាញពីអ្វីដែលបានរកឃើញទាក់ទងនឹងការអនុវត្តការងារគណនេយ្យភាព ការងារដឹកនាំ និងគ្រប់គ្រងការបង្រៀន និងរៀនដែលនាយកសាលារៀនបានអវត្តក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការងារ និងលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងសំណូមពរមួយចំនួន ដើម្បីធ្វើឱ្យការអនុវត្តការងារក្នុងអង្គភាពប្រកប ដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

# ជំពូកទី២

## រំលឹកទ្រឹស្តី

### ២.១ លទ្ធផលនៃការស្រាវជ្រាវពីមុន

ការសិក្សាមួយនៅប្រទេសអង់គ្លេស ( Leithwood et al's,2006 ) បានទទួលស្គាល់យ៉ាងទូលំទូលាយថាភាពជាអ្នកដឹកនាំ ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកគឺជាចំណុចសំខាន់សម្រាប់សាលារៀនក្នុងការអភិវឌ្ឍ កែលម្អ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

ការដឹកនាំជាមួយនិងភាពជាអ្នកដឹកនាំបង្ហាត់បង្ហាញជាតួនាទីដ៏សំខាន់ដែលនាយកសាលាត្រូវអនុវត្តជាប្រចាំ។ នាយកសាលាជាច្រើនបានទទួលស្គាល់យ៉ាងទូលំទូលាយអំពី តួនាទីការដឹកនាំបង្រៀនរបស់គាត់នៅក្នុងសលារៀន វាគឺច្បាស់ណាស់ថានាយកសាលាគ្រប់រូបបានរក្សាអាជីព និងវិជ្ជាជីវៈរបស់ខ្លួនក្នុងការបង្ហាត់បង្ហាញនិងចែករំលែកបទពិសោធន៍ទៅដល់លោកគ្រូអ្នកគ្រូ។ នាយកសាលាជាច្រើនបាននិយាយដោយមោទនភាពចំពោះរបៀបដែលពួកគេបានធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសិក្សាល្អ ការកើនឡើងនូវលទ្ធផលសិក្សារបស់សិស្ស ការរៀបចំ និងកែសម្រួលឡើងវិញនូវកម្មវិធីសិក្សា កាលវិភាគសិក្សាដើម្បីឱ្យសិស្សទទួលបាននូវការសិក្សាមួយដែលមិនមានហានិភ័យ និងស្របទៅតាមតម្រូវការដែលពួកគេចង់បាន។ ( Karan Leigh Sanzo, ២០១០ )

នាយកសាលាមានតួនាទីសំខាន់ក្នុងការជួយសម្របសម្រួលដល់គ្រូបង្រៀនក្នុងដំណើរការអប់រំ។ ពួកគេបានបង្ហាញវត្តមានតិចតួចនៅក្នុងថ្នាក់រៀន ប៉ុន្តែគេមានតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួលនិងត្រួតពិនិត្យអាកប្បកិយារំខានទាំងឡាយក្នុងចំណោមសិស្សានុសិស្ស។ លើសពីនេះទៅទៀតនាយកសាលាក៏មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រ វិធីសាស្ត្របង្រៀន

និងអនុវត្តកម្មវិធីសិក្សារបស់គ្រូ និងណែនាំពួកគេឱ្យចេះប្រឈមមុខនិងបញ្ហាជាមួយសិស្ស។ (Tommaso et al, ២០១៨)

ការពិនិត្យមើលគោលនយោបាយ និងឯកសារស្រាវជ្រាវរបស់រាជរដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិនានា បង្ហាញឱ្យឃើញនូវការកើនឡើងនូវការតស៊ូមតិឱ្យមានការចូលរួមរបស់សហគមន៍ក្នុងការអប់រំ។ ការតស៊ូមតិនេះមួយផ្នែកគឺផ្អែកលើតម្រូវការមួយក្នុងការបែងចែកការទទួលខុសត្រូវលើការផ្តល់ធនធានសម្រាប់ប្រព័ន្ធអប់រំ ប៉ុន្តែក៏មានគោលបំណងក្នុងការបង្កើននូវទំហំ ការជាប់ទាក់ទង និងឥទ្ធិពល (ផលជះ) របស់សាលារៀនផងដែរ។ ក្របខណ្ឌគោលនយោបាយជាច្រើនដែលនៅជុំវិញចលនាទាំងនេះជាប់ទាក់ទងគ្នាជាមួយនឹងការផ្លាស់ប្តូរនានាឆ្ពោះទៅរកការធ្វើវិមជ្ឈការ ការទទួលខុសត្រូវចំពោះការអប់រំ។ ចំពោះចំណុចនេះការអប់រំសម្រាប់មនុស្សជំនាន់ថ្មីត្រូវបានគេជឿជាក់ថា ជាការទទួលខុសត្រូវរបស់មនុស្សគ្រប់គ្នាដើម្បីឱ្យគេអាចទទួលបាននូវគណនេយ្យភាពខ្ពស់។

ការសិក្សាស្រាវជ្រាវអប់រំជាច្រើនបង្ហាញថា ការចូលរួមពីភាគីដែលពាក់ព័ន្ធនានា ពោលគឺឪពុកម្តាយអាណាព្យាបាលសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាឃុំសង្កាត់ ជាពិសេសនាយកសាលារៀនផ្ទាល់ នៅក្នុងការគ្រប់គ្រងធនធាន និងបុគ្គលិករបស់សាលារៀនមានសារៈសំខាន់ណាស់ចំពោះលទ្ធផលនៃការសិក្សារបស់អ្នករៀនសូត្រ។ ក្នុងន័យនេះ គណនេយ្យភាពត្រូវបានគេមើលឃើញថាជាយន្តការមួយក្នុងចំណោមយន្តការជាច្រើនដែលលើកទឹកចិត្តឱ្យមន្ត្រីនានាធ្វើសកម្មភាព ដើម្បីផលប្រយោជន៍របស់សាធារណៈជន។( ណូហ្សាតា ហេងគ្រេង, ២០១៦)

នៅប្រទេសកម្ពុជាគោលគំនិតផ្នែកវិមជ្ឈការ និងគណនេយ្យភាពទើបតែកើតឡើងក្នុងពេលបច្ចុប្បន្នថ្មីៗនេះប៉ុណ្ណោះ។ កាលពីអតីតកាលប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជាបានរៀបចំឡើងមានលក្ខណៈមជ្ឈការមែនទែនដោយសារការចូលរួមរបស់រដ្ឋបាលថ្នាក់កណ្តាលស្ទើរតែកើតមាននៅគ្រប់ការសម្រេចចិត្តទាំងអស់សម្រាប់ការប្រតិបត្តិផ្សេងៗ។ អង្គភាពសាធារណៈនៅថ្នាក់ក្រោមជាតិមានស្វ័យភាព ឬសិទ្ធឯករាជ្យតិចតួចបំផុ

ត។ ការយល់ដឹងពីសារៈសំខាន់របស់គណនេយ្យភាពតាមរយៈវិមជ្ឈការរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តកម្មវិធីកំណែទម្រង់យ៉ាងទូលំទូលាយ ដើម្បីបង្កើតនូវស្ថាប័នបែបប្រជាធិបតេយ្យផ្សេងៗនៅថ្នាក់មូលដ្ឋាន និងធ្វើវិមជ្ឈការអំណាច (ណូហ្សាតា ហេងគ្រេង, ២០១៦) ។ នៅឆ្នាំ២០០២ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតឱ្យមានក្រុមប្រឹក្សាឃុំ/សង្កាត់ឯករាជ្យ។អ្នកទាំងឡាយដែលរស់នៅតាមតំបន់ជនបទមានសំឡេងមួយក្នុងការជ្រើសរើសអ្នកដឹកនាំតាមមូលដ្ឋានរបស់ខ្លួន ទោះបីជាអភិបាលស្រុក និងខេត្តនៅតែត្រូវបានតែងតាំងដោយរដ្ឋាភិបាលថ្នាក់កណ្តាលក៏ដោយ ។( Sandara &Ojendal, 2007 )

នៅក្នុងវិស័យអប់រំ ការចូលរួមរបស់ភាគីដែលពាក់ព័ន្ធខុសៗគ្នានៅក្នុងដំណើរការសាលារៀនបានចាប់ផ្តើមជាមួយនិងកម្មវិធី កម្រងសាលារៀន ដែលត្រូវបានគេណែនាំនៅក្នុឆ្នាំ១៩៩២។ នៅពេលដែលកម្មវិធីនេះត្រូវបានគេវាយតម្លៃថាបានទទួលជោគជ័យចំពោះជំនួយបច្ចេកទេសដល់គ្រូបង្រៀន និងនាយកសាលា (Turner, ២០០២) នាយកសាលាមានតួនាទីក្នុងការរៀបចំ និងបង្កើតឡើងនូវគណៈកម្មការផ្សេងដើម្បីឱ្យសាលារៀនមានដំណើរការដោយយប្រក្រតីភាព ហើយសមាសសភាពដែលជាសមាជិកត្រូវធ្វើការជ្រើសរើសប្រកបដោយតម្លាភាព គណនេយ្យភាព ចេញពីសហគមន៍ អាជ្ញាធរដែនដី និងគ្រប់ភាគី ដែលពាក់ព័ន្ធផ្សេងៗទៀត។

## ២.២ មុខងាររបស់នាយកសាលារៀន

តួនាទីរបស់នាយកសាលាគ្របដណ្តប់លើវិស័យខុសៗគ្នាជាច្រើនរួមមាន ភាពជាអ្នកដឹកនាំ ការវាយតម្លៃគ្រូនិងការវិនិច្ឆ័យ សិស្ស និងជាច្រើនទៀត។ ការធ្វើជានាយកសាលាដ៏មានប្រសិទ្ធិភាពគឺជាការខិតខំនិងត្រូវចំណាយពេលច្រើន។ នាយកសាលាល្អគឺមានតុល្យភាពនៅក្នុងតួនាទីរបស់ពួកគេទាំងអស់ហើយធ្វើការយ៉ាងលំបាកដើម្បីធានាថាពួកគេកំពុងធ្វើអ្វីដែលពួកគេគិតថាល្អបំផុតសម្រាប់អ្នកចូលរួមទាំងអស់។ ពេលវេលាគឺជាកត្តាចំបងសម្រាប់នាយកសាលាទាំងអស់។ នាយកសាលាមួយត្រូវមានប្រសិទ្ធិភាពក្នុងការអនុវត្តដូចជាការកំណត់អាទិភាពការកំណត់កាលវិភាគនិងការរៀបចំ។

### ២.២.១ តួនាទីជាមេដឹកនាំសាលា

នាយកសាលា គឺជាអ្នកដឹកនាំសំខាន់នៅក្នុងអគារសិក្សា។ អ្នកដឹកនាំល្អតែងតែនាំមុខដោយគំរូ។ នាយកសាលាគួរមានភាពវិជ្ជមាន មានចំណង់ខ្លាំង មានស្នាដៃនៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់សាលារៀននិងស្តាប់នូវអ្វីដែលសមាជិកក្នុងអង្គភាពកំពុងនិយាយ។ អ្នកដឹកនាំដែលមានប្រសិទ្ធិភាពអាចរកបានសម្រាប់គ្រូបង្រៀនសមាជិកបុគ្គលិកឪពុកម្តាយ សិស្សនិស្សិត និងសមាជិកសហគមន៍។ អ្នកដឹកនាំល្អមានភាពស្ងប់ស្ងាត់ក្នុងស្ថានភាពលំបាកគិតមុនពេលពួកគេធ្វើហើយដាក់តម្រូវការរបស់សាលារៀនជាសំខាន់។ អ្នកដឹកនាំដ៏មានប្រសិទ្ធិភាពឈានទៅបំពេញតាមតម្រូវការបើទោះបីជាវាមិនមែនជាផ្នែកមួយនៃទម្លាប់ប្រចាំថ្ងៃរបស់ពួកគេក៏ដោយ។

### ២.២.២ តួនាទីក្នុងការរៀបចំវិន័យរបស់សិស្ស

ផ្នែកដ៏ធំមួយនៃការងាររបស់នាយកសាលាគឺដើម្បីគ្រប់គ្រងវិន័យរបស់សិស្ស។ ជំហានដំបូងនៃការ មានវិន័យសិស្សមានប្រសិទ្ធភាព គឺត្រូវប្រាកដថាគ្រូរបស់អ្នកដឹងពីអ្វីដែលអ្នករំពឹងទុកនៅពេលដែលវិន័យរបស់សិស្សត្រូវបានរៀបចំ។ នៅពេលដែលពួកគេយល់ពីរបៀបដែលអ្នកចង់ឱ្យពួកគេដោះស្រាយវានោះការងាររបស់អ្នកនឹងកាន់តែងាយស្រួល។ វិន័យដែលអ្នកដោះស្រាយនឹងភាគច្រើនមកពី ការបញ្ជូន គ្រូ។ មានពេលខ្លះវាអាចយកមួយផ្នែកធំនៃថ្ងៃ។

នាយកសាលាដ៏ល្អ នឹងស្តាប់គ្រប់ផ្នែកទាំងអស់នៃបញ្ហាមួយដោយគ្មានការសន្និដ្ឋានដែលប្រមូលភស្តុតាងច្រើនតាមដែលអ្នកអាចធ្វើបាន។ តួនាទីសំខាន់នៅក្នុងវិន័យរបស់សិស្សនិស្សិតគឺដូចជាចៅក្រមនិងចៅក្រម។ អ្នកសម្រេចចិត្តថាតើសិស្សមានពិរុទ្ធពីបទល្មើសវិន័យហើយតើគួរដាក់ទោសអ្វី។ នាយកសាលាដែលមានប្រសិទ្ធិភាពតែងតែរក្សាឯកសារវិន័យ ធ្វើការសម្រេចចិត្តដោយយុត្តិធម៌និងជូនដំណឹងដល់ឪពុកម្តាយនៅពេលចាំបាច់។

### ២.២.៣ តួនាទីជាអ្នកវាយតម្លៃគ្រូ

នាយកសាលាភាគច្រើនទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធផលនៃការបង្រៀនរបស់គ្រូរបស់ពួកគេបន្ទាប់ពីការណែនាំរបស់ស្រុកនិងរដ្ឋ។ សាលាដែល មាន ប្រសិទ្ធិភាព ត្រូវ មានគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព ហើយ ដំណើរការវាយតម្លៃគ្រូ ត្រូវបានធ្វើឡើងដើម្បីធានាថាគ្រូបង្រៀននៅក្នុងសាលារបស់អ្នកមានប្រសិទ្ធិភាព។ ការវាយតម្លៃគួរតែមានភាពយុត្តិធម៌និងចងក្រងជាឯកសារបានចង្អុលបង្ហាញចំណុចខ្លាំងនិងចំណុចខ្សោយ។

ចំណាយពេលវេលាដែលមានគុណភាពច្រើននៅក្នុងថ្នាក់រៀនរបស់អ្នកតាមតែអាចធ្វើទៅបាន។ ប្រមូលព័ត៌មានរាល់ពេលដែលអ្នកទៅទស្សនាសូម្បីតែវាគ្រាន់តែសម្រាប់ពីរបីនាទីប៉ុណ្ណោះ។ ការធ្វើបែបនេះអាចឱ្យអ្នកវាយតម្លៃមានភស្តុតាងកាន់តែច្រើនដែលបង្ហាញពីអ្វីដែលកើតឡើងក្នុងថ្នាក់រៀនជាងអ្នកដែលមានទស្សនកិច្ចតិចតួចនៅក្នុងថ្នាក់រៀន។ អ្នកវាយតម្លៃល្អតែងតែអនុញ្ញាតឱ្យគ្រូរបស់ពួកគេដឹងពីអ្វីដែលពួកគេរំពឹងទុកហើយបន្ទាប់មកផ្តល់យោបល់សម្រាប់ភាពប្រសើរឡើងប្រសិនបើការរំពឹងទុកទាំងនោះមិនត្រូវបានឆ្លើយតប។

### ២.២.៤ តួនាទីក្នុងការអភិវឌ្ឍ អនុវត្ត និងវាយតម្លៃកម្មវិធី

ការអភិវឌ្ឍការអនុវត្តនិងវាយតម្លៃកម្មវិធីនៅក្នុងសាលារៀនគឺជាផ្នែកមួយទៀតនៃតួនាទីរបស់នាយកសាលា។ នាយកសាលាគួរតែស្វែងរកវិធីដើម្បីលើកកម្ពស់បទពិសោធសិស្សនៅឯសាលារៀន។ ការបង្កើតកម្មវិធីដែលមានប្រសិទ្ធភាពដែលគ្របដណ្តប់លើវិស័យផ្សេងៗគ្នាគឺជាវិធីមួយដើម្បីធានាបាននូវចំណុចនេះ។ វាអាចទទួលយកបានក្នុងការមើលសាលារៀនផ្សេងៗនៅក្នុងតំបន់របស់អ្នកនិងដើម្បីអនុវត្តកម្មវិធីទាំងនោះនៅក្នុងសាលារៀនផ្ទាល់ខ្លួនរបស់អ្នកដែលបានបង្ហាញថាមានប្រសិទ្ធិភាពនៅកន្លែងផ្សេង។ កម្មវិធីនៅក្នុងសាលារៀនរបស់អ្នកគួរតែត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំហើយត្រូវបានគេកែសម្រួលបើចាំបាច់។ ប្រសិនបើកម្មវិធី

អានរបស់អ្នកកាន់តែរឹងមាំហើយសិស្សរបស់អ្នកមិនមានកំនើនច្រើនទេនោះវាប្រហែលជាចាំបាច់ដើម្បីពិនិត្យឡើងវិញនូវកម្មវិធីនិងធ្វើការផ្លាស់ប្តូរខ្លះៗដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាពនៃកម្មវិធីនោះ។

### ២.២.៥ តួនាទីក្នុងការពិនិត្យឡើងវិញនូវគោលនយោបាយ និងកម្មវិធី

ឯកសារគ្រប់គ្រងរបស់សាលារៀននីមួយៗគឺសៀវភៅសិស្ស។ នាយកសាលាគួរតែមានត្រារបស់ពួកគេនៅលើសៀវភៅដែ។ នាយកសាលាគួរតែពិនិត្យឡើងវិញដកចេញសរសេរឬសរសេរគោលនយោបាយនិងនីតិវិធីជារៀងរាល់ឆ្នាំតាមការចាំបាច់។ ការមានសៀវភៅសិស្សដែលមានប្រសិទ្ធិភាព អាចបង្កើនគុណភាពនៃការអប់រំដែលសិស្សរបស់អ្នកទទួលបាន។ វាក៏អាចធ្វើឱ្យការងាររបស់នាយកសាលាមានភាពងាយស្រួលជាងមុនដែរ។ តួនាទីរបស់នាយកសាលាគឺដើម្បីធានាថាសិស្សានុសិស្សនិងឪពុកម្តាយដឹងពីគោលនយោបាយនិងនីតិវិធីទាំងនេះហើយនិងឱ្យបុគ្គលនីមួយៗទទួលខុសត្រូវក្នុងការអនុវត្តតាម។

### ២.២.៦ តួនាទីក្នុងការកំណត់កាលវិភាគ

ការបង្កើតកាលវិភាគជារៀងរាល់ឆ្នាំអាចជាការងារដ៏គួរឱ្យខ្លាច។ វាអាចចំណាយពេលខ្លះដើម្បីធ្វើឱ្យអ្វីៗធ្លាក់ចូលទៅក្នុងកន្លែងត្រឹមត្រូវ។ មានកាលវិភាគខុសគ្នាជាច្រើនដែលនាយកសាលាអាចតម្រូវឱ្យបង្កើតរួមបញ្ចូលទាំងកាលវិភាគជួងតារាងពេលវេលាកាតព្វកិច្ចកម្មវិធីកុំព្យូទ័របណ្តោះអាសន្នបណ្ណាល័យជាដើម។ ពិនិត្យឆ្លងកាត់កាលវិភាគនីមួយៗដើម្បីប្រាកដថាអ្នកមិនដាក់ច្រើនពេកលើនរណាម្នាក់។ មនុស្សម្នាក់នៅពេលតែមួយអាចជាការលំបាក។

ជាមួយនឹងការកំណត់ពេលវេលាដែលអ្នកត្រូវធ្វើវាស្មើរតែមិនអាចធ្វើឱ្យអ្នករាល់គ្នារីករាយជាមួយនឹងកាលវិភាគរបស់ពួកគេ។ ឧទាហរណ៍គ្រូបង្រៀនមួយចំនួនដូចជាផែនការរបស់ពួកគេជាលើកដំបូងនៅពេលព្រឹកនិងអ្នកដទៃដូចពួកគេនៅចុងបញ្ចប់នៃថ្ងៃប៉ុន្តែវាមិនអាចទៅរួចទេក្នុងការទទួលយកពួកគេទាំងអស់។ វាប្រហែលជាល្អបំផុតក្នុងការបង្កើតកាលវិភាគដោយមិនចាំបាច់ព្យាយាមសម្រុះសម្រួលនរណាម្នាក់។ ដូចគ្នា

នេះផងដែរ, ត្រូវបានរៀបចំដើម្បីធ្វើឱ្យការលៃតម្រូវទៅកាលវិភាគរបស់អ្នកនៅឆ្នាំចាប់ផ្តើម។ អ្នកត្រូវតែមានភាពបត់បែនពីព្រោះមានពេលវេលាដែលមានជម្លោះដែលអ្នកមិនដឹងមុនថាត្រូវផ្លាស់ប្តូរ។

### ២.២.៧ តួនាទីក្នុងការរៀបចំផែនការជ្រើសរើសគ្រូបង្រៀនថ្មី

ផ្នែកមួយដ៏សំខាន់នៃការងាររបស់អ្នកគ្រប់គ្រងសាលាគឺជួលគ្រូបង្រៀននិងបុគ្គលិកដែលនឹងធ្វើការងាររបស់ពួកគេឱ្យបានត្រឹមត្រូវ។ ជួលមនុស្សខុសអាចបណ្តាលឱ្យអ្នកឈឺក្បាលយ៉ាងខ្លាំងនៅលើបន្ទាត់ខណៈពេលដែលជួលមនុស្សដែលត្រឹមត្រូវធ្វើឱ្យការងាររបស់អ្នកកាន់តែងាយស្រួល។ ដំណើរការសំភាសន៍គឺមានសារៈសំខាន់ណាស់នៅពេល ជួលគ្រូបង្រៀនថ្មី ។ មានកត្តាជាច្រើនដែលចូលទៅក្នុងមនុស្សម្នាក់ដែលជាបេក្ខជនដ៏ល្អសម្រាប់អ្នកដើម្បីជួល។ ទាំងនោះរួមមានការបង្រៀនចំណេះដឹងបុគ្គលិកលក្ខណៈភាពស្មោះត្រង់ភាពរំភើបចំពោះអាជីពជាដើម។

នៅពេលអ្នកបានសម្ភាសបេក្ខជនទាំងអស់របស់អ្នកនោះវាសំខាន់ណាស់ក្នុងការហៅសេចក្តីយោងរបស់ពួកគេដើម្បីទទួលអារម្មណ៍ពីអ្វីដែលអ្នកដែលស្គាល់ពួកគេគិតថាពួកគេនឹងធ្វើ។ បន្ទាប់ពីដំណើរការនេះអ្នកអាចបង្រួមវាទៅជាបេក្ខជន ៣-៤ នាក់ល្អបំផុតរបស់អ្នកហើយសុំឱ្យពួកគេត្រលប់មកសំភាសន៍ជាលើកទីពីរវិញ។ ពេលនេះសូមឱ្យ ជំនួយការនាយក គ្រូឬគ្រូម្នាក់ទៀតចូលរួមជាមួយអ្នកដើម្បីឱ្យអ្នកអាចមានប្រតិកម្មរបស់អ្នកផ្សេងក្នុងដំណើរការជួល។ នៅពេលដែលអ្នកបានបញ្ចប់ដំណើរការនេះបន្ទាប់មកដាក់ចំណាត់ថ្នាក់បេក្ខជនរបស់អ្នកនិងផ្តល់ជូនបុគ្គលដែលអ្នកគិតថាល្អបំផុតសម្រាប់តំណែងនេះ។ ត្រូវប្រាកដថាឱ្យបេក្ខជនដែលអ្នកមិនជួលអោយដឹងថាទីតាំងត្រូវបានបំពេញ។

### ២.២.៨ តួនាទីក្នុងការទំនាក់ទំនងជាមួយមាតាបិតា និងសហគមន៍

ការមានទំនាក់ទំនងល្អជាមួយឪពុកម្តាយនិងសមាជិកសហគមន៍អាចផ្តល់ផលប្រយោជន៍ដល់អ្នកនៅក្នុងវិស័យផ្សេងៗ។ ប្រសិនបើអ្នកបានកសាងទំនាក់ទំនងដែលទុកចិត្តជាមួយមាតាឬបិតាដែលកូនរបស់គាត់

មានវិន័យវិន័យនោះវាងាយស្រួលក្នុងការដោះស្រាយស្ថានភាពប្រសិនបើមាតាបិតាគាំទ្រសាលារៀននិងការសម្រេចចិត្តរបស់អ្នក។ ដូចគ្នានេះដែរវាពិតសម្រាប់សហគមន៍។ ការកសាងទំនាក់ទំនងជាមួយបុគ្គលនិងអាជីវកម្មនៅក្នុងសហគមន៍អាចជួយសាលារបស់អ្នកយ៉ាងខ្លាំង។ អត្ថប្រយោជន៍រួមមានការបរិច្ចាគពេលវេលាផ្ទាល់ខ្លួននិងការគាំទ្រជាវិជ្ជមានសម្រាប់សាលារៀនរបស់អ្នក។ វាគឺជាផ្នែកមួយដ៏សំខាន់នៃការងាររបស់នាយកសាលាណាម្នាក់ក្នុងការបិញ្ចឹមបីបាច់ទំនាក់ទំនងរបស់ពួកគេជាមួយមាតាបិតានិងសមាជិកសហគមន៍។

### ២.២.៩ តួនាទីក្នុងការធ្វើប្រតិភូកម្ម

មេដឹកនាំជាច្រើនដោយធម្មជាតិមានការលំបាកក្នុងការដាក់អ្វីនៅក្នុងដៃផ្សេងទៀតដោយគ្មានត្រាផ្ទាល់របស់ពួកគេនៅលើវា។ ទោះយ៉ាងណាក៏ដោយមានកិច្ចការជាច្រើនដែលត្រូវធ្វើដែលមានសារៈសំខាន់ណាស់ដែលថានាយកសាលាតម្រូវឱ្យមានភារកិច្ចមួយចំនួននៅពេលចាំបាច់។ ការមានមនុស្សនៅជុំវិញអ្នកដែលអ្នកទុកចិត្តទាំងស្រុងនឹងធ្វើឱ្យកាន់តែងាយស្រួល។ នាយកសាលាដែលមានប្រសិទ្ធិភាពមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើអ្វីៗគ្រប់យ៉ាងដែលត្រូវធ្វើដោយខ្លួនឯងនោះទេ។ ពួកគេត្រូវពឹងផ្អែកលើអ្នកដទៃដើម្បីជួយពួកគេក្នុងការទទួលបានអ្វីដែលបានធ្វើហើយទុកចិត្តថាពួកគេនឹងធ្វើការងារឱ្យបានល្អ។ ( Meador, ២០២១ )

## ២.៣ តួនាទីរបស់នាយក ឬនាយិកាសាលារៀន

### ២.៣.១.តួនាទីរបស់នាយក ឬនាយិកាសាលារៀន

នាយកឬនាយិកាសាលារៀនមានតួនាទីជាអាជ្ញាធរអប់រំជាមន្ត្រីរដ្ឋបាលជាទីប្រឹក្សាគរុកោសល្យជាអធិការអប់រំអេចិន្ត្រៃយ៍និងជាភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍។

#### ២.៣.១.១.ជាអាជ្ញាធរអប់រំ

នាយក ឬនាយិកាសាលារៀន ជាប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំ យុវជន និងកីឡាប្រចាំភូមិសាស្ត្រសិក្សារបស់សាលារៀននីមួយៗ។ គាត់ជាអ្នកធានាទាក់ទងការងារ រវាងសាលារៀន និងថ្នាក់លើ។ គាត់ជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទបញ្ញាសិក្សា និងអត្ថបទផ្លូវការទាំងឡាយ។ នាយក ឬនាយិកាសាលារៀនដឹកនាំគ្រប់សកម្មភាពក្នុងសាលារៀន និងធានាឱ្យបាននូវប្រសិទ្ធភាពតាមគោលដៅអប់រំដែលបានគ្រោងទុក។ នាយក ឬនាយិកាសាលារៀនទទួលខុសត្រូវទាំងស្រុងចំពោះសាលារៀន និងថ្នាក់លើនូវរាល់អ្វីដែលកើតមានឡើងក្នុងដែននៃការគ្រប់គ្រងពិតប្រាកដរបស់ខ្លួន។

### ២.៣.១.២.ជាមន្ត្រីរដ្ឋបាល

នាយក ឬនាយិកាសាលារៀន ជាអ្នកណែនាំ អនុវត្តរដ្ឋបាលសិក្សាទាំងអស់នៅក្នុងសាលារៀន ដោយធានាធ្វើឱ្យសម្រេចនូវគោលនយោបាយអប់រំដោយរិះរកគ្រប់មធ្យោបាយ និងវិធានការចាំបាច់ដើម្បីធ្វើឱ្យសកម្មភាពនៃការដឹកនាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

### ២.៣.១.៣.ជាទីប្រឹក្សាគរុកោសល្យ

ក្នុងឋានៈជាគ្រូបង្រៀន និងជាគ្រូបង្រៀនមានបទពិសោធន៍ល្អ នាយកនាយិកាសាលារៀនមានសិទ្ធិអំណាចណែនាំគរុកោសល្យដល់គ្រូបង្រៀនក្រោមឱវាទនូវល្បិចវិធីសាស្ត្រ និងគន្លឹះល្អៗនៃការបង្រៀន។ នាយក នាយិកាសាលារៀននឹងអាចបំពេញភារកិច្ចនេះបានលុះត្រាណាជានិច្ចកាលត្រូវស្វ័យសិក្សានិងអភិវឌ្ឍន៍សម្បទាចិត្ត - គរុកោសល្យគ្មានឈប់ឈរ គ្រូបង្រៀនតែងផ្តល់កិត្តិយស និងគោរពនាយក ឬនាយការសាលារៀនដែលមានសម្បទាអាចធានាការរៀបចំគរុកោសល្យបានល្អ។

### ២.៣.១.៤.ជាអធិការអប់រំអចិន្ត្រៃយ៍

នាយក ឬនាយិកាសាលារៀនមានសិទ្ធិត្រួតពិនិត្យ និងជួយកែលម្អសកម្មភាពអប់រំគ្រប់ផ្នែក ជាពិសេសសកម្មភាពបង្រៀន និងរៀន។ ក្រោយពេលអធិការកិច្ចម្តងៗ បន្ទាប់ពីការសំណេះសំណាលស្វែងយល់

ពីគ្នាទៅវិញទៅមក លោកអធិការអេប់រំតែងធ្វើការណែនាំមួយចំនួនដើម្បីឲ្យមានការអភិវឌ្ឍពោលគឺនាយកនាយិកាសាលារៀនដែលជាអធិការអេប់រំអែចិន្ត្រៃយ៍បន្តណែនាំឱ្យអនុវត្ត ជួយកែលម្អ និងវាយតម្លៃដើម្បីឲ្យបានសម្រេចទៅតាមស្មារតីនៃការណែនាំរបស់លោកអធិការអប់រំ។

### ២.៣.១.៥.ជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍

នាយក ឬនាយការសាលារៀន គឺជាភ្នាក់ងារដ៏សំខាន់ និងចាំបាច់នូវការអភិវឌ្ឍន៍របស់សហគមន៍ជាពិសេសអភិវឌ្ឍចិត្តគំនិត និងស្មារតី។ នាយកឬ នាយិកាសាលារៀនមានសិទ្ធិចូលរួមគ្រប់សកម្មភាពរបស់សហគមន៍ពីតួនាទី និងភារកិច្ច "ការអប់រំសម្រាប់ទាំងអស់គ្នា" និង "ទាំងអស់គ្នាសម្រាប់ការអប់រំ"។ ( នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ,២០០៦ )

## ២.៣.២.ភារកិច្ចរបស់នាយក ឬនាយិកាសាលារៀន

ដើម្បីដំណើរការសាលារៀនខ្លួនបានល្អ នាយក ឬនាយិកាសាលារៀនមានភារកិច្ចទទួលខុសត្រូវលើការងាររដ្ឋបាល បច្ចេកទេស គរុកោសល្យ និងទំនាក់ទំនង។

### ២.៣.២.១.ការងាររដ្ឋបាល

ការងាររដ្ឋបាល គឺត្រូវធានាដំណើរការល្អរបស់សាលារៀន អនុវត្តបទបញ្ជាសិក្សា និងអត្ថបទណែនាំផ្លូវការរបស់ក្រសួងអប់រំ បែងចែកសិស្សតាមថ្នាក់ ចាត់តាំងបែងចែកភារកិច្ចដល់បុគ្គលិកក្រោមឱវាទតាមសំណើរបស់ក្រុមប្រឹក្សា របស់គ្រូបង្រៀន ធាននិយ័តភាពក្នុងការសិក្សា ត្រៀមថែរក្សាការពារបរិស្ថានសោភ័ណភាព និងអនាម័យក្នុងសាលារៀន ការធ្វើផែនការអភិវឌ្ឍសាលារៀន ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិកនិងផែនការទំនាក់ទំនងជាមួយសហគមន៍។ សោភ័ណភាព និងអនាម័យក្នុងសាលារៀន ដូចជាទីធ្លា ថ្នាក់រៀន តូបលក់នំចំណី ដើមឈើធ្វើជាម្លប់ សួនច្បារជាដើម។ លើសពីនេះទៀតការងាររដ្ឋបាលត្រូវធានាឱ្យសាលារៀនអាចបំពេញបាននូវសេវាសាធារណៈទទួលកុមារ និងការការពារកុមារ រក្សាសណ្តាប់ធ្នាប់ និងវិន័យក្នុងគ្រឹះស្ថានសិក្សាចូលរួមបង្កើតក្រុមប្រឹក្សានានា ចាត់តាំងប្រជុំដឹកនាំការប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មការ

នានា។ ក្រៅពីនេះក៏ត្រូវចាត់តាំងការចូលរួមក្នុងសកម្មភាពសង្គមបន្ថែមទៀត រៀបចំចាត់ចែងការបណ្តុះបណ្តាលនៅទីកន្លែង ឬបញ្ជូនទៅបណ្តុះបណ្តាលនៅថ្នាក់លើ រៀបចំចាត់ការសាលារៀន រៀបចំការងារលិខិតស្នាម និងរក្សាទុកលិខិតស្នាម បែងចែកមធ្យោបាយសម្រាប់ធ្វើការងារផ្សេងៗសមស្របទៅតាមការងារ និងកម្រិតថ្នាក់នីមួយៗ និងធ្វើរបាយការណ៍ជូនថ្នាក់លើអំពីសកម្មភាពនានារបស់សាលារៀន ការងាររដ្ឋបាលត្រូវធ្វើ ជាអាជ្ញាកណ្តាលផ្សះផ្សារទំនាស់ផ្សេងៗដែលកើតមានឡើងនៅក្នុងសាលារៀន កសាងផែនការសាលារៀន និងបែងចែកកម្មវិធីការងារប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំឲ្យបានច្បាស់លាស់ក្នុងនោះត្រូវរៀបចំឲ្យបានល្អនូវវិធានការសមស្របនានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការងារយ៉ាងល្អិតល្អន់ធ្វើតារាងស្ថិតិនានា គ្រប់គ្រងមូលដ្ឋានសម្ភារៈឱ្យបានម៉ត់ចត់ ដោយជៀសវាងការខ្ជះខ្ជាយបញ្ជីសារពើភ័ណ្ឌ បញ្ជីចែកចាយ និងបញ្ជីបញ្ចេញ-បញ្ចូលឃ្លាំង ចាត់តាំងការប្រើប្រាស់ប្រាស់ និងថែរក្សាអគារសិក្សា និងចលនវត្ថុទាំងឡាយឲ្យបានចំទិសដៅ និងទទួលខុសត្រូវជាមួយគណៈកម្មការទ្រទ្រង់សាលារៀននៅចំណូលនិងចំណាយថវិការបស់សាលារៀន។ នាយក ឬនាយការសាលារៀនត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមបែបបទគណនេយ្យភាពចំពោះថវិកាសាលារៀន និងត្រូវទទួលស្គាល់ការពិតដែលថាអំណាចផ្តាច់ការគឺគេស្អប់ណាស់ ពោលគឺត្រូវដឹកនាំ និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដោយធ្វើសកម្មភាពទាំងឡាយគោរពភាពយុត្តិធម៌ និងភាពត្រឹមត្រូវច្បាស់លាស់។ ការអភិវឌ្ឍសាលារៀនមួយបានមកពីការប្រមូលបទពិសោធន៍ល្អៗនិងគំនិតផ្តួចផ្តើមល្អៗ និងគណនេយ្យករល្អៗ បង្កើតមិត្តភាពល្អៗ និងប្រសិទ្ធភាពការងារ។

ចំណែកឯការងារបច្ចេកទេសគរុកោសល្យវិញ គឺត្រូវរក្សាឲ្យបានខ្ជាប់ខ្ជួននូវតួនាទីជាទីប្រឹក្សាគរុកោសល្យ ជាអ្នកជីវចលនាគរុកោសល្យ ផ្សព្វផ្សាយ និងណែនាំ អនុវត្តនូវសៀវភៅសិក្សាថ្មី សារាចរណែនាំនានាឲ្យបានទូលំទូលាយ ត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សាគ្រប់ថ្នាក់លើខ្លឹមសារត្រឹមត្រូវតាមមុខវិជ្ជា ការប្រើវិធីសាស្ត្រថ្មីដែលគ្រូណែនាំ និងជួយសិស្សឲ្យធ្វើសកម្មភាពច្រើន រៀបចំកាលវិភាគប្រចាំសប្តាហ៍ទៅតាមថ្នាក់នីមួយៗ និងចូលរួមបំប៉នគ្រូតាមរយៈទស្សនកិច្ចថ្នាក់រៀន ត្រួតពិនិត្យកិច្ចតែងការបង្រៀន ការដឹកនាំការ

បង្រៀន ការប្រើប្រាស់សៀវភៅសិស្ស សៀវភៅគ្រូ បញ្ជីពិន្ទុ បញ្ជីហៅឈ្មោះ ការងាររដ្ឋបាលថ្នាក់។ ជាងនេះទៀត ការងារបច្ចេកទេស គរុកោសល្យ គឺត្រូវជានាសហការចាំបាច់រវាងគ្រូបង្រៀនទាំងអស់ក្នុងសាលារៀន ដើម្បីជាគុណប្រយោជន៍ដល់ការពង្រឹងគុណភាពបង្រៀន និងរៀន ណែនាំគ្រូបង្រៀនគ្រប់មុខវិជ្ជាជៀសវាងការរំលងមុខវិជ្ជាណាមួយដែលខ្លួនមិនពេញចិត្ត ឬមិនមានបំណិនប្រសព្វ ផ្គត់ផ្គង់សៀវភៅសិក្សា និងឯកសារព្រមទាំងជំរុញការប្រជុំបច្ចេកទេស តាមចង្កោមថ្នាក់ដោយមានរបៀបវារៈច្បាស់លាស់និងចូលរួមបណ្តុះបណ្តាលអនាគតនាយក ឬនាយិកាសាលារៀន។ ជាពិសេសត្រូវលើកទឹកចិត្តគ្រូឱ្យមានការស្រាវជ្រាវវិធីបង្រៀនថ្មីៗ ស្រាវជ្រាវ និងប្រើប្រាស់សម្ភារៈឧបទេសថ្មីៗ ដើម្បីជួយសម្រួលដល់ការបង្រៀន និងរៀន ផ្តល់មតិយោបល់ និងជួយគ្រូក្នុងការអនុវត្តវិជ្ជាជីវៈជាដំបូងរបស់ខ្លួន រក្សាឲ្យបាននូវបរិយាកាសគរុកោសល្យក្នុងសាលារៀន និងក្នុងថ្នាក់រៀន បន្តអនុវត្តមតិណែនាំរបស់លោកអធិការអប់រំ ចាត់តាំងកសាងសម្ភារៈឧបទេសសម្រាប់ការបង្រៀន និងរៀន។ ការងារបច្ចេកទេសគរុកោសល្យត្រូវចូលរួមបង្រៀនជំនួសកាលណាមានអវត្តមានគ្រូគ្រប់គ្រងថែរក្សារាល់លិខិតបច្ចេកទេសចាត់តាំងរាល់សកម្មភាពក្រៅម៉ោងសិក្សា និងជម្រុញណែនាំសិស្សានុសិស្សឲ្យរៀននៅផ្ទះ និងនៅក្លឹបសិក្សាស្របតាមសុភាសិត "រៀនថ្ងៃមិនគ្រប់រៀនយប់បន្ថែម"។ ជាងនេះទៀតការងារបច្ចេកទេសគរុកោសល្យគឺ ត្រូវជានាជម្រុញការបញ្ចប់កម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់ និងគ្រប់មុខវិជ្ជាប្រកបដោយគុណភាព ជានាបន្តការសិក្សានៅអនុវិទ្យាល័យ វិទ្យាល័យ និងឧត្តមសិក្សា និងវង្វាយតម្លៃលទ្ធផលសិក្សាជាដំណាក់ និងជាកញ្ចប់។

### ២.៣.២.២.ការងារបច្ចេកទេសគរុកោសល្យ

ដើម្បីប្រសិទ្ធភាពនៃការងារគ្រប់គ្រងអង្គភាពសាលារៀន ការគ្រប់គ្រងរដ្ឋបាល និងការងារបច្ចេកទេសគរុកោសល្យនោះ ទោះបីមានដំណើរការល្អយ៉ាងណាក៏ដោយ ក៏នាយក ឬនាយិការសាលារៀនមិនអាចដឹកនាំសាលារៀនបានល្អប្រកបដោយប្រសិទ្ធភាពបានដែរប្រសិនបើខ្វះទំនាក់ទំនងផ្ទៃក្នុងសាលារៀនមាននាយករង ឬនាយិការង គ្រូបង្រៀន បុគ្គលិកផ្សេងៗ និងសិស្សានុសិស្ស និងខាងក្រៅសាលារៀនមានមាតា បិតាសិស្ស

សហគមន៍ អាជ្ញាធរដែនដី ព្រះគ្រូចៅអធិការវត្ត ព្រះសង្ឃ អាចារ្យគណៈកម្មការ សប្បុរសជនជាតិ និងអន្តរជាតិ។

### ក.ការងារទំនាក់ទំនងផ្ទៃក្នុង

នាយក ឬនាយិការសាលារៀនត្រូវមានទំនាក់ទំនងល្អជាមួយសហសេវិករួមការងារ និងអ្នកនៅក្រោមឱវាទ។ នាយក ឬនាយិការសាលារៀនត្រូវប្រគល់ភារកិច្ចឲ្យនាយករង ឬនាយិការងដែលជាអ្នកជំនួយការឲ្យបានសមស្របតាមសមត្ថភាព និងតាមភារកិច្ចដែលបានកំណត់ គ្រូបង្រៀន បុគ្គលិកផ្សេងៗបែងចែកភារកិច្ចឱ្យសមនឹងសមត្ថភាព ហើយសិស្សានុសិស្ស នាយក ឬនាយការសាលារៀនត្រូវបង្ហាញឲ្យសិស្សទាំងអស់បានឃើញថា រាល់ការខិតខំប្រឹងប្រែងរបស់នាយក ឬនាយការសាលារៀន ឬលោកគ្រូ អ្នកគ្រូបង្រៀន ឬសហគមន៍ និងវិធានការវិនិច្ឆ័យចំពោះសិស្ស គឺដើម្បីជួយសិស្សទាំងអស់ឲ្យសម្រេចបាននូវលទ្ធផលល្អនៃការសិក្សាដែលបង្កលក្ខណៈឲ្យពួកគេមានអនាគតល្អនៅពេលពួកគេចេញពីសាលារៀន។

### ខ.ការងារទំនាក់ទំនងខាងក្រៅ

ក្នុងតួនាទី និងភារកិច្ចទទួលខុសត្រូវក្នុងការដឹកនាំអង្គភាពមួយ នាយក ឬនាយិកាសាលារៀនត្រូវចំណាយពេលវេលាមួយចំនួនដើម្បីប្រាស្រ័យទាក់ទងជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស សហគន៍ សប្បុរសជនជាតិ និងអន្តរជាតិ អាជ្ញាធរដែនដី ភូមិ ឃុំ ស្រុក ខេត្ត និងភ្នាក់ងារស្ថាប័ននានាក្នុងស្រុកភូមិពេទ្យ សហគមន៍ និងសមាគមកីឡា និងព្រះគ្រូចៅអធិការ ព្រះសង្ឃ គណៈកម្មការអាចារ្យវត្តជាដើម។( នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ,២០០៦ )

## ២.៤. នាយក ឬនាយិកាសាលារៀនល្អ

**ការដឹកនាំនិងគ្រប់គ្រង៖** មានរចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន និងបំណែងចែកភារកិច្ចទទួលខុសត្រូវច្បាស់លាស់ មានប្រសិទ្ធភាពនិងភាពសាកសិទ្ធក្នុងការបែងចែកការងារសាលារៀន មានសម្ភារបរិក្ខារនិងសម្ភា

រៈឧបទេសសម្រាប់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពបរិស្ថានល្អសម្រាប់ការរៀនសូត្រ និងអភិវឌ្ឍន៍។

**ការបង្រៀននិងរៀន៖** ការបង្រៀន និងរៀនអនុវត្តតាមកម្មវិធីសិក្សាមានការប្រើប្រាស់គរុកោសល្យ និងវិធីសាស្ត្រគ្រប់គ្រាន់ពាក់ព័ន្ធនឹងគោលបំណងនៃការបង្រៀនមេរៀន ការបង្រៀនសមស្របតាមតម្រូវការរបស់សិស្ស គ្រូបង្កើតបរិយាកាសលើកទឹកចិត្តសិស្សអោយខិតខំរៀនសូត្រ និងគ្រូបន្តកែលម្អការបង្រៀនរបស់ខ្លួន។

**លទ្ធផលសិក្សារបស់សិស្ស៖** លទ្ធផលសិក្សារបស់សិស្សមានការរីកចម្រើនច្រើនជាបន្តបន្ទាប់ សាលារៀនមានកម្មវិធីដំណើរការល្អដើម្បីធានាឱ្យសិស្សមានវត្តមាននៅក្នុងសាលារៀន ការវាយតម្លៃ និងការដាក់ពិន្ទុធ្វើឡើងប្រកបដោយសមធម៌ យុត្តិធម៌ និងតម្លាភាព។ ស្វ័យវាយតម្លៃសាលារៀន៖ មានប្រព័ន្ធដែលមានដំណើរការពិនិត្យតាមដាន និងវាយតម្លៃគុណភាពការងាររបស់សាលារៀន សាលារៀនមានផែនការអភិវឌ្ឍន៍ និងមានការសហការ និងប្រាស្រ័យទាក់ទងនៅគ្រប់កម្រិតទាំងអស់ក្នុងសាលារៀន។ (MoEYS, ២០១៦)។

## ២.៥ លក្ខណៈសម្បត្តិរបស់នាយកសាលាល្អ

នាយកសាលាល្អ សំដៅលើអ្នកដឹកនាំល្អចូលរួមអភិវឌ្ឍវិស័យអប់រំ និងគ្រប់គ្រងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាព។ ខាងក្រោមនេះជាលក្ខណៈសម្បត្តិមួយចំនួនរបស់នាយកសាលាល្អ ៖

**១. បុគ្គលមានចំណេះដឹងខ្ពស់ និងបទពិសោធន៍ការងារ៖** នាយកសាលាល្អត្រូវមានកម្រិតវប្បធម៌ទាបបំផុតត្រឹមបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឬប្រសិទ្ធផលគ្រប់គ្រាន់ និងមានវិញ្ញាបនបត្រវិជ្ជាជីវៈនាយកសលារៀន ។ លើសពីនេះ នាយកសាលាល្អត្រូវមានចំណេះដឹងមូលដ្ឋាន ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ។ ម្យ៉ាងវិញទៀត នាយកត្រូវមានកម្រិតវប្បធម៌ទូលំទូលាយ មានចំណេះដឹងជំនាញភាសាបរទេសប្រើប្រាស់ក្នុងការទំនាក់ទំនង និងធ្លាប់មានបទពិសោធបំពេញការងារជាគ្រូបង្រៀនយ៉ាងតិចប្រាំឆ្នាំ ។

**២. បុគ្គលមានបំណិនត្រិះរិះពិចារណា និងនវានុវត្តន៍៖** នាយកសាលាល្អចាំបាច់ត្រូវស្វែងយល់អំពីក្របខណ្ឌគតិយុត្ត តាមរយៈការអភិវឌ្ឍសមត្ថភាព ការពង្រឹងយន្តការ និងគោលការជំរុញប្រសិទ្ធភាពការងារដោយមានការចូលរួមដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ។ លើសពីនេះ សូចនាករសំខាន់ៗរួមមាន ចក្ខុវិស័យ បេសកកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្រការត្រួតពិនិត្យ ការអនិវត្តចក្ខុវិស័យ និងផែនការសកម្មភាព និងវាយតម្លៃការងារ ។ ដូចគ្នា នាយកសាលាល្អ មានការគិត និងវិភាគដោយប្រមូលភស្តុតាំងក្នុងការដោះស្រាយបញ្ហាឱ្យប្រសើរឡើងក្នុងការបំពេញការងារ ។

**៣. បុគ្គលមានភាពជាអ្នកដឹកនាំល្អ ៖** នាយកសាលាល្អត្រូវគ្រប់គ្រងរដ្ឋបាលសាលារៀនឱ្យមានការអភិវឌ្ឍកាន់តែល្អប្រសើរលើគ្រប់ផ្នែក ប្រកបដោយគុណភាព និងប្រសិទ្ធភាព ។ លើសពីនេះ ត្រូវអនុវត្តលើការងារបរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយ័តភាពការងារ ការត្រួតពិនិត្យវាយតម្លៃការផ្តល់សេវា ការគ្រប់គ្រងនិន្នន័យបុគ្គលិក ថ្នាក់រៀន សិស្ស និងការរៀបចំផែនការសកម្មភាពជាដើម ។ នាយកសាលាល្អ ត្រូវធ្វើជាគម្រូក្នុងការដឹកនាំ និងការប្រតិបត្តិល្អសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ។

**៤. បុគ្គលមានសមត្ថភាពគ្រប់គ្រងការរៀន និងបង្រៀន៖** នាយកសាលាល្អជំរុញលើកទឹកចិត្តសិស្សឱ្យស្វ័យសិក្សាជាប្រចាំ។ លើសពីនេះ រៀបចំក្រុមបច្ចេកទេស និងកិច្ចប្រជុំបច្ចេកទេសឱ្យបានទៀតទាត់ ជំរុញការស្រាវជ្រាវល្អៗ ដើម្បីឱ្យការបង្រៀនរបស់គ្រូកាន់តែមានប្រសិទ្ធភាព។ ម៉្យាងវិញទៀត ចូលរួមពិនិត្យ កែលម្អ អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា ។ នាយកសាលាល្អត្រូវលើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលាឱ្យទទួលបានការសិក្សាស្រាវជ្រាវបន្ថែម ។

**៥. បុគ្គលគ្រប់គ្រងសាលារៀនផ្សារភ្ជាប់នឹងសហគមន៍៖** នាយកសាលាល្អបង្កើនទំនាក់ទំនងជិតស្និទ្ធយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធនានាដើម្បីអភិវឌ្ឍន៍សាលារៀន ។ លើសពីនេះ ពង្រឹងការគ្រប់គ្រងដឹកនាំដោយបង្ហាញឱ្យឃើញច្បាស់អំពីផែនការ ការទទួលខុសត្រូវ តម្លាភាព

និងមិនប្រកាន់បក្សពួក ។ ម្យ៉ាងវិញទៀត នាយកសាលាត្រូវកសាងទំនុកចិត្ត ដោយខិតខំបង្កើនសមិទ្ធផល លទ្ធផលសិក្សាល្អ គោរពធន្ទៈរួម មានការលះបង់ មានចក្ខុវិស័យ បេសកកម្ម រចនាសម្ព័ន្ធច្បាស់លាស់ ។

៦. **បុគ្គលមានក្រមសីលធម៌វិជ្ជាជីវៈ៖** នាយកសាលាល្អ ត្រូវប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន ពង្រឹងសាមគ្គីភាព គោរពវិន័យការងារ រក្សាការសង្ងាត់វិជ្ជាជីវៈ និងមានភាពស្មោះត្រង់ ។ លើសពីនេះ ផ្តល់តម្លៃដល់អ្នកសិក្សា មិនរើសអើង មិនប្រើអំពើហិង្សា មានសីលធម៌រស់នៅល្អប្រកបដោយគុណធម៌ យុត្តិធម៌ សុភវិនិច្ឆ័យ និងការពិគ្រោះយោបល់ផ្អែកលើកស្តុតាំងជាក់ស្តែង។(គីមសល់, ២០២១)

## ២.៦ សេចក្តីព្រាងស្តង់ដាវិជ្ជាជីវៈនាយកសាលារៀន

យោងសេចក្តីព្រាងស្តង់ដាវិជ្ជាជីវៈនាយកសាលារៀនចំណោះទូទៅ មាន៥សមាសភាគ ១៦សមត្ថភាព ៤២សមត្ថភាពរង ១៣៦ស្តង់ដាសមត្ថភាព។

### សមាសភាគទី១៖ ការគិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍

១. ការលើកផែនការទឹសដៅយុទ្ធសាស្ត្រសម្រាប់សាលារៀន៖ នាយកសាលារៀនមានការទទួលខុសត្រូវក្នុងការធ្វើសកម្មភាផ្សេងៗជាមួយបុគ្គលិក្នុងសាលារៀន សហគមន៍ និងគ្រប់ភាគីពាក់ព័ន្ធដើម្បីរៀបចំ និងអភិវឌ្ឍនូវផែនការយុទ្ធសាស្ត្ររបស់សាលារៀន។ នាយក/នាយិកាសាលាត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងអំពីនីតិវិធីក្នុងការធ្វើផែនការយុទ្ធសាស្ត្រ ព្រមទាំងមានចក្ខុវិស័យច្បាស់លាស់ជាមួយសាលារៀន និងអ្នកពាក់ព័ន្ធក្នុងសហគមន៍អភិវឌ្ឍសាលារៀនដែលនាំការសិក្សាប្រកបដោយប្រសិទ្ធភាព។ ក្នុងនោះផងដែរ សមត្ថភាពដែលនាយក/នាយិកាសាលាត្រូវមានគឺ បង្កើតគោលបំណងជាក់លាក់ដើម្បីសម្រេចឱ្យបានចក្ខុវិស័យអភិវឌ្ឍសាលារៀន ធានាថាផែនការមានភាពពេញលេញនូវតម្រូវការសម្រាប់សមាជិកសហគមន៍សាលារៀន ផ្សព្វផ្សាយផែនការឱ្យបានទូលំទូលាយ ដល់ភាគីពាក់ព័ន្ធដើម្បីអនុវត្ត និងធ្វើជាម្ចាស់ផែនការ។

២. ដឹកនាំការអនុវត្តផែនការយុទ្ធសាស្ត្រ៖ សមត្ថភាពក្នុងការដឹកនាំ និងគ្រប់គ្រងក្នុងអង្គភាពដូចជា ធ្វើប្រតិភូកម្មមានប្រសិទ្ធភាពដើម្បីសម្រេចគោលបំណងផែនការយុទ្ធសាស្ត្រ ចាត់ចែងការប្រើប្រស់ធនធាន ដែលមាននៅពេលត្រូវការ ជានាថាធនធានមនុស្ស ហិរញ្ញវត្ថុនិងសម្ភារគ្រប់គ្រាន់ពេលត្រូវការ ពិនិត្យតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រ និងប្រើប្រាស់លទ្ធផលការតាមដានសម្រាប់កែលម្អសកម្មភាពផ្សេងៗទៀត។

៣. បង្ហាញពីចក្ខុវិស័យ និងធ្វើជាគម្រូបង្ហាញពីតម្លៃការងារ និងការប្រតិបត្តិជារៀងរាល់ថ្ងៃ៖ មានភាពបត់បែនក្នុងការធ្វើសេចក្តីសម្រេចចិត្តស្របតាមចក្ខុវិស័យ និងគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ ធ្វើការជាមួយភាគីពាក់ព័ន្ធដើម្បីបង្កើបរិយាកាសវិជ្ជមានក្នុងសាលារៀន ធានាថានាយកសាលា និងបុគ្គលិកធ្វើការជាមួយគ្នាសំដៅសម្រេចឱ្យបានតាមគោលបំណងរបសើផែនការ។

៤. ការធ្វើសេចក្តីសម្រេចចិត្ត៖ មានសមត្ថភាពក្នុងការប្រើទិន្នន័យជាភស្តុតាងដើម្បីគាំទ្រ តាមដាន វាយតម្លៃ និងកែលម្អផែនការយុទ្ធសាស្ត្រ អាន និងប្រើប្រាស់ព័ត៌មានដែលទទួលបានពីប្រភពផ្សេងៗ ប្រើទិន្នន័យព័ត៌មានដែលរកឃើញដើម្បីកែលម្អផែនការយុទ្ធសាស្ត្រសាលារៀន ធានាថាទិន្នន័យ និងសូចនាករ របស់សាលារៀនអាចជឿទុកចិត្តបាន ធានាថាទិន្នន័យ និងសូចនាករមានភាពទាក់ទងគ្នាហើយអ្នកពាក់ព័ន្ធ អាចយកប្រើប្រាស់បានក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងក្របខណ្ឌសាលារៀនផ្ទាល់។

៥. ពិនិត្យកែលម្អជាទៀងទាត់នូវការអនុវត្តផែនការដើម្បីដោះស្រាយបញ្ហា៖ នាយក/នាយិកាសាលា ត្រូវធ្វើការ ដឹកនាំប្រមូលទិន្នន័យសម្រាប់កែលម្អការបំពេញការងាររបស់សាលារៀន វិភាគទិន្នន័យ (ឧទាហរណ៍សូចនាករបំពេញការងាររបស់សាលា)ដើម្បីជួយបន្ថែមវឌ្ឍនៈភាពសំដៅសម្រេចគោលបំណង នៅក្នុងផែនការយុទ្ធសាស្ត្រសាលារៀន ធ្វើអាទិភាពការដោះស្រាយបញ្ហាតាមត្រូវការដើម្បីសម្រេចឱ្យបាននូវការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍសាលារៀន។

៦. ការដឹកនាំឱ្យមានការផ្លាស់ប្តូរ រីចម្រើន និងនវានុវត្តន៍៖ ដឹកនាំដំណើរការនៃការផ្លាស់ប្តូររីកចម្រើន ដើម្បីបង្កើតឡើងនូវវិធីថ្មីៗហើយល្អសម្រាប់ធ្វើការងារ វាយតម្លៃការអប់រំតាមមូលដ្ឋាន និងលក្ខណ្ឌតម្រូវគោល នយោបាយអប់រំជាតិដើម្បីដោះស្រាយតម្រូវការជាក់ស្តែសម្រាប់អភិវឌ្ឍសាលារៀន លើកទឹកចិត្តបុគ្គលិក សាលារៀនដើម្បីអភិវឌ្ឍគំនិតថ្មីៗសម្រាប់ការបង្រៀន និងរៀនមានប្រសិទ្ធភាព អនុវត្តគំនិតថ្មីក្នុងការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពស្របទៅតាមតម្រូការសលារៀននិងសហគមន៍មូលដ្ឋាន

៧. ទ្រទ្រង់គំនិតថ្មីៗសម្រាប់ការរៀនមានប្រសិទ្ធភាពនៅក្នុងសហគមន៍សាលារៀន៖ ទទួលស្គាល់ និង ផ្តល់រង្វាន់ដល់បុគ្គលិកសាលារៀនដែលអនុវត្តបានជោគជ័យនូវគំនិតថ្មីៗដើម្បីកែលម្អការបង្រៀន និងរៀន មានប្រសិទ្ធភាព វាយតម្លៃលទ្ធផលនៃការអនុវត្តគំនិតថ្មីនេះដើម្បីកែលម្អការបំពេញការងាររបស់សាលារៀន ចែករំលែកការអនុវត្តល្អៗជាមួយដៃគូក្នុងស្រុកឬសាលារៀនដ៏ទៃដើម្បីផ្លាស់ប្តូរ និងទទួលបាននូវបទពិសោធន៍ ថ្មីៗ។

**សមាសភាគទី២៖ ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន**

**១. ការដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា**

១.១ គ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា៖ ពិនិត្យកែលម្អកម្មវិធីសិក្សា និងធនធានសិក្សាឱ្យបាន ទៀងទាត់ដើម្បីធានាឱ្យបាននូវការបង្រៀន និងរៀនមានប្រសិទ្ធភាព ដឹកនាំអភិវឌ្ឍ និងអនុវត្តកម្មចិធីសិក្សា រៀបចំប្រជុំជាមួយបុគ្គលិក និងសហគមន៍ឱ្យបានទៀងទាត់ដើម្បីកែលម្អការអនុវត្តកម្មវិធីសិក្សា និងការ បង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព ផ្តួចផ្តើមសកម្មភាពល្អៗ ដែលនាំឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាព

១.២ ជំរុញឱ្យមានការចាប់អារម្មណ៍លើកម្មវិធីនៃការបង្រៀន និងរៀនផ្សេងៗគ្នា៖ ត្រូវធានាថា គ្រូបង្រៀនធ្វើការសម្រាប់បរិយាប័ន្នដល់សិស្សគ្រប់ប្រភេទមិនមានការរើសអើង ធានាថាគ្រូបង្រៀនផ្តល់ ការងារឬបង្រៀនសិស្សឱ្យឆ្លើយតបនឹងតម្រូវការផ្សេងៗគ្នារបស់សិស្សទាំងអស់

## ២. ការបង្កើតបរិស្ថានអ្នកសិក្សាមជ្ឈមណ្ឌល

២.១ ធ្វើការជាមួយគ្រូបង្រៀន៖ វាយតម្លៃការងារសិស្សដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្រៀន និងរៀនមានប្រសិទ្ធភាព ពិនិត្យបរិស្ថានសិក្សាដើម្បីធានាឱ្យទីកន្លែងសិក្សាស្អាត និងមានសណ្តាប់ធ្នាប់ល្អ ដែលធ្វើឱ្យសិស្សរៀនប្រកបដោយប្រសិទ្ធភាព ធានាថាគ្រូបង្រៀនលើកទឹកចិត្តសិស្សឱ្យចេះឆក់ឱកាសសិក្សាដោយខ្លួនឯង ធានាថាគ្រូបង្រៀនប្រើគរុកោសល្យបង្រៀនមានប្រសិទ្ធភាពតាមរយៈការតាមដានជាប្រចាំ

២.២ ជំរុញឱ្យបរិស្ថានសិក្សាមានសុខភាព សុវត្ថិភាព និងបរិយាបន្ន៖ ធានាថាសម្ភាររូបវន្ត និងធនធានសិក្សារបស់សាលាអ្នកសិក្សាទាំងអស់មានសិទ្ធប្រើបាន ថែរក្សាបរិស្ថានសាលារៀនឱ្យមានសុវត្ថិភាព ស្អាត និងគ្មានគ្រោះថ្នាក់ វាយតម្លៃផលប៉ះពាល់បរិស្ថានសាលារៀនដែលមានឥទ្ធិពលដល់លទ្ធផលការសិក្សាសិស្ស។

២.៣ ជំរុញឱ្យមានវប្បធម៌សន្តិភាព និងគោរពភាពទីទៃៗពីគ្នា៖ អនុវត្តគោលនយោបាយសាលារៀនដែលជំរុញឱ្យមានសន្តិភាព និងមានការគោរពពិពិធកម្ម ធានាឱ្យការអប់រំមានសន្តិភាព និងគោរពពិពិធកម្មវប្បធម៌ ដែលគ្រូបានបង្កប់ក្នុងកម្មវិធីសិក្សា និងអនុវត្តជារៀងរាល់ថ្ងៃនៅក្នុងថ្នាក់រៀន ធ្វើប្រតិភូកម្មការទទួលខុសត្រូវឱ្យគ្រូបង្រៀន និងសមាជិកក្រុមប្រឹក្សាសិស្សទទួលខុសត្រូវ

## ៣. ការងារអធិការកិច្ច និងវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន

៣.១ ការអនុវត្តគម្រូសមស្របសម្រាប់អធិការកិច្ច និងការវាយតម្លៃ៖ បង្ហាញពីចំណេះដឹង និងការយល់ដឹងពីនីតិវិធីត្រឹមត្រូវសម្រាប់អធិការកិច្ច អភិវឌ្ឍ និងអនុវត្តប្រតិទិនតាមដានការបង្រៀន និងការរៀន វាយតម្លៃការងារគ្រូបង្រៀននៅក្នុងថ្នាក់រៀន ផ្តល់ព័ត៌មានត្រឡប់ដល់គ្រូបង្រៀនដែលអាចអនុវត្តបានមេរៀនប្រចាំថ្ងៃ វាយតម្លៃប្រសិទ្ធភាពមេរៀនផ្អែកលើភាពជោគជ័យនៃការសិក្សាធៀបនិងវត្ថុបំណងមេរៀន។

៣.២ អប់រំគ្រូដែលមានឧបនិស្ស័យជាអ្នកដឹកនាំ៖ កំណត់បានអ្នកដែលមានឧបនិស្ស័យដឹកនាំ និងជួយអភិវឌ្ឍពួកគេ ធានាថាមុខងារសំខាន់ៗរបស់អ្នកដឹកនាំត្រូវបានផ្ទេរជូន គាំទ្របុគ្គលិកដែលស្ថិតក្នុងភារកិច្ចជាអ្នកដឹកនាំ។

**៤. ការផ្តល់លទ្ធសិក្សាតាមផែនការ**

**៤.១ ជំរុញឱ្យមានគោលវិធីផ្អែកលើក្រុមការងារចំពោះភាពជាអ្នកដឹកនាំការបង្រៀននិងរៀន៖** លើកទឹកចិត្តគ្រូបង្រៀនក្នុងការចែករំលែកការប្រតិបត្តិល្អៗដើម្បីលើកកម្ពស់ការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព ផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីចែករំលែកការប្រតិបត្តិល្អៗ តាមដានគំនិតផ្តួចផ្តើមរបស់ក្រុម។

**៤.២ គ្រប់គ្រងវាយតម្លៃដើម្បីកែលម្អការបង្រៀន និងរៀន៖** ធានាថាការវាយតម្លៃគឺស្មើភាព ត្រឹមត្រូវ មានតម្លាភាព និងទៀងទាត់ ធានាថាលទ្ធផលនៃការវាយតម្លៃត្រូវបានដាក់ឱ្យភាគីពាក់ព័ន្ធប្រើប្រាស់បាន ធានាថាការវាយតម្លៃការសិក្សាត្រូវបានប្រើប្រាស់ដើម្បីជូនដំណឹងដល់ការធ្វើកិច្ចតែងការបង្រៀនសម្រាប់ការបង្រៀន និងរៀនមានប្រសិទ្ធភាព។(ក្រសួងអប់រំយុវជននិងកីឡា, ២០១៨)

## ២.៧ ភារកិច្ច និងការទទួលខុសត្រូវរបស់នាយកសាលា

បេសកកម្មរបស់**នាយក ឬនាយិកាសាលាបឋមសិក្សា**ត្រូវរក្សាភាពជាអ្នកដឹកនាំប្រកបដោយវិជ្ជាជីវៈសម្រាប់ សាលារៀន ដើម្បីធានាភាពជោគជ័យ និងការរីកចំរើនរបស់សាលារៀន។ នាយក ឬនាយិកាត្រូវផ្តល់ការអប់រំ ប្រកបដោយគុណភាពខ្ពស់ ចំពោះសិស្សានុសិស្សទាំងអស់ និងស្តង់ដារនៃការសិក្សា និងសមិទ្ធផលល្អ។

### ២.៧.១ រៀបចំទិសដៅយុទ្ធសាស្ត្រ និងការអភិវឌ្ឍសាលារៀន

នាយកសាលាមានទំនួលខុសត្រូវក្នុងការផ្តល់ការដឹកនាំបំផុសគំនិត និងកំណត់គោលបំណង សម្រាប់បុគ្គលិក និងសិស្សានុសិស្ស ធ្វើការជាមួយឪពុកម្តាយសិស្ស និងគណៈគ្រប់គ្រងសាលា ដើម្បីបង្កើនការចូលរួមរបស់ពួកគាត់នៅសាលារៀនយើង និងការអភិវឌ្ឍធនធានសម្រាប់សាលារៀន បន្តការអនុវត្តន៍ផែនការអភិវឌ្ឍន៍ ដើម្បីជានាឲ្យមានការរីកចំរើនជាបន្តបន្ទាប់ដល់សាលារៀន ត្រួតពិនិត្យ និងវាយតំលៃការអនុវត្តរបស់សាលារៀន និងឆ្លើយតប និងធ្វើរបាយការណ៍ ជូននាយិកាគរុកោសល្យ និងនាយកប្រតិបត្តិសាលា តាមតម្រូវការ ត្រូវរៀបចំរបាយការណ៍សង្ខេបនូវលទ្ធផល ហើយបកស្រាយនាពេលប្រជុំផ្នែកគរុកោសល្យ បន្ទាប់ពី ការប្រឡងនីមួយៗ ជានាថា គោលដៅ និងការអនុវត្តរបស់សាលារៀនយកចិត្តទុកដាក់លើតម្រូវការថ្នាក់ជាតិ ថ្នាក់តំបន់ និងការសិក្សាអប់រំ បង្កើតកាលវិភាគគោលប្រចាំឆ្នាំ សម្រាប់កម្មវិធីសិក្សា ដោយផ្អែកលើកម្មវិធីសិក្សាជាតិដែលចេញ ដោយក្រសួងអប់រំយុវជន និងកីឡា ជានាថា រាល់ឯកសារទាំងអស់ត្រូវបានរៀបចំជាស្រេច តាមតម្រូវការរបស់ក្រសួងអប់រំ (ឧទាហរណ៍ សៀវភៅរដ្ឋបាល) រៀបចំការចុះអធិការកិច្ចរបស់ក្រសួងអប់រំ បើសិនចាំបាច់។

លើសពីនេះទៅទៀតនាយកសាលាក៏មានទំនួលខុសត្រូវលើការវាយតម្លៃការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស

ដូចជាៈ ផ្ទៀងផ្ទាត់ និងពិនិត្យពិន្ទុ ការចុះបញ្ជី និងរបាយការណ៍លទ្ធផលនៃការប្រឡង ដើម្បីវាយតំលៃ ការកើនឡើង និងការរីកចំរើនរបស់សិស្ស ដឹកនាំការវាយតំលៃសិស្សានុសិស្សដូចជាៈ(១) **សំណួរប្រចាំខែ** ពិនិត្យមើលការចុះបញ្ជីលទ្ធផលប្រចាំខែ (២) **ការប្រឡងឆមាស** ៈពិនិត្យឡើងវិញនូវសំណួរ / លំហាត់ប្រឡងឆមាស ដែលស្នើឡើងដោយគ្រូបង្រៀ ត្រួតពិនិត្យ និងជ្រើសរើសសំណួរ / លំហាត់ប្រឡងស្នើឡើងជាមួយនាយិកា រៀបចំ និងត្រួតពិនិត្យការកែវិញ្ញាសាប្រឡង ផ្ទៀងផ្ទាត់ និងត្រួតពិនិត្យអត្រាកំណែដែលបានបង្កើតឡើង

ដោយគ្រូបង្រៀន ពិនិត្យមើលគ្រប់ឯកសារប្រឡងកែដោយគ្រូបង្រៀន វាយតម្លៃផលលំបាកក្នុងការរៀនរបស់សិស្សានុសិស្ស និងពិគ្រោះយោបល់ជាមួយពួកគាត់

### ២.៧.២ ការដឹកនាំ និងគ្រប់គ្រងបុគ្គលិក

ក្នុងការដឹកនាំ និងគ្រប់គ្រងក្នុងអង្គភាពគ្នាមួយធនធានមនុស្សគឺជារឿងសំខាន់ និងជាការចាំបាច់មួយដែលនាយកសាលាត្រូវយកចិត្តទុកដាក់ មានភាពប៉ិនប្រសព្វក្នុងការរៀបចំដូចជា៖ រៀបចំផែនការ បែងចែកគាំទ្រ និងវាយតំលៃការងារដែលបានអនុវត្ត លក្ខណៈជាក្រុម (ក្រុម និងបុគ្គល) ដើម្បីជានានូវការបែងចែកភារកិច្ចច្បាស់លាស់ និងការទទួលខុសត្រូវនានា ស្របតាមលក្ខខណ្ឌការងារ រៀបចំ និងតាមដានឯកសារសម្រង់វត្តមានប្រចាំសប្តាហ៍ និងទាក់ទងទៅការិយាល័យធនធានមនុស្ស អនុវត្ត និងរក្សាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព ចំពោះការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក រួមបញ្ចូលទាំងសមត្ថភាពគ្រប់គ្រង និងការកំណត់គោលដៅ អនុវត្តការវាយតម្លៃការងារប្រចាំឆ្នាំរបស់បុគ្គលិកទាំងអស់ ពង្រឹង និងតាមដានបន្តការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិក រួមទាំងការបណ្តុះបណ្តាលគ្រូបង្រៀននូវសមត្ថភាពថ្មីៗ។

គិតគូដល់ការអភិវឌ្ឍសមត្ថភាពជាប្រចាំឆ្លើយតបនិងគោលនយោបាយរបស់ក្រសួងក្នុងការអភិវឌ្ឍវិជ្ជាជីវៈដូចជា

លើកកម្ពស់ ការសិក្សាស្រាវជ្រាវ និងបង្កើតបច្ចេកទេសបង្រៀនថ្មីៗ បណ្តុះបណ្តាលគ្រូបង្រៀនអំពីបច្ចេកទេសបង្រៀនថ្មីៗ ស្រាវជ្រាវ និងផ្តល់នូវប្រភពឯកសារផ្សេងៗសម្រាប់គ្រូបង្រៀន ដើម្បីងាយស្រួលក្នុងការបង្រៀន រៀបចំវគ្គបណ្តុះបណ្តាលក្រៅសាលារៀន បើសិនចាំបាច់។

### ២.៧.៣ ការរៀបចំបុគ្គលិក និងធនធានប្រកបដោយគុណភាព និងប្រសិទ្ធភាព

នាយកសាលាមានទំនួលខុសត្រូវលើការបំពេញការងារយ៉ាងស្និទ្ធជាមួយការិយាល័យធនធានមនុស្ស ក្នុងការគ្រប់គ្រងគ្រូបង្រៀន ជ្រើសរើសបុគ្គលិក រក្សាទុក រៀបចំបុគ្គលិក សហការគ្នាប្រកបដោយប្រសិទ្ធភាព ដើម្បីរក្សា និងលើកកម្ពស់គុណភាពនៃការអប់រំដែលបានផ្តល់។ បង្កើតការរៀបចំសម្រាប់ធានានូវសុវត្ថិភាព និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដល់សិស្សានុសិស្ស កំណត់នូវការងារអាទិភាពឲ្យបានត្រឹមត្រូវ ចំពោះរាល់ការចំណាយ ការប្រើប្រាស់ថវិកា និងប្រសិទ្ធភាព គ្រប់គ្រង តាមដាន និងពិនិត្យឡើងវិញនូវការរៀបចំ គុណភាព និងការប្រើប្រាស់ធនធានទាំងអស់ ដើម្បីកែលម្អគុណភាពនៃការអប់រំ សមិទ្ធិផលរបស់សិស្ស និងធានានូវប្រសិទ្ធភាព។

### ២.៧.៤ គណនេយ្យភាព

បន្តអភិវឌ្ឍការរៀបចំជូនបុគ្គលិកទាំងអស់ ដើម្បីឲ្យពួកគាត់ដឹងថា ពួកគាត់មានសារៈសំខាន់ និងជាអ្នកទទួលខុស ត្រូវចំពោះភាពជោគជ័យរបស់សាលារៀន ជានាថា ឪពុកម្តាយរបស់សិស្ស ការងារ និងសិស្សទាំងអស់ បានដឹងច្បាស់លាស់អំពីកម្មវិធីសិក្សា លទ្ធផលសិក្សា និងការរីកចំរើន និងអំពីការចូលរួមចំណែករបស់ពួកគាត់ ដើម្បីផ្តល់នូវការគាំទ្រការរៀនសូត្រដល់កូនៗរបស់ពួកគាត់ និងសំរេចបាននូវគោលដៅនៃការកែលម្អរបស់សាលារៀន អនុវត្តភារកិច្ចឲ្យបានត្រឹមត្រូវតាមការស្នើសុំដោយគណៈគ្រប់គ្រងសាលារៀន បុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់មានសិទ្ធិអាចលើកឡើងនូវការព្រួយបារម្ភ ទាក់ទិនការអនុវត្តមិនប្រក្រតី ឬគ្រោះថ្នាក់ ប៉ះពាល់ដល់សិស្សានុសិស្ស ហើយការព្រួយបារម្ភទាំងនេះត្រូវបានដោះស្រាយប្រកបដោយភាពម៉ត់ចត់ និងប្រសិទ្ធភាពទាន់ពេលវេលា។

### ២.៧.៥ ការងារបច្ចេកទេស៖ ការបង្រៀន និងការរៀន

បន្តការការពារបរិស្ថានដែលលើកកម្ពស់ និងធានានូវការបង្រៀនដ៏ល្អ ការរៀនសូត្រប្រកបដោយស្តង់ដារខ្ពស់ ក្នុងការបំពេញការងារ និងអាកប្បកិរិយាល្អ ត្រួតពិនិត្យ និងវាយតម្លៃគុណភាពការបង្រៀន និងការ

រៀន និងស្តង់ដារក្នុងការបំពេញការងាររបស់សិស្សទាំងអស់ នៅក្នុងសាលារៀនតាមរយៈវិធីសាស្ត្រសមស្រប ត្រួតពិនិត្យដំណើរការបង្រៀន និងការរៀន ធ្វើការជាមួយគ្រូបង្រៀន ដើម្បីអភិវឌ្ឍសៀវភៅលំហាត់ ធ្វើការជាមួយគ្រូបង្រៀន ដើម្បីកែលម្អសម្ភារៈបង្រៀន

- អធិការកិច្ចផ្ទៃក្នុង៖ រៀបចំ និងអនុវត្តការចុះអធិការកិច្ចថ្នាក់រៀនឲ្យបានទៀងទាត់ វាយតម្លៃការបង្រៀនរបស់គ្រូ

បង្រៀន ផ្តល់មតិយោបល់ដល់គ្រូបង្រៀន ដើម្បីកែលម្អការបង្រៀនរបស់ពួកគាត់ សរសេររបាយការណ៍ស្តីពីការចុះអធិការកិច្ចគ្រូបង្រៀន ហើយផ្ញើរជូននាយិកាសាលា

- ការអភិវឌ្ឍវិជ្ជាជីវៈ ៖រៀបចំ និងដឹកនាំការប្រជុំបច្ចេកទេសប្រចាំខែដឹកនាំការបង្រៀនលក្ខណៈជាដៃគូរឲ្យបា

ទៀងទាត់ ដើម្បីពង្រឹងចំណេះដឹងនៃខ្លឹមសារមុខវិជ្ជានីមួយៗ រៀបចំការបង្រៀនខ្នាតតូច ឬការសិក្សាមេរៀន ដើម្បីពង្រឹងការបង្រៀនតាមថ្នាក់នីមួយៗ ធានាថា សិស្សានុសិស្សទាំងអស់អភិវឌ្ឍសមត្ថភាពសិក្សារបស់ខ្លួន ដើម្បីរៀនសូត្រឱ្យកាន់តែមានប្រសិទ្ធិភាព និងបង្កើននូវឯករាជ្យភាព។

រៀបចំថ្នាក់បំប៉ននៅពេលចាំបាច់ ផ្តល់ជំនួយដល់គ្រូបង្រៀនដែលមានសិស្សពិបាករៀនក្នុងការបង្រៀនកំណត់ រៀបចំ និងអនុវត្តគោលការណ៍ សម្រាប់ការអភិវឌ្ឍន៍បុគ្គល សង្គម និងសីលធម៌របស់សិស្សានុសិស្ស។ សហការជាមួយការិយាល័យសង្គម និងសុខភាព និងប្រធានអនុរក្សក្នុងការអភិវឌ្ឍទំនាក់ទំនង កំណត់ និងអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីវិជ្ជមានដែលធានាឱ្យមានឥរិយាបថ និងវិន័យល្អរបស់សិស្ស និងផ្តល់ការ គាំទ្រ និងការណែនាំច្បាស់លាស់អំពីការលើកលែងទោស ធ្វើការសហការជាមួយប្រធានអនុរក្ស ចំពោះរាល់បញ្ហាទាំងអស់អំពីអាកប្បកិរិយារបស់សិស្ស របាយការណ៍អំពីអាកប្បកិរិយាមិនសមរម្យ ការសំរេច

ចិត្តនៃការដាក់ទណ្ឌកម្ម បន្តរក្សាភាពជាដៃគូប្រកបដោយប្រសិទ្ធភាពជាមួយឪពុកម្តាយសិស្ស និងសហគមន៍ទាំងមូល ដើម្បីគាំទ្រ និងលើក កម្ពស់សមិទ្ធផលរបស់សិស្ស និងការអភិវឌ្ឍខ្លួនផ្ទាល់ រៀបចំការប្រជុំមាតាបិតាសិស្សទូទៅឲ្យបានទៀងទាត់ ត្រួតពិនិត្យ និងរៀបចំការប្រជុំជាលក្ខណៈបុគ្គល ជាមួយឪពុកម្តាយរបស់សិស្សដែលជួបការលំបាក។( Toutesàl'école, 2017 )

## ២.៨ សមត្ថភាពរបស់នាយកសាលានៅតំបន់អាស៊ី

### ២.៨.១ ការគិតបែបយុទ្ធសាស្ត្រ និងនវានុវត្តន៍

នាយកសាលារៀនគឺជាអ្នកកាន់ចង្កូនសម្រាប់សាលារៀនមួយដូចនេះពួកគាត់ត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីឱ្យបុគ្គលិកក្នុងអង្គភាពមានទំនុកចិត្ត និងមានភាពកក់ក្តៅក្នុងការអនុវត្តការងារផ្សេងៗដែលក្នុងនោះរួមមាន ១) សមត្ថភាពក្នុងការចង្អុលបង្ហាញ និងយល់អំពីដំណើរការនៃផែនការយុទ្ធសាស្ត្រដែលបានរៀបចំឡើង ២) រៀបចំកសាងនូវ ទស្សនៈវិស័យ ចក្ខុវិស័យ តម្លៃ បេសកកម្ម និងគោលដៅដែលឆ្លើតបទៅហ្នឹងវត្ថុបំណងក្នុងការអភិវឌ្ឍអង្គភាពរបស់ខ្លួនឱ្យមានភាពរីកចម្រើន ៣) មានសមត្ថភាពក្នុងការយល់ប្រាកដថាផែនការយុទ្ធសាស្ត្រសាលារៀនឆ្លើយតបទៅហ្នឹងតម្រូវការ ភាពផ្សេងៗគ្នារបស់អ្នកសិក្សា និងបទពិសោធន៍ផ្សេងរបស់សហគមន៍ជុំវិញសាលារៀន ៤) ធ្វើខ្លួនឯង និងបុគ្គលិកក្នុងអង្គភាពឱ្យក្លាយជាមនុស្សដែលមានទំនួលខុសត្រូវចំពោះទង្វើ អាកប្បកិរិយា និងរាល់គ្រប់សកម្មភាពដែលបានប្រព្រឹត្ត។

### ២.៨.២ ភាពជាអ្នកដឹកនាំ បែបបង្ហាត់បង្ហាញ

នាយកសាលារៀនត្រូវមានសមត្ថភាពក្នុងការរៀបចំដឹកនាំអនុវត្តនូវកម្មវិធីសិក្សារបស់សាលារៀនឆ្លើយតបនឹងផែនយុត្ធសាស្ត្រ និងគោលនយោបាយនានាដែលក្រសួងបានរៀបចំ។ ពិនិត្យ ពង្រឹង និងកំណត់បរិបទកម្មវិធីសិក្សា និងការរៀនសូត្រ ធនធាន ការអនុវត្តកម្មវិធីសិក្សាផ្ទាល់ រៀបចំវគ្គសិក្សាជាប្រចាំស្តីពីការអនុវត្តកម្មវិធីសិក្សា និងការកែលម្អ

ផ្តួចផ្តើមសកម្មភាពរួមគ្នា និងកម្មវិធីសិក្សាបន្ថែម ដែលគាំទ្រកម្មវិធីសិក្សាដែលកំពុងអនុវត្ត។ ត្រូវប្រាកដថាគ្រូបង្រៀនពិចារណាពីភាពចម្រុះក្នុងការធ្វើផែនការ និងការចែកចាយការណែនាំផ្សេងគ្នា ព្រមទាំងទ្រទ្រង់គំនិតផ្តួចផ្តើមដែលរួមបញ្ចូលការគោរពចំពោះភាពចម្រុះគ្នារបស់អ្នកសិក្សា។ សហការជាមួយគ្រូក្នុងការវិភាគការងាររបស់សិស្ស ដើម្បីដោះស្រាយតម្រូវការសិក្សា ផ្តល់នូវបរិយាកាសសិក្សាប្រកបដោយផាសុកភាព និងជំរុញទឹកចិត្តដែលឆ្លើយតបនឹងអ្នកសិក្សា។

ការអភិវឌ្ឍន៍រួមមាន រាងកាយ សង្គម-អារម្មណ៍ បញ្ញា និងការកំសាន្ត ធានាថាគ្រូបង្រៀនលើកកម្ពស់ការសិក្សាពេញមួយជីវិត និងដឹកនាំខ្លួនឯងប្រកបដោយសេចក្តីថ្លៃថ្នូ។ លើកទឹកចិត្តគ្រូបង្រៀនឱ្យប្រើប្រាស់ការបង្រៀន-រៀនដោយសហការ និងមានប្រសិទ្ធភាព សកម្មភាព និងមានគរុកោសល្យត្រឹមត្រូវ។ បង្ហាញពីចំណេះដឹង និងការយល់ដឹងអំពីនិន្នាការបច្ចុប្បន្ន និងអនាគតនៅក្នុងការត្រួតពិនិត្យ អនុវត្ត និងវាយតម្លៃផែនការត្រួតពិនិត្យការបង្រៀន វាយតម្លៃការអនុវត្តរបស់គ្រូ និងផ្តល់មតិកែលម្អដល់ចំណុចខ្វះខាតដែលកើតមានឡើង អនុវត្តការងារផ្តោតលើលទ្ធផលនៃការណែនាំដោយប្រើប្រាស់បច្ចេកវិទ្យា និងប្រភពទិន្នន័យជាច្រើន ដើម្បីកែលម្អការអនុវត្តការគ្រប់គ្រងរបស់ខ្លួន។ ត្រូវប្រាកដថាស្តង់ដារ និងគោលដៅដែលទាក់ទងនឹងការវាយតម្លៃសិស្សទាក់ទងទៅភាគីពាក់ព័ន្ធ តម្រឹមផែនការបង្រៀនរបស់គ្រូជាមួយនឹងស្តង់ដារ និងគោលដៅរបស់សាលា ធានាបានការរួមបញ្ចូលជាទៀងទាត់នៃការវាយតម្លៃសមស្របនៅក្នុងការណែនាំក្នុងថ្នាក់រៀន និងប្រើលទ្ធផលនៃការវាយតម្លៃរបស់អ្នកសិក្សាសម្រាប់ការធ្វើការសម្រេចចិត្ត។

### ២.៨.៣ ឧត្តមភាពផ្ទាល់ខ្លួន

នាយកសាលាដែលមានឧត្តមភាពត្រូវមានសមត្ថភាពក្នុងការគ្រប់គ្រងខ្លួនឯងប្រកបដោយប្រសិទ្ធភាព។ បង្ហាញជំនឿយ៉ាងមុតមាំថាកុមារទាំងអស់អាចរៀនបានប្រកបដោយសមធម៌ និងបរិយាបន្នឆ្លើយនឹងគោលនយោបាយអប់រំដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ២០១៩-២០២៣។ បង្ហាញ និងយកគំរូតាមក្រមសីលធម៌វិជ្ជាជីវៈ តម្លៃ និងភាពជាអ្នកដឹកនាំប្រកបដោយសីលធម៌។ ធ្វើសកម្មភាពល្អៗ និងមាន

ប្រយោជន៍ប្រកបដោយវិចារណញ្ញាណដើម្បីជាកត្តាជះឥទ្ធិពលដល់បុគ្គលិកក្នុងអង្គភាពធ្វើតាមគំរូផ្ទាល់ខ្លួន។ បង្កើតឱ្យមានអ្នកពាក់ព័ន្ធនៃការទទួលខុសត្រូវផ្ទាល់ខ្លួន និងរបាយការណ៍លទ្ធផល កំណត់ប្រព័ន្ធត្រួតពិនិត្យតាមដាន វាយតម្លៃ និងមធ្យោបាយសម្រាប់ការផ្ដល់ជាមតិកែលម្អ និងទំនាក់ទំនងជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងទទួលខុសត្រូវលើការងាររៀងៗខ្លួន។ ទទួលខុសត្រូវចំពោះកំហុសផ្ទាល់ខ្លួន និងអង្គភាព និងការចែករំលែកចំណុចខ្លាំង ចំណុចខ្សោយដើម្បីចូលរួមកែលម្អ។ ( SEAMEOINNOTECH, ២០១៤ )

# ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅហ្នឹងសំណួរស្រាវជ្រាវដែលបានកំណត់ ការប្រមូលទិន្នន័យបែបគុណភាព ដោយធ្វើការសម្ភាសទៅលើក្រុមសំណាកដែលជាគោលដៅរបស់អ្នកស្រាវជ្រាវត្រូវបានរៀបចំឡើង។ ហេតុដូច្នេះការសិក្សាស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រគុណវិស័យដើម្បីស្វែងយល់អំពីតួនាទីរបស់នាយកសាលាក្នុងការបំពេញការងារ និងការទទួលខុសត្រូវរបស់គាត់ក្នុងការគ្រប់គ្រងលើដំណើរការបង្រៀន និងរៀនរបស់គ្រូ។ ការរៀបចំនូវបាតុភូតវិទ្យា (phenomenological) ត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់ពីសារៈសំខាន់នៃការបំពេញតួនាទី និងទំនួលខុសត្រូវបានល្អរបស់នាយកសាលាដើម្បីរុញច្រានការចូលរួមបំពេញការងាររបស់គ្រូបង្រៀន គណៈកម្មាការគ្រប់គ្រងសាលា ក៏ដូចជាការលើកកម្ពស់គុណភាពអប់រំផងដែរ។

### ៣.១ សំណាក

គម្រោងនៃការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅក្នុងខេត្តត្បូងឃ្មុំ ដោយជ្រើសរើសយកស្រុកអូរាំងឪដែលជាកន្លែងដែលអ្នកស្រាវជ្រាវកំពុងបម្រើការងារ និងដោយសង្កេតឃើញថានាយកសាលាមួយចំនួនពុំទាន់បានបំពេញតួនាទី ទំនួលខុសត្រូវបានគ្រប់ជ្រុងជ្រោយនៅឡើយ ទន្ទឹមនឹងគ្នានេះផងដែរអ្នកស្រាវជ្រាវក៏ចង់បាននូវការចែករំលែកនូវបទពិសោធន៍ល្អៗរបស់លោកនាយកសាលាក្នុងការងារដឹកនាំគ្រប់គ្រងរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់ការងាររបស់អ្នកស្រាវជ្រាវនាពេលអនាគតផងដែរ។

ក្នុងនោះផងដែរដោយផ្អែកទៅតាមពេលវេលា និងសមត្ថភាពអ្នកស្រាវជ្រាវនៅមានកម្រិតព្រមទាំងមានការណែនាំពីសំណាក់គ្រូណែនាំបង្គោល និងគ្រូណែនាំរងអ្នកស្រាវជ្រាវបានប្រើប្រាស់វិធីចាប់ឆ្នោតទៅលើក្រុមសាលាមធ្យមសិក្សាបឋមភូមិទាំងអស់ក្នុងស្រុកអូរាំងឪដែលមានចំនួនប្រាំសាលា។ ជាលទ្ធផលអ្នកស្រាវជ្រាវបានជ្រើសរើសសាលាចំនួនបីមកធ្វើជាភាគសំណាកក្នុងការសិក្សាស្រាវជ្រាវ។

អ្នកចូលរួមសម្ភាសត្រូវបានជ្រើសរើសតាមមធ្យោបាយនៃការជ្រើសរើសដែលមានគោលបំណងច្បាស់លាស់( Purposive Sampling) ដោយជ្រើសរើសយកសាលាអនុវិទ្យាល័យចំនួនបីក្នុងស្រុកអូរាំងឪនៃខេត្តត្បូងឃ្មុំក្នុងនោះគឺអនុវិទ្យាល័យពោធិ៍មាស អនុវិទ្យាល័យមៀន និងអនុវិទ្យាល័យចំការស្បូវ។ ក្នុងមួយសាលាអ្នកស្រាវជ្រាវជ្រើសរើសនាយកចំនួន១នាក់ គ្រូបង្រៀនចំនួន៧នាក់ និងគណៈកម្មការគ្រប់គ្រងសាលាចំនួន២នាក់(ប្រធាន និងអនុប្រធាន) ជាសរុបរួម៣០នាក់។

តារាងទី១ ៖ *ចំនួនសំណាកតាមសាលានីមួយនីមួយៗ*

| ឈ្មោះសាលា | ចំនួននាយក | គណៈកម្មការគ្រប់គ្រងសាលា | គ្រូបង្រៀន | សរុបរង |
|---|---|---|---|---|
| អនុវិទ្យាល័យពោធិ៍មាស | ១ | ២ | ៧ | ១០ |
| អនុវិទ្យាល័យមៀន | ១ | ២ | ៧ | ១០ |
| អនុវិទ្យាល័យចំការស្បូវ | ១ | ២ | ៧ | ១០ |
| សរុប | ៣ | ៦ | ២១ | ៣០ |

ដើម្បីកំណត់ពីសំណាកនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវជាបឋមទៅដល់សាលារៀនគោលដៅដើម្បីស្នើសុំទិន្នន័យគ្រូបង្រៀន។ នៅពេលដែលសាលារៀនបានផ្តល់ទិន្នន័យរួចហើយអ្នកស្រាវជ្រាវបានចូលទៅកាន់សាលារៀនដើម្បីកំណត់ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន ចំនួនគ្រូបង្រៀនដើម្បីងាយស្រួលក្នុងណាត់ពួកគាត់ធ្វើការសម្ភាស។ ដោយការសិក្សានេះព្យាយាមចង់ដឹងពីការយល់ឃើញទៅលើតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលារៀន ហេតុដូចនេះហើយការជ្រើសរើសអ្នកចូលរួមសម្ភាសន៍មានលក្ខណៈសម្រាំង និងមានចេតនាជាក់លាក់ដើម្បីធានាថាទិន្នន័យដែលទទួលបានអាចយកមកឆ្លុះបញ្ចាំងលើការ

អនុវត្តការងារប្រចាំថ្ងៃ។ លើសពីនេះទៅទៀតចំពោះសំណាកជាគ្រូបង្រៀន គឺត្រូវបានណែនាំដោយនាយកសាលា និងបន្តបន្ទាប់ត្រូវបានណែនាំដោយលោកគ្រូអ្នកគ្រូដែលបានចូលរួមសម្ភាសន៍។

## ៣.២ ការប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ

ចំពោះដំណើរការស្រាវជ្រាវ អ្នកស្រាវជ្រាវបានពិនិត្យបន្ថែមទៅលើប្រធានបទដើម្បីឱ្យបានយល់កាន់តែស៊ីជម្រៅដើម្បីងាយស្រួលក្នុងការគិតគូរអំពីការបង្កើតសំណួរគន្លឹះ ថាតើគួរបង្កើតសំណួរគន្លឹះ ក៏ដូចជាសំណួរសម្ភាសន៍បែបណាដើម្បីឱ្យអ្នកត្រូវសម្ភាសផ្តល់ចម្លើយមកដល់ចំណុចដៅដែលអ្នកស្រាវជ្រាវចង់បាន ហើយឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ និងគោលបំណងស្រាវជ្រាវ។ បញ្ជីសំណួរសម្រាប់សម្ភាសត្រូវបានរៀបចំឡើងដោយផ្អែកទៅលើសេចក្តីព្រាងស្តង់ដាវិជ្ជាជីវៈនាយកសាលារៀនចំណេះទូទៅដកស្រង់ចេញពីសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួងអប់រំយុវជន និងកីឡាឆ្នាំ២០១៨ដែលមាន៥សមាសភាគ ១៦សមត្ថភាព ៤២សមត្ថភាពរង និង១៣៦ស្តង់ដាសមត្ថភាព។ ប៉ុន្តែអាស្រ័យទៅលើពេលវេលា និងស្ថានភាពជាក់ស្តែងអ្នកស្រាវជ្រាវបានយកតែសមាសភាគទី២(ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន) ប៉ុណ្ណោះមកបង្កើតជាសំណួរសម្ភាសន៍ក្នុងនោះរួមមាន៖(១) ការដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា (២) ការបង្កើតបរិស្ថានអ្នកសិក្សាមជ្ឈមណ្ឌល (៣)ការងារអធិការកិច្ច និងវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន (៤)ការផ្តល់លទ្ធផលសិក្សាតាមផែនការ។ ហេតុផលនៅពីក្រោយការដាក់បញ្ចូលសេចក្តីព្រាងនេះនៅក្នុងបញ្ជីសំណួរគឺថាសេចក្តីព្រាងនេះអាចឱ្យអ្នកស្រាវជ្រាវពិនិត្យមើលតួនាទី និងទំនួលខុសត្រូវសំខាន់ៗរបស់នាយកសាលាក្នុងការគ្រប់គ្រងដំណើរការបង្រៀន និងរៀន។ សេចក្តីព្រាងនេះក៏បានកំណត់យ៉ាងច្បាស់ពីតួនាទីភារកិច្ចរបស់នាយកសាលាធ្វើយ៉ាងណាលើកកម្ពស់គុណភាពសិក្សាឱ្យបានល្អប្រសើរ។

## ៣.៣ ការវិភាគទិន្នន័យ

គម្រោងនៃការស្រាវជ្រាវនេះអនុវត្តវិធីសាស្ត្របែបគុណភាពដើម្បីស្វែងយល់ពីការបំពេញការងារ និងទំនួលខុសត្រូវរបស់នាយកលើការគ្រប់គ្រងការបង្រៀន និងរៀន ថាតើនាយកសាលាបានដឹងពីទំនួលខុសត្រូវ

របស់ខ្លួនក្នុងការបំពេញការងារប្រចាំថ្ងៃដែរឬទេ ហើយអ្នកពាក់ព័ន្ធ(គ្រូ និង គណៈកម្មការគ្រប់គ្រងសាលា) បានដឹងពីទំនួលខុសត្រូវរបស់នាយក និងសារៈសំខាន់របស់វាដើម្បីលើកកម្ពស់គុណភាពអប់រំដែរឬទេ?

ពេលបង្កើតសំណួរគន្លឹះរួចរាល់ហើយអ្នកស្រាវជ្រាវបានទូរស័ព្ទណាត់លោកនាយក ដោយឱ្យលោកនាយកអញ្ជើញគណៈកម្មការគ្រប់គ្រងសាលារៀន លោកគ្រូទទួលបន្ទុកថ្នាក់ដែលពាក់ព័ន្ធដើម្បីឱ្យអ្នកស្រាវជ្រាវសុំសម្ភាសន៍ពាក់ព័ន្ធនិងប្រធានបទខាងលើ។ ទិន្នន័យដែលបានមកពីការសមភាសន៍អ្នកពាក់ព័ន្ធ (ទាំងការថតសម្លេង និងការកត់ត្រា)និងត្រូវយកមករៀបចំជាក្រុមគំនិត(Coding) ដើម្បីធ្វើការវិភាគទៅលើខ្លឹមសារ(Content Analysis)។

ក្នុងពេលចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវបានអនុវត្តតាមគោលការណ៍របស់ក្រមសីលធម៌ស្រាវជ្រាវ។ អ្នកស្រាវជ្រាវពុំបានបង្ខិតបង្ខំអ្នកផ្តល់សម្ភាស ដោយបានប្រើប្រាស់គោលការស្ម័គ្រចិត្តក្នុងការផ្តល់សម្ភាស ហើយអ្នកស្រាវជ្រាវក៏ពុំបានបង្ហាញឈ្មោះ អត្តសញ្ញាណ ឬទិន្នន័យទាំងឡាយណាដែលសម្ភាសបានពីអ្នកផ្តល់សម្ភាសជាសាធារណៈនោះឡើយ។ មួយវិញទៀត អ្នកស្រាវជ្រាវពុំបានកុហក ឬក៏ប្រើល្បិចបោកបញ្ឆោទណាមួយ ដើម្បីបានមតិយោបល់ពីអ្នកផ្តល់សម្ភាសទេ។ ក្នុងនោះផងដែរប្រសិនបើអ្នកផ្តល់សម្ភាសន៍លែងចង់ឱ្យធ្វើការសម្ភាសអ្នកស្រាវជ្រាវក៏យល់ស្របតាម។

# ជំពូកទី៤

## លទ្ធផល និងការពិភាក្សា

ក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញនូវលទ្ធផលនៃការសិក្សាស្រាវជ្រាវក្រោយពីបានធ្វើការសម្ភាសជាមួយភាគីពាក់ព័ន្ធផ្សេងៗដែលរួមមាន លោកនាយកសាលា លោកគ្រូអ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលារៀនផងដែរ។ ប៉ុន្តែដោយសារមានការលំបាកក្នុងការទំនាក់ទំនងអ្នកស្រាវជ្រាវពុំបានប្រមូលទិន្នន័យពីគណៈកម្មការគ្រប់គ្រងសាលារៀនទេ។

ឆ្លើយតបទៅហ្នឹងសំណួរស្រាវជ្រាវទី១៖តើនាយកសាលាត្រូវបំពេញតួនាទី និងទំនួលខុសត្រូវក្នុងការគ្រប់គ្រងលើការបង្រៀននិងរៀនដូចម្តេចខ្លះ?និងសំណួរស្រាវជ្រាវទី២៖តើការបំពេញតួនាទី និងការទទួលខុសត្រូវរបស់នាយកសាលាមានសារៈសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន និងរៀនដូចម្តេចខ្លះ? នៅក្នុងសំណួរស្រាវជ្រាវទាំង២នេះអ្នកស្រាវជ្រាវបានបានកំណត់នូវសូចនាករសំខាន់ៗមួយចំនួនដើម្បីមកបង្កើតជាសំណួរសម្ភាសសម្រាប់នាយកសាលា និងលោកគ្រូអ្នកគ្រូតាមសាលាគោលដៅដែលបានកំណត់។ ឆ្លងតាមរយៈការធ្វើការសម្ភាសអ្នកស្រាវជ្រាវបានរកឃើញថាមានមតិយោបល់ជាច្រើនដែលឆ្លុះបញ្ចាំងពីទំនួលខុសត្រូវ និងតួនាទីរបស់នាយកសាលាទេពកោសល្យ និងភាពប៉ិនប្រសព្វលើការដឹកនាំគ្រប់គ្រងដំណើរការបង្រៀននិងរៀនដែលនាយកសាលាបានអនុវត្តកន្លងមកពិសេសនៅក្នុងបរិបទដែលកម្ពុជាជួមប្រទះនូវបញ្ហាសុខភាពសាធារណៈគឺជំងឺកូវីត១៩ ដែលតម្រូវឱ្យសាលារៀនត្រូវបានបិទទ្វារអស់រយៈពេលជាច្រើនខែ។ ខាងក្រោមគឺជាមតិយោបល់ដែលបញ្ជាក់យ៉ាងលម្អិតពីនាយកសាលា លោកគ្រូអ្នកគ្រូបានឆ្លើយតបទាំងដោយផ្ទាល់ និងតាមរយៈប្រព័ន្ធអេឡិចត្រូនិចលើការគ្រប់គ្រងដំណើរការបង្រៀននិងរៀននៅស្រុកអូរាំងឪខេត្តត្បូងឃ្មុំ៖

### ៤.១ ការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា

កម្មវិធីសិក្សាគឺជាកត្តាសំខាន់មួយក្នុងការកំណត់បាននូវគុណភាពសិក្សារបស់សិស្ស។ កាលណាគ្រូបង្រៀនអនុវត្តទៅតាមកម្មវិធីសិក្សាបានត្រឹមត្រូវស្របតាមការណែនាំរបស់ក្រសួង នោះគុណភាពនៃការបង្រៀន និងរៀននិងមានប្រសិទ្ធភាពខ្ពស់។ក្នុងន័យនេះនាយកសាលាបានណែនាំឱ្យគ្រូបង្រៀនអនុវត្តនូវកម្មវិធីសិក្សាបំពេញរបស់ក្រសួងអប់រំដែលបានដាក់ចេញនៅក្នុងបរិបទកូវីត១៩។ ដូចតាមការសម្ភាសនាយកសលាម្នាក់បានលើកឡើង

*"...ចំពោះកម្មវិធីសិក្សាយើងបានណែនាំដល់លោកគ្រូអ្នកគ្រូទាំងអស់ដកស្រង់ និងសង្ខេបនូវខ្លឹមសារមេរៀនដែលសំខាន់ៗទៅបង្រៀនដល់សិស្សានុសិស្ស និងត្រូវបំពេញនូវកម្មវិធីសិក្សាខ្លះដើម្បីឆ្លើយតបនិងស្ថានភាពនៃជម្ងឺកូវីត១៩..."*។ នាយកសាលាម្នាក់បានលើកឡើងពីស្ថានភាពបច្ចុប្បន្ននៃសាលារៀនរបស់គាត់ទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សាថា *"...កម្មវិធីសិក្សាគឺជារឿងចាំបាច់ដែលយើងត្រូវយកចិត្តទុកដាក់នៅរៀងរាល់ដើមឆ្នាំសិក្សា ខ្ញុំតែងជម្រុញឱ្យគ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់រៀបចំធ្វើកម្មវិធីសិក្សាឱ្យបានត្រឹមត្រូវទាំងប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំដើម្បីឱ្យមានភាពងាយស្រួលក្នុងការបង្រៀន និងត្រូវអនុវត្តនូវកម្មវិធីសិក្សានោះឱ្យបានត្រឹមត្រូវក្នុងការបង្រៀនផងដែរ..."*។

គ្រូបង្រៀនម្នាក់ក៏បានលើកឡើងទាក់ទងនិងការអនុវត្តកម្មវិធីសិក្សានេះផងដែរដោយគាត់បានបញ្ជាក់ថានាយកសាលារបស់គាត់តែងតែតម្រូវឱ្យគ្រូបង្រៀនទាំងអស់ប្រគល់កម្មវិធីសិក្សាប្រចាំឆ្នាំមកឱ្យគណៈនាយកពិនិត្យនិងចុះហត្ថលេខាដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវងាយស្រួលដល់គ្រូបង្រៀនទាំងអស់អនុវត្ត។ គាត់បានបន្ថែមថា

*"...លោកនាយកតែងឱ្យគ្រូទាំងអស់រៀបចំធ្វើបំណែងចែកកម្មវិធីសិក្សាតាមរយៈគ្រប់រូបភាពទៅតាមសៀវភៅសិក្សាគោល និងកម្មវិធីសិក្សារបស់ក្រសួងដោយធ្វើយ៉ាងណាឱ្យបានចប់ខ្លឹមសារមេរៀននៅមុនដំណាច់ឆមាសទី២នៃឆ្នាំសិក្សា..."*។

សរុបជារួមមកនាយកសាលាភាគច្រើនបានយកចិត្តទុកដាក់ខ្លាំងទៅលើការរៀបចំនិងអនុវត្តនូវបំណែងចែកកម្មវិធីសិក្សារបស់លោកគ្រូអ្នកគ្រូ ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យដំណើរការបង្រៀននិងរៀនប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ឆ្លើយនិងផែនការយុទ្ធសាលារៀន ក៏ដូចជាផែនការយុទ្ធរបស់ក្រសួងអប់រំផងដែរ។

## ៤.២ ការខារអធិការកិច្ចអចិន្ត្រៃយ៍របស់នាយកសាលា

ការពិនិត្យតាមដាន និងវាយតម្លៃទៅលើដំណើរការបង្រៀន និងរៀនពិតជាមានសារៈសំខាន់ណាស់ដើម្បីស្វែងរកចំណុចល្អៗ ឬចំណុចខ្វះផ្សេងៗដើម្បីធ្វើការកែលម្អ។ ក្នុងន័យនេះនាយកសាលាមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកក្នុងការងារនេះ។ នាយកសាលាត្រូវបានគេចាត់ទុកជាអធិការអចិន្ត្រៃយ៍ដែលគាត់មានទំនួលខុសត្រូវក្នុងការពិនិត្យតាមដានលើដំណើរការបង្រៀន និងរៀនជាប្រចាំ។ ការរៀបចំផែនការអធិការកិច្ចច្បាស់លាស់ ត្រឹមត្រូវ និងអនុវត្តបានទៀងទាត់ពេលវាលានឹងជម្រុញឱ្យដំណើរការបង្រៀនមានប្រសិទ្ធភាព។ នាយកសាលាម្នាក់បានលើកឡើងថា

*"...វាគឺជាការចាំបាច់ណាស់ដែលត្រូវចុះត្រួតពិនិត្យមើលដំណើរការបង្រៀនរបស់គ្រូជាប្រចាំ មានគ្រូបង្រៀនខ្លះចេញបម្រើការងារយូរហើយដូចនេះការប្រើប្រាស់វិធីសាស្ត្របង្រៀន មិនសូវមានភាពទាន់សម័យ លើសពីនេះទៀតយើងក៏បានជួយគ្រូបង្រៀនមួយចំនួនដែលពួកគាត់មានបញ្ហានៅក្នុងការអនុវត្តការបង្រៀននៅក្នុងថ្នាក់"*។

ទោះបីជាយ៉ាងណាក៏ដោយមានចំណុចធកល្វែងមួយចំនួនដែលកើតមានឡើងដោយការអនុវត្តមិនបានពេញលេញលើការងារពិនិត្យតាមដាននិងវាយតម្លៃលើដំណើរការបង្រៀន និងរៀន។ គ្រូបង្រៀនបីនាក់បានលើកឡើងស្រដៀងគ្នាថា

*"...នាយកសាលាមិនបានចុះមើលដំណើរការបង្រៀន និងរៀនឡើយដោយសារគាត់មានការរវល់លើកិច្ចការផ្សេងៗ ខ្វះខាតបុគ្គលិកនៅទីចាត់ការ(មិនមាននាយករង)ដូចនេះរាល់ការងារទាំងអស់នាយកសាលាជាអ្នករ៉ាប់រងជាហេតុធ្វើឱ្យគាត់មិនបានអនុវត្តនូវសកម្មភាពនេះ"។*

សរុបជារួម នាយកសាលាគឺជាអធិការអេចិន្ត្រៃយ៍ដែលគាត់មានទំនួលខុសត្រូវយ៉ាងសំខាន់លើដំណើរការបង្រៀន និងរៀន គាត់គឺមិនត្រឹមតែជាអ្នកគ្រប់គ្រងប៉ុណ្ណោះទេតែគាត់ក៏ជាទីប្រឹក្សាដ៏សំខាន់សម្រាប់គ្រូបង្រៀនផងដែរទាំងផ្នែកគរុកោសល្យ ការគ្រប់គ្រងថ្នាក់រៀន...ជាដើម។ លើសពីនោះទៀតគណៈគ្រប់គ្រងត្រូវរៀបចំផែនការឱ្យបានច្បាស់លាស់ក្នុងចុះពិនិត្យមើលដំណើរការបង្រៀនរបស់គ្រូក្នុងគោលបំណងស្វែងរកជាតុចូលល្អៗបម្រើឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

## ៤.៣ ការគ្រប់គ្រងលើការអនុវត្តវិធីសាស្ត្របង្រៀន

ឆ្លើយតមនឹងសំណួរថាតើវិធីសាស្ត្របង្រៀនបានជះឥទ្ធិពលទៅលើដំណើរការបង្រៀន និងរៀនដែរឬទេ? គ្រូបង្រៀនមួយចំនួនបានផ្តល់ចម្លើយស្រដៀងគ្នាថាវាពិតជាមានសារៈសំខាន់ណាស់ដែលគ្រូបង្រៀនម្នាក់ បានជ្រើសរើសនិងប្រើប្រាស់វិធីសាស្ត្របង្រៀបថ្មីៗស្របតាមខ្លឹមសាមេរៀន និងនាំឱ្យការបង្រៀនទទួលបានជោគជ័យ សម្រេចតាមវត្ថុបំណងដែលបានរៀបចំទុកក្នុងកិច្ចតែងការបង្រៀនផងដែរ។ គ្រូបង្រៀនម្នាក់ដែលទើបមានបទពិសោធបង្រៀន២ឆ្នាំម្នាក់បានលើកឡើងថា

*"...ការបង្រៀនរបស់ខ្ញុំទទួលបានជោគជ័យសម្រេចតាមវត្ថុបំណង និងលទ្ធផលរំពឹងទុកដោយសារតែខ្ញុំបានរៀបចំកិច្ចតែងការបានត្រឹមត្រូវ និងបានប្រើវិធីសាស្ត្របង្រៀនសមស្របតាមខ្លឹមសារមេរៀន រួមទាំងតម្រូវតាមភាពផ្សេងៗគ្នារបស់សិស្សទៀតផង"។*

ទោះបីជាយ៉ាងនេះក្តីប៉ុន្តែលោកគ្រូអ្នកគ្រូមួយចំនួនក៏បានរៀបរាប់ពីបញ្ហាប្រឈមមួយចំនួនដែលកើតមានឡើងនឹងបនធ្វើឱ្យរាំងស្ទះដល់ការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗផងដែរពោលគឺខ្វះការគាំទ្រពេញលេញពីគណៈគ្រប់គ្រងសាលា(នាយក)។ គ្រូបង្រៀនរូបវិទ្យាម្នាក់បានលើកឡើងថា

"...*ការបង្រៀនមេរៀនវិទ្យាសាស្ត្រគឺទាមទារឱ្យសិស្សប្រើវិធីសាស្ត្រអនុវត្តពិសោធន៍ជាក់ស្តែង ប៉ុន្តែសម្ភារៈមួយចំនួនត្រូវការចំណាយថវិកាច្រើនព្យាយាមស្នើសុំទៅសាលាមិនបានគ្រប់គ្រាន់ដូច្នេះសកម្មភាពមួយចំនួនមិនបានអនុវត្តគ្រប់ជ្រុងជ្រោយ*"។ គ្រូបង្រៀនម្នាក់ទៀតដែលចេញបង្រៀនជាងដប់ឆ្នាំមកហើយបានលើកឡើងថា "...*ការបង្រៀនមួយម៉ោងសិក្សាដើម្បីឱ្យទទួលបានជោគជ័យគ្រូបង្រៀនត្រូវមានកិច្ចតែងការបង្រៀន និងត្រូវប្រើវិធីសាស្ត្របង្រៀនឱ្យបានសមស្រប ប៉ុន្តែសម្រាប់ខ្ញុំវិធីសាស្ត្របង្រៀនមិនសូវបានដឹងច្បាស់ទូលំទូលាយទេដោយសារចេញបង្រៀនយូរឆ្នាំ មិនដែលបានចូលរួមសិក្សាសាលាថ្មីៗទាក់ទងនធងវិធីសាស្ត្របង្រៀន ណាមួយក្នុងមួយថ្នាក់រៀនមានចំនួនសិស្សច្រើនពិបាកក្នុងការបែងចែកក្រុមពិភាក្សា*"។

សរុបជារួម ការអនុវត្តវិធីសាស្ត្របង្រៀនត្រឹមត្រូវ ឆ្លើយតបនឹងខ្លឹមសារមេរៀនអាចធ្វើឱ្យសម្រេចបាននូវលទ្ធផលសិក្សារំពឹងទុកដែលគ្រូបានរៀបចំនៅក្នុងកិច្ចតែងការបង្រៀន។ គណៈគ្រប់គ្រងសាលាមានទំនួលខុសត្រូវខ្ពស់ក្នុងការជម្រុញដល់គ្រូបង្រៀនតាមគ្រប់រូភាពដើម្បីឱ្យពួកគាត់បង្រៀនបានត្រឹមត្រូវដែលនាំទៅដល់លទ្ធផលសិក្សាមានគុណភាព រួមចំណែកកាត់បន្ថយនូវអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សារបស់សិស្ស។

### ៤.៤ ការគ្រប់គ្រងលើការអនុវត្តការងាររដ្ឋបាលរបស់គ្រូបង្រៀន

ជាទូទៅគ្រូបង្រៀនគឺជាតួអង្គដ៏សំខាន់មួយក្នុងដំណើការអប់រំ គោលនយោបាយអប់រំជាច្រើនដែលក្រសួងបានដាក់ចេញគឺសំដៅធ្វើយ៉ាងណាលើកទឹកចិត្តដល់គ្រូបង្រៀនគ្រប់រូបឱ្យមានឆន្ទៈខ្ពស់ក្នុងការ

បង្រៀនសិស្ស។ ក្នុងន័យនេះពួកគាត់មានទំនួលខុសត្រូវជាច្រើនដែលត្រូវអនុវត្តដើម្បីបម្រើដល់ការផ្ទេរចំណេះដឹង និងបទពិសោធន៍របស់ពួកគាត់ដល់សិស្សានុសិស្សឱ្យមានប្រសិទ្ធភាពខ្ពស់។

នាយកសាលាម្នាក់បានលើកឡើងថាការងាររដ្ឋបាលគ្រូគឺជារឿងសំខាន់ និងចាំបាច់ដែលគ្រូបង្រៀនម្នាក់ត្រូវរៀបចំក្នុងនោះដែរគាត់ក៏បានប្រជុំរៀបចំនៅរៀងរាល់ដើមឆ្នាំសិក្សាថ្មីដូចជា ការផ្តល់សម្ភារផ្សេងៗដើម្បីឱ្យគ្រូរៀបចំសៀវភៅកិច្ចតែងការ សៀវភៅអត្តបទសម្រាប់គ្រូផ្ទាល់ និងគ្រូតាមមុខវិជ្ជា សៀវភៅវត្តមាន ...។ មិនត្រឹមតែការផ្តល់នូវសម្ភារ និងការណែនាំផ្សេងៗទេ នាយកសាលាត្រូវមានយន្តការច្បាស់លាស់ក្នុងការពិនិត្យតាមដាន និងវាយតម្លៃផងដែរ។ នាយកសាលាបានព្យាយាមអនុវត្តគ្រប់មធ្យោបាយ និងគ្រប់រូបភាពដើម្បីឱ្យគ្រូបង្រៀនគ្រប់រូបអនុវត្តបានត្រឹមត្រូវ និងម៉ត់ចត់ជាពិសេសគឺការធ្វើកិច្ចតែងការបង្រៀន។ លោកនាយកម្នាក់បានលើកឡើងថាគ្រូបង្រៀនមួយចំនួនបានប្រើប្រាស់កិច្ចតែងការចាស់ ថតចម្លងតៗគ្នាដោយមិនបានធ្វើការកែតម្រូវ និងធ្វើបច្ចុប្បន្នភាពជាហេតុធ្វើឱ្យខ្លឹមសារមេរៀនមួយចំនួនមិនបានគ្រប់ជ្រុងជ្រោយ។ គាត់បានបន្ថែមថាគាត់បានព្រយ៉ាមណែនាំដល់លោកគ្រូអ្នកគ្រូទាំងនោះធ្វើកិច្ចតែងការជាថ្មីឡើងវិញ បញ្ចូលនូវវិធីសាស្ត្រថ្មីៗ តិចនិចថ្មីៗក្នុងការបង្រៀនឆ្លើយតបនឹងការរីចម្រើនផ្នែកបច្ចេកវិទ្យា។ គ្រូបង្រៀនម្នាក់បានលើកឡើងថា

*"លោកនាយកបានណែនាំយើងឱ្យធ្វើកិច្ចតែការបង្រៀនជាប្រចាំ ហើយវាពិតជាបានជួយសម្រួលច្រើនដល់ការបង្រៀននិងរៀនមានភាពងាយស្រួល ច្បាស់លាស់ មានលំដាប់លំដោយ មិនត្រឹមតែប៉ុណ្ណោះយើងអាចសម្រេចបានតាមវត្ថុបំណងនៃមេរៀននៅពេលដែលយើងបានអនុវត្តត្រឹមត្រូវទៅតាមជំហាននៅក្នុងកិច្ចតែងការបង្រៀន"។*

សរុបជារួមមកការគ្រប់គ្រងទៅលើការងាររដ្ឋបាលរបស់គ្រូបង្រៀនពិតជារឿងសំខាន់ និងចាំបាចនាយកសាលាត្រូមានភាពប៉ិនប្រសព្វ និងបត់បែនខ្ពស់ដោយសារបច្ចុប្បន្នបច្ចេកវិទ្យាមានការរីកចម្រើនលោក

គ្រូអ្នកគ្រូអាចប្រើប្រាស់កំព្យូទ័រក្នុងការរៀបចំការងាររដ្ឋបាលមួយចំនួនដោយគ្រាន់តែធ្វើបច្ចុប្បន្នភាពជាប្រចាំ។

### ៤.៥ ការដឹកនាំនិងគ្រប់គ្រងលើការងារប្រជុំបច្ចេកទេស

ការប្រជុំបច្ចេកទេសគឺជារឿងដ៏សំខាន់ដើម្បីគាំទ្រដល់ការបង្រៀននិងរៀនមានប្រសិទ្ធភាព។ តាមរយៈចម្លើយដែលទទួលបានពីការសម្ភាសលើនាយកសាលា៣រូបបានបង្ហាញថា មិនបានអនុវត្តការងារប្រជុំបច្ចេកទេសបាន១០០%នោះទេ ដោយលើកហេតុផលថាមានមមាញឹកក្នុងការដឹកនាំការងារផ្សេងៗនៅក្នុងអង្គភាពខ្វះខាតបុគ្គលិកទីចាត់ការ។ គ្រូបង្រៀនម្នាក់បានលើកឡើងថា

*"...ការប្រជុំបច្ចេកទេសគឺជារឿងចាំបាច់ដែលគ្រូបង្រៀនត្រូវអនុវត្តដើម្បីដោះស្រាយបញ្ហាបច្ចេកទេសផ្សេងៗ ដែលកើតមានឡើងទាក់ទងនិងខ្លឹមសារមេរៀន បច្ចេកទេសបង្រៀន ការប្រើប្រាស់វិធីសាស្ត្រ និងឧបសគ្គផ្សេងៗ ដែលបានជួបប្រទះដើម្បីមកធ្វើការដោះស្រាយតាមរយៈការជជែកពិភាក្សា ប៉ុន្តែគណៈគ្រប់គ្រងពុំសូវបានយកចិត្តទុកដាក់លើការងារនេះ ដោយចាត់តាំងឱ្យប្រធានក្រុមបច្ចេកទេសជាអ្នកទទួលខុសត្រូវដោយមិនបានធ្វើការពិនិត្យតាមដាននិងវាយតម្លៃ"។*

គ្រូបង្រៀនម្នាក់ទៀតមានការលើកឡើងបន្ថែមថា ការងារនេះគឺពិតជាមានសារសំខាន់ហើយបានជួយគាត់ក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានជួបប្រទះជាពិសេសទៅលើបញ្ហាបច្ចេកទេសបង្រៀន កំហុសឆ្គងក្នុងសៀវភៅសិក្សាគោលជាដើម។ គ្រូបង្រៀនម្នាក់ទៀតក៏បានលើកឡើងស្រដៀងគ្នានេះដែរ

*"...ក្រោយពីបានធ្វើការប្រជុំយើងបានយល់ដឹងបន្ថែមពីការងារពិសោធន៍មួយចំនួន តាមរយៈការណែនាំរបស់ប្រធានក្រុមបច្ចេកទេសក៏ដូចជាលោកគ្រូអ្នកគ្រូមួយចំនួនដែលមានបទពិសោធន៍ល្អៗ លើសពីនេះទៅទៀតយើងក៏បានបង្កើតនូវទំនាក់ទំនងល្អរវាងបុគ្គលិកទាំងអស់នៅក្នុងអង្គភាពផងដែរ។ ប៉ុន្តែពិតជាមានឧបសគ្គច្រើនក្នុងការអនុវត្តនូវការងារនេះដោយសារពួកយើងមិនបានអនុវត្ត១០០% ម្យ៉ាងដោយខ្វះ*

*ការខុបត្ថម្ភគាំទ្រពីគណៈគ្រប់គ្រង និងម្យ៉ាងគ្រូមួយចំនួនយកហេតុផលថាផ្ទះនៅឆ្ងាយ ព្រមទាំងពុំសូវឱ្យតម្លៃលើការងារប្រជុំបច្ចេកទេសដោយពួកគាត់មួយចំនួនគិតថាវាជារឿងចាស់ដដែលៗជាដើម។*

ជាសរុបមកដើម្បីលើកកម្ពស់ប្រសិទ្ធនៃដំណើរការបង្រៀន និងរៀនឱ្យមានប្រសិទ្ធមានគណៈគ្រប់គ្រងត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការដឹកនាំបុគ្គលិកប្រជុំជាប្រចាំជាពិសេសលើការងារបច្ចេកទេសផ្សេងៗ ទាក់ទងនិងវិធីសាស្ត្របង្រៀនថ្មីៗ ព្រមទាំងអាចបញ្ជ្រាបនូវការងារពិសោធន៍មួយចំនួនដែលទាក់ទងនឹងមុខវិជ្ជាSTEM ដែលក្រសួងអប់រំកំពុងតែយកចិត្តទុកដាក់ខ្ពស់ផងដែរ។

## ៤.៦ ការគ្រប់គ្រងលើលទ្ធផលនៃការសិក្សារបស់សិស្ស

ជាទូទៅ សិស្សតែងតែចង់បាននូវលទ្ធផលសិក្សាដែលល្អត្រឹមត្រូវនិងភាពយុត្តិធម៌សម្រាប់ពួកគេ។

ការប្រកាសលទ្ធផលទាន់ពេលវេលា ច្បាស់លាស់ និងមានតម្លាភាពគឺជារឿងដ៏សំខាន់មួយដែលនាយកសាសាលោកគ្រូអ្នកគ្រូម្នាក់ៗត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត។ លើសពីនេះទៅទៀតលទ្ធផលនៃការសិក្សាប្រចាំខែប្រចាំឆមាសនិងប្រចាំឆ្នាំគឺជាយន្តការមួយក្នុងចំណោមយន្តការចាំបាច់ជាច្រើនទៀត ជួយជំរុញការប្រឹងប្រែងរបស់សិស្ស មួយវិញទៀតវាជាយន្តការក្នុងការទំនាក់ទំនងជាមួយមាតាបិតាឬ អាណាព្យាបាលសិស្សឱ្យគាត់ចូលរួមក្នុងការតាមដានសិក្សារៀនសូត្ររបស់កូនៗគាត់។

តាមរយៈការសាកសួរលើនាយកសាលាពីរនាក់បានលើកឡើងស្រដៀងគ្នាទាក់ទងនិងយុទ្ធសាស្ត្រនិងវិធីមួយចំនួនដែលគាត់បានអនុវត្តលើការងារនេះកន្លងមក។ ពួកគាត់បានលើកឡើងថា គាត់បានប្រជុំណែនាំនិងដាក់ផែនការឱ្យគ្រូទទួលបន្ទុកថ្នាក់ទាំងអស់ធ្វើការបូកស្រង់ពិន្ទុដែលសិស្សានុសិស្សរបស់ខ្លួនបានប្រឡងឱ្យបានចប់សព្វគ្រប់ នៅរៀងរាល់ថ្ងៃទៅម្ភៃនៃខែនីមួយៗព្រមទាំងចុះចូលសៀវភៅតាមដានការសិក្សាសិស្សឱ្យបានទៀងទាត់និងចែកឱ្យពួកគេជារៀងរាល់ខែនៅថ្ងៃទី ២៥នៃខែនីមួយៗ។ ធ្វើយ៉ាងនេះដើម្បីឱ្យសិស្សបាន

ដឹងពីលទ្ធផលដែលពួកគេបានខិតខំប្រឹងប្រែងកន្លងមក និងដើម្បីរកវិធីកែលម្អនូវចំណុចខ្វះខាតរបស់ពួកគេរៀងៗខ្លួន។ គណៈគ្រប់គ្រងម្នាក់ទៀតបានលើកឡើងថា ៖

*"...លទ្ធផលសិក្សារបស់សិស្សមួយរយៈពេលចុងក្រោយនេះមានការធ្លាក់ចុះដោយសារពួកគេមិនបានមករៀននៅសាលាជាប់លាប់ដោយបញ្ហាកូវីត១៩ ប៉ុន្តែយើងបានព្យាយាមគ្រប់រូបភាពដើម្បីឱ្យសិស្សបានសិក្សារៀនសូត្រព្រមទាំងឱ្យពួកគេដឹងពីលទ្ធផលសិក្សារបស់ពួកគេជាប្រចាំផងដែរ"។*

គ្រូបង្រៀនម្នាក់ទៀតលើកឡើងថា *"...សិស្សមានការប្រកួតប្រជែងគ្នា និងសប្បាយរីករាយនៅពេលដែលពួកគេទទួលបានសៀវភៅតាមដានការសិក្សាម្តងៗ លើសពីនេះទៀត អាណាព្យាបាលក៏បានដឹងពីការខិតខំប្រឹងប្រែងកូនរបស់ខ្លួនក៏ដូចជា ពេលវេលា ភាពទៀតទាត់កម្រិតណា ក្នុងការមកសាលារបស់ពួកគេ លើសពីនេះទៅទៀត លោកនាយកតែងតែធ្វើការប្រជុំណែនាំជារៀងរាល់ខែដល់លោកគ្រូអ្នកគ្រូក្នុងការដាក់ពិន្ទុគឺត្រូវមានភាពយុត្តិធម៌ ត្រឹមត្រូវ និងត្រូវយកគុណភាពជាជាងគិតពីបរិមាណ"។*

គ្រូបង្រៀនម្នាក់ទៀតបានបន្ថែមថា *"...មិនត្រឹមតែប្រកាសលទ្ធផលទាន់ពេលវេលាទេគណៈគ្រប់គ្រងសាលាបានលើកទឹកចិត្តឱ្យគ្រូបន្ទុកថ្នាក់ទាំងអស់រៀបចំជាតារាងកិត្តិយស និងផ្តល់ជារង្វាន់លើកទឹកចិត្តដល់សិស្សទទួលបានចំណាត់ថ្នាក់ល្អទៀតផង ទាំងនេះគឺជាការជម្រុញឱ្យសិស្សខិតខំប្រឹងប្រែងរៀនសូត្រកាន់តែខ្លាំងឡើងមួយកម្រិតថែមទៀត"។*

សរុបសេចក្តីមក ការយកចិត្តទុកដាក់លើលទ្ធផលនៃការសិក្សារបស់សិស្សគឺជាកត្តាមួយជួយលើកកម្ពស់គុណភាពនៃការបង្រៀននិងរៀនផងដែរ ហើយវាក៏ជាទំនួលខុសត្រូវរបស់គណៈនាយកដែលមិនអាចខ្វះបានក្នុងការគាំទ្រធ្វើឱ្យមានភាពខ្លាំងខ្លា ត្រឹមត្រូវ តម្លាភាពនិងគណនេយ្យភាពលើការងារនេះ។

## ៤.៧ ការកៀរគរការចូលរួមគាំទ្រពីសហគមន៍លើដំណើរការបង្រៀននិងរៀន

ភាពដែគួរជំសំខាន់និងមិនអាចខ្វះបានគឺការចូលរួមពីសហគមន៍លើដំណើរបង្រៀននិងរៀន។ដូចអ្វីដែលយើងធ្លាប់បានដឹងកន្លងមក ដំណើរការនៃការសិក្សារៀនសូត្រដែលទទួលបាននូវលទ្ធផលនិងជោគជ័យអាស្រ័យលើកត្តាមួយចំនួនដូចជា កត្តាសាលារៀន កត្តាគ្រូ កត្តាសិស្សខ្លួនឯង និងសំខាន់មួយទៀតនោះគឺការចូលរួមពីអាណាព្យាបាលសិស្សនិងសហគមន៍។ ក្នុងន័យនេះសាលារៀនត្រូវបង្កើតឱ្យមានបរិយាកាស ទំនាក់ទំនងល្អរវាងសាលារៀននិងសហគមន៍ ដើម្បីផ្ដល់ឱកាសឱ្យពួកគាត់បានចូលរួមចំណែកក្នុងការលើកកម្ពស់ដំណើរការបង្រៀននិងរៀនឱ្យមានប្រសិទ្ធភាពខ្ពស់។ ប៉ុន្តែតាមរយៈការសម្ភាសទៅលើគណៈគ្រប់គ្រងសាលានិងលោកគ្រូអ្នកគ្រូមួយចំនួនបានលើកឡើងពីភាពអសកម្មមួយចំនួន របស់សហគមន៍ក្នុងដំណើរបង្រៀននិងរៀនរបស់សាលា។ នាយកសាលាម្នាក់បានលើកឡើងថា

*"...សាលារៀនពិតជាត្រូវការខ្លាំងពីការគាំទ្ររបស់សហគមន៍ទាំងស្មារតីនិងសម្ភារពីព្រោះសាលារៀនមានធនធានមិនគ្រប់គ្រាន់នោះទេក្នុងការធ្វើឱ្យដំណើរការបង្រៀននិងរៀនប្រព្រឹត្តទៅបានល្អនិងគ្រប់ជ្រុងជ្រោយ ប៉ុន្តែបើពិនិត្យមើលទៅហាក់មិនសូវអើពើឬគិតគូរចូលរួមជួយសាលាឡើយ ពេលអញ្ជើញពួកគាត់មកប្រជុំរៀបចំផែនការម្ដង គាត់មិនចង់មកចូលរួម ជួនកាលមកចូលរួមបានម្នាក់ ជួនកាលគ្មានតែម្ដង ទាំងអស់នេះធ្វើឱ្យសាលាពិបាកនិងមិនសូវដំណើរការបានល្អ"។*

គ្រូបង្រៀនម្នាក់ទៀតបានលើកឡើងថា សាលារបស់គាត់បានចូលរួមតិចតួចណាស់ពីសហគមន៍ជាពិសេសលើដំណើរការបង្រៀននិងរៀន ពេលអញ្ជើញពួកគាត់មកប្រជុំទាក់ទងលទ្ធផលសិក្សារបស់កូនម្ដងៗមកចូលរួមមិនបាន៥០%ផង ដោយយកហេតុថារវល់និងការងារ រកទទួលទាន។ ទាំងនេះជាមូលហេតុធ្វើឱ្យការសិក្សារបស់សិស្សមានការធ្លាក់ចុះ ទន្ទឹមនិងនេះក្នុងស្ថានភាពរៀនពីចម្ងាយផងធ្វើឱ្យមានការលំបាកដល់ការបង្រៀននិងរៀនជាខ្លាំង។ គ្រូបង្រៀនម្នាក់ទៀតបានលើកឡើងផងដែរថា

*"...នាយកសាលាគួរព្យាយាមកសាងទំនាក់ទំនងឱ្យបានល្អជាមួយនិងសហគមន៍ទើបសាលារៀនមានភាពរីកចម្រើន។ ប៉ុន្តែគាត់បានសង្កេតឃើញថាបច្ចុប្បន្ននេះគណៈគ្រប់គ្រងសាលា ហាក់ធ្វើមិនបានល្អ និងធ្វើ*

*មិនទាន់អស់លទ្ធភាពក្នុងការកសាងទំនាក់ទំនងជាមួយសហគមន៍ជាហេតុធ្វើឱ្យសហគមន៍មួយចំនួនហាក់មិនភាពទុកចិត្ត និងជឿជាក់លើសាលារៀន*"។

សរុបជារួមមក ការចូលរួមពីសហគមន៍គឺជាកត្តាសំខាន់មួយដែលធ្វើឱ្យដំណើរបង្រៀននិងរៀនមានប្រសិទ្ធភាព។ គណៈគ្រប់គ្រងសាលាគួរមានទំនួលខុសត្រូវខ្ពស់ចំពោះការងារនេះ ធ្វើយ៉ាងណាកៀរគរការចូលរួមពីសហគមន៍ឱ្យបានផុសផុលធ្វើយ៉ាងណាឱ្យសាលារៀនមានដំណើរការល្អនិងមានការអភិវឌ្ឍ។

# ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ

### ៥.១ សេចក្តីសន្និដ្ឋាន

គណៈគ្រប់គ្រងសាលាជាតួអង្គដ៏សំខាន់មួយក្នុងចំណោមតួអង្គពាក់ព័ន្ធជាច្រើនទៀត ក្នុងការរួមចំណែកធ្វើឱ្យសាលារៀនមួយមានដំណើការល្អ និងមានការអភិវឌ្ឍរីកចម្រើន។ ការយកចិត្តទុកដាក់ ការអនុវត្តតួនាទី និងទំនួលខុសត្រូវពេញលេញ មានតម្លាភាព គណនេយ្យភាព និងធ្វើឱ្យមានការចូលរួមយ៉ាងពេញចិត្ត និងពេញលេញពីសំណាក់គ្រូបង្រៀន សិស្សានុសិស្ស អាណាព្យាបាល គណៈកម្មការគ្រប់គ្រងសាលាសហគមន៍ជុំវិញ និងគ្រប់ភាគីពាក់ព័ន្ធផ្សេងៗ។ ដោយមើលឃើញពីសារៈសំខាន់បែបនេះហើយទើបយើងបានជ្រើសរើសយកប្រធានបទ "ការអនុវត្តតួនាទី និតទំនួលខុសត្រូវរបស់នាយកសាលាលើដំណើការបង្រៀន និងរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ" មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណងសំខាន់ៗដូចជា ទី១ ដើម្បីស្វែងយល់ពីទេពកោសល្យក្នុងការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលាលើដំណើការបង្រៀន និងរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ទី២ ដើម្បីស្វែងយល់ពីសារៈសំខាន់នៃការទទួលខុសត្រូវរបស់នាយកសាលាក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀននិងរៀននៅមធ្យមសិក្សាបឋមភូមិ។

ក្រោយពីការវិភាគទៅលើលទ្ធផលដែលបានមកពីការសម្ភាសជាមួយនិងក្រុមសំណាកគោលដៅស្របតាមសំណួរសម្ភាសរួចមក យើងអាចសន្និដ្ឋានបានថា នាយកសាលាពិតជាមានការទទួលខុសត្រូវច្រើនលើការងារគ្រប់គ្រងជាពិសេសលើដំណើការបង្រៀន និងរៀនពួកគាត់ត្រូវមានភាពប៉ិនប្រសព្វ និងមានភាពបទបែនខ្ពស់ទៅតាមស្ថានភាពជាក់ស្តែងធ្វើយ៉ាងណាឱ្យដំណើការបង្រៀន និងរៀនប្រព្រឹត្តទៅបានល្អ ទាំងគ្រូ ទាំងសិស្សបានចូលរួមពេញលេញ ព្រមទាំងទទួលបាននូវប្រយោជន៍ស្របតាមអ្វីដែលពួកគេគួរតែទទួលបានស្របតាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលក្រសួងអប់រំបានដាក់ចេញជាបន្តបន្ទាប់។

នាយកសាលាមានការទទួលខុសត្រូវចំពោះដំណើរការបង្រៀន និងរៀនលើចំណុចសំខាន់ៗមួយចំនួន ដូចជា៖ (១)ការអនុវត្តតួនាទី និងទំនួលខុសត្រូវក្នុងការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា (២)ការគ្រប់គ្រងអនុវត្តការងារអធិការកិច្ចអចិន្ត្រៃយ៍ (៣)ទំនួលខុសត្រូវក្នុងការដឹកនាំការអនុវត្តវិធីសាស្ត្របង្រៀន (៤)ការដឹកនាំនិងគ្រប់គ្រងលើការអនុវត្តការងាររដ្ឋបាលរបស់គ្រូ (៥)ទំនួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រងលើការងារប្រជុំបច្ចេកទេស (៦)ទំនួលខុសត្រូវក្នុងការគ្រប់គ្រងលើលទ្ធផលសិក្សារបស់សិស្ស និង (៧)ទំនួលខុសត្រូវក្នុងការងារកៀរគរការចូលរួមពីសហគមន៍។ ក្នុងចំណោមទាំងអស់នោះចំណុចដែលសំខាន់ និងត្រូវយកចិត្តទុកដាក់ខ្ពស់ជាងគេគឺ ការគ្រប់គ្រងអនុវត្តការងារអធិការកិច្ចអចិន្ត្រៃយ៍ ការដឹកនាំនិងគ្រប់គ្រងលើការអនុវត្តការងាររដ្ឋបាលរបស់គ្រូ និងទំនួលខុសត្រូវក្នុងការងារកៀរគរការចូលរួមពីសហគមន៍ ជាភារកិច្ចដែលនាយកសាលាគ្រប់រូបត្រូវយកចិត្តដាក់ខ្ពស់ ព្រោះថាតាមរយៈការសម្ភាសទៅលើគ្រូបង្រៀនមួយចំនួនបានលើកឡើងពីផលលំបាកក្នុងការបង្រៀនដោយសារចេញធ្វើការយូរឆ្នាំ មិនបានអភិវឌ្ឍសមត្ថភាពបន្ថែម ខ្វះការជ្រោមជ្រែងពីនាយកសាលា ខ្វះការផ្តល់ប្រឹក្សាកែលម្អលើចំណុចខ្វះខាតដែលកើតមានឡើងនៅអំឡុងពេលបង្រៀនជាដើម ដែលផ្ទុយពីសាលាមួយចំនួនដែលនាយកមានផែនការច្បាស់លាស់ក្នុងការអនុវត្តការពិនិត្យតាមដានជាប្រចាំលើដំណើរការបង្រៀន និងរៀនដែលបានធ្វើឱ្យពួកគាត់មានភាពងាយស្រួល និងបានដោះស្រាយនូវបញ្ហាផ្សេងក្នុងការបង្រៀនសិស្ស រួមមានទាំងការប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មី ការច្នៃប្រឌិតនូវសម្ភារឧបទេស និងបានដោះស្រាយទាន់ពេលវេលានូវតម្រូវការរបស់ពួកគាត់។ លើពីនេះទៅទៀតការស្រាវជ្រាវនេះក៏បានបង្ហាញផងដែរថាការយកចិត្តទុកដាក់ពិនិត្យតាមដាន និងវាយតម្លៃលើការងារបង្រៀន និងរៀនរបស់គ្រូរួមទាំងការរៀបចំកិច្ចតែងការបានត្រឹមត្រូវ ការរៀបចំកិច្ចបញ្ជីការផ្សេងៗលើដំណើរការបង្រៀន និងរៀនរបស់សិស្សានុសិស្ស បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការខិតខំប្រឹងប្រែងរៀនសូត្ររបស់សិស្សហើយលទ្ធផលនៃការសិក្សាក៏មានការប្រែប្រួលជាវិជ្ជមានបើទោះជាប្រទេសកម្ពុជាបានរងឥទ្ធិពលពីជម្ងឺឆ្លងដ៏កាចសាហាវ(កូវីត១៩)យ៉ាងណាក៏ដោយ។ ការរកឃើញនេះបានឆ្លើតតបទៅនឹងការរកឃើញរបស់ក្រសួងអប់រំ

យុវជននិងកីឡាក្នុងសៀវភៅផែនទីបង្ហាញផ្លូវអប់រំមធ្យមសិក្សាឆ្នាំ២០៣០ទំព័រ៣៥ ដែលគ្រូបង្រៀនម្នាក់មានប្រសាសន៍ថា៖

*"ខ្ញុំមិនដឹងពីគ្រូផ្សេងទៀតនោះឡើយ ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំចង់ឱ្យគេសង្កេតមើលការបង្រៀនរបស់ខ្ញុំញឹកញាប់។ ប្រសិនបើពុំមានការណែនាំគាំទ្រ និងការបង្វឹកជាប់ជាប្រចាំនោះទេ ខ្ញុំនឹងមិនអាចកែលម្អការបង្រៀនរបស់ខ្ញុំឡើយ ហើយយូរៗទៅ ខ្ញុំប្រាកដជាបាត់បង់ទំនុកចិត្តលើខ្លួនឯងជាមិនខាន"។*

មួយវិញទៀតការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងដំណើការសាលារៀនមួយ គឺរឿងដ៏មានសារៈសំខានខ្លាំងបំផុត និងមិនអាចខ្វះបាន។ ជាពិសេសគឺការយកចិត្តទុកដាក់ ទទួលខុសត្រូវខ្ពស់ក្នុងការបំពេញតួនាទីប្រចាំថ្ងៃរបស់គណៈគ្រប់គ្រងសាលារៀន។ តួយ៉ាងក្រោយពីបានធ្វើការសម្ភាស និងសង្កេតទៅលើការឆ្លើយតបរបស់លោកគ្រូអ្នកគ្រូបានបង្ហាញថាបើនាយកសាលាយកចិត្តទុកដាក់បំពេញតួនាទីបានត្រឹមត្រូវ មានតម្លាភាព មានគណនេយ្យភាព នោះគុណភាព និងលទ្ធផលសិក្សារបស់សិស្សនិងមានការរីកចម្រើនជាវិជ្ជមាន។ ផ្ទុយទៅវិញបើនាយកសាលាមិនរវល់គិតគូពីដំណើការនៃការបង្រៀននិងរៀនទេនោះច្បាស់ណាស់ថា និងមានធកល្វែងច្រើនក្នុងការបំពេញការងាររបស់លផកគ្រូអ្នកគ្រូ។ ភាពលម្អៀង ការគិតតែប្រយោជន៍បក្សពួក ឬក្រុមខ្លួន និងធ្វើឱ្យខឹងសម្បារ ភាពអាក់អន់ស្រពោនចិត្ត មិនបានបំពេញភារកិច្ចត្រឹមត្រូវពីបុគ្គលិកមួយចំនួនដែលគិតថាខ្លួនទទួលរងនូវភាពអយុត្តិធម៌ ដែលជាហេតុធ្វើឱ្យអង្គភាពទាំងមូលមានភាពបែកបាក់។

លើសពីនេះទៅទៀតបើនាយសាលាស្គាល់ពីតួនាទី និងបំពេញវាដោយភាពទទួលខុសត្រូវវានឹងអាចទាក់ទាញដល់មាតាបិតា អាណាព្យាបាល និងសហគមន៍ដែលមួយចំនួនបានអស់ជំនឿលើប្រព័ន្ធអប់រំងាកមកចូលរួមក្នុងដំណើការអប់រំវិញផងដែរ។ ការរកឃើញក៏បានឆ្លុះបញ្ចាំង និងមានភាពឆ្លើយតបទៅនឹងការរកឃើញរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានបង្ហាញនៅក្នុងសៀវភៅផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០ទំព័រ៣៦ បានលើកឡើងថា ការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ផ្តល់គណនេយ្យភាព

យ៉ាងសំខាន់ ហើយនាយកសាលាត្រូវត្រៀមខ្លួនត្រួតពិនិត្យ និងរក្សាគុណភាពដែលផ្ដល់ដោយគណៈកម្មការនេះ

*"សាលាពុំអាចក្លាយជាថ្នាលបណ្ដុះបណ្ដាលកាសិក្សាបានទេ ខណៈដែលគ្រូ និងសិស្សអវត្តមានញឹកញាប់ និងមកសាលាយឺតយ៉ាវ ហើយគ្រូផ្ដោតការយកចិត្តទុកដាក់តិចតួចលើការអភិវឌ្ឍវិជ្ជាជីវៈ និងពុំមានដំណោះស្រាយចំពោះបញ្ហាត្រួតថ្នាក់។ ប្រឈមជាមួយបញ្ហាបែបនេះចាំបាច់ត្រូវមានប្រព័ន្ធគណនេយ្យភាពមួយដែលរឹងមាំ"។*

## ៥.២ សំណូមពរ

### ៥.២.១ សាលារៀន

គ្រប់សាលារៀនមធ្យមសិក្សាទាំងអស់ត្រូវយកចិត្តទុកដាកខ្ពស់លើដំណើរការបង្រៀន និងរៀនជាពិសេសនាយកសាលាត្រូវយកចិត្តទុកដាក់បំពេញតួនាទីរបស់ខ្លួនឱ្យបានម៉ត់ចត់ និងអនុវត្តឱ្យស្របទៅតាមគោលនយោបាយអប់រំដែលក្រសួងបានដាកចេញជាបន្តបន្ទាប់ក្នុងទិសដៅកសាងនូវមូលធនមនុស្សឆ្លើយតប និងតម្រូវការទីផ្សារការងារទាំងក្នុងប្រទេស ក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោកទាំងមូល។ ក្រោយពីបានសិក្សារួមអ្នកស្រាវជ្រាវសំណូមពរដល់គណៈគ្រប់គ្រងសាលាទាំងអស់ពង្រឹងបន្ថែមទៅលើការងារមួយចំនួនដែលជាការទទួលខុសត្រូវជាចាំបាច់ដូចជា៖

- គួរពង្រឹងបន្ថែមទៅលើការពិនិត្យតាមដាន និវាយតម្លៃជាប្រចាំលើដំណើការបង្រៀន និងរៀន ដោយត្រូវរៀបចំធ្វើផែនការអធិការកិច្ចឱ្យបានច្បាស់លាស់

- ពង្រឹងបន្ថែមលើការគ្រប់គ្រងនិងដឹកនាំការងារប្រជុំបច្ចេកទេសឱ្យបានត្រឹមត្រូវ និងមានភាពទៀងទាត់ក្នុងការអនុវត្តដើម្បីពង្រឹងប្រសិទ្ធភាពការងារ

- ពង្រឹងបន្ថែមលើការងារទំនាក់ទំនងជាមួយសហគមន៍ជុំវិញសាលាដើម្បីគៀគរការចូលរួមក្នុងដំណើរការអភិវឌ្ឍសាលារៀនឱ្យមានភាពរីកចម្រើន។

### ៥.២.២ ការិយាល័យអប់រំយុវជន និងកីឡាស្រុក

គាំទ្រដល់សាលារៀនក្នុងការអនុវត្តនូវតួនាទីរបស់ខ្លួនឱ្យបានសមស្រប ជួយពង្រឹងបន្ថែមទៅលើភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា។ ចូលរួមពិនិត្យតាម ដាន និងវាយតម្លៃលើកិច្ចការងារដែលសាលាបានអនុវត្តតាមផែនការដែលបានគ្រោងទុកដើម្បីជួយដល់សាលារៀនបន្តនូវបេសកម្មកសាងមូលធនមនុស្សនៅក្នុងប្រទេសកម្ពុជា។

### ៥.២.៣ មន្ទីរអប់រំយុវជន និងកីឡា

បង្កើតឱ្យមានកម្មវិធីប្រកួតប្រជែងអ្នកដឹកនាំល្អ នាយកសាលាល្អនៅក្នុងខេត្តដៀម្បីជម្រុញលើកទឹកចិត្តដល់គណៈគ្រប់គ្រងខិតខំបំពេញការងារ។ ក្នុងនោះផងដែររៀបចំឱ្យមានកម្មវិធីបំប៉នសមត្ថភាពដល់គណៈគ្រប់គ្រងក៏ដូចជាបុគ្គលិកអប់រំទាំង លើជំនាញវិជ្ជាជីវៈ និងជំនាញផ្សេងដើម្បីឱ្យការងារបង្រៀន និងរៀនមានប្រសិទ្ធភាពខ្ពស់។

### ៥.២.៤ ក្រសួងអប់រំ យុវជន និងកីឡា

- រៀបចំនិងផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ដល់គ្រូ និងសិស្ស និងរៀបចំឱ្យមានកម្មវិធីពង្រឹងគុណវុឌ្ឍិគ្រូបង្រៀន

### ៥.២.៥ អ្នកស្រាវជ្រាវបន្ត

ដោយយោងទៅតាមស្ថានភាពនៃការរក្សាគម្លាតនូវមិនទាន់ចប់ជាស្ថាពរការសិក្សាស្រាវជ្រាវនេះមិនបានប្រមូលទិន្នន័យពីគ្រប់ភាគីពាក់ព័ន្ធពោលគឺសហគមន៍ដែលជាតួអង្គសំខាន់ ដូចនេះការសិក្សាស្រាវជ្រាវ

នេះនៅមិនទាន់មានភាពគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយនៅឡើយ។ នៅថ្ងៃអនាគតប្រសិនបើមានអ្នកចង់សិក្សាលើប្រធានបទនេះឱ្យបានស៊ីជម្រៅបន្ថែមទៀតនោះគួរពង្រីកទំហំសំណាក និងជ្រើសរើសឱ្យបានពីគ្រប់ភាគីពាក់ព័ន្ធ។ លើសពីនេះទៀតអ្នកសិក្សាស្រាវបន្តអាចប្រើវិធីសាស្រ្តស្រាវជ្រាវបែបផ្សេងដើម្បីឱ្យបានលទ្ធផលជាក់លាក់ជាប្រយោជន៍ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។

# ឯកសារយោង


Meador, D. (២០២១). មុខនាទីរបស់នាយកសាលា. Retrieved ២៦ –០៥ –២០២២ from https://km.eferrit.com

SEAMEOINNOTECH. (២០១៤). *Competency Framework for Southeast Asian School Heads*.

Sebastian, J., Allensworth, E., Wiedermann, W., Hochbein, C., & Cunningham, M. (2018, 29 Oct 2018). Principal leadership and school performance:An examination of instructional leadership and organizational management [Jernal Article]. *Leadership and Policy in Schools, 18*(4), 591– 613. https://doi.org/10.1080/15700763.2018.1513151

Toutesàl'école. (2017). នាយក/នាយិកាសាលាបឋមសិក្សា. Retrieved ២៨– ០៥– ២០២២ from http://www.topjobcambodia.com/kh/job--5013.html

ក្រសួងអប់រំយុវជននិងកីឡា. (២០១៦). នាយកឬនាយិកាសាលារៀនល្អ.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨a). ការគ្រប់គ្រងតាមសាលារៀន.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨b). ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ស្តីពីការអប់រំនៅកម្ពុជា.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៩). ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣.

ក្រសួងអប់រំយុវជននិងកីឡា. (២០២១). ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៩). ផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣.

ក្រសួងអប់រំយុវជននិងកីឡា. (២០២១a). ផែនទីបង្ហាញផ្លូវការអេប់រំមធ្យមសិក្សាឆ្នាំ២០៣០.

ក្រសួងអប់រំយុវជននិងកីឡា. (២០២១b). ផែនទីបង្ហាញផ្លូវអេប់រំមធ្យមសិក្សា២០៣០.

ក្រសួងអប់រំយុវជននិងកីឡា. (២០២១c). ផែនទីបង្ហាញផ្លូវអេប់រំមធ្យមសិក្សាឆ្នាំ២០៣០.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ. (២០០៦). ឯកសាបំប៉ននាយកសាលាបឋមសិក្សា និងសាលាចំណេះទូទៅ.

គីមសល់, ក. ញ. វ. ន. (២០២១). លក្ខណៈសម្បត្តិទាំង៦យ៉ាងរបស់នាយកល្អ. Retrieved ២៦ – ០៥ – ២០២២ from https://education.ams.com.kh/six-qualities-of-a-good-principal-school-in-cambodia/

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ. (២០០៦). ឯកសាបំប៉ននាយកសាលាបឋមសិក្សា និងសាលាចំណេះទូទៅ.

ហេងគ្រេង, ណ. ហ. វ. ត. (២០១៦). ការចូលរួមរបស់សហគមន៍ក្នុងការងារគ្រប់គ្រងសាលារៀនកម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិនៅកម្ពុជា.

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ(ក) សំណួរសម្ភាសសម្រាប់នាយកសាលា

## គម្រោងស្រាវជ្រាវស្តីពី

## ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលាលើដំណើរការបង្រៀននិងរៀន នៅកម្រិតមធ្យមសិក្សាក្នុងខេត្តត្បូងឃ្មុំ

- ការធ្វើគារវកិច្ច និងការជជែកគ្នាលេងមិននឹងចាប់ផ្តើមកិច្ចសម្ភាសន៍
- ការណែនាំអំពីគោលបំណងនៃការស្រាវជ្រាវ (១)ស្វែងយល់ពីទួនាទីភារកិច្ច និងទំនួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងដឹកនាំការបង្រៀន និងរៀន (២) អត្ថប្រយោជន៍ និងសារសំខាន់នៃការបំពេញតួនាទីបានគ្រប់ជ្រុងជ្រោយរបស់នាយកសាលាឈានទៅដល់ការលើកកម្ពស់គុណភាពអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ **ផ្នែក ក ៖ អំពីអ្នក**

ខាងក្រោមនេះជាសំណួរដែលពាក់ព័ន្ធនឹងអ្នក ការអប់រំរបស់អ្នក និងការងារជានាយករបស់អ្នក។ សូមគូសសញ្ញា( ) ឬសរសេរចម្លើយខ្លីៗលើបន្ទាត់ដែលផ្តល់ជូន

១. ភេទ ☐ ស្រី ☐ ប្រុស

២. អាយុ ☐ ក្រោម៤០ឆ្នាំ ☐ ៤០-៤៩ ☐ ៥០-៥៩ ☐ លើសពី៦០ឆ្នាំ

៣. តើអ្នកមានកម្រិតវប្បធម៌ខ្ពស់បំផុតកម្រិតណា?

☐ កម្រិតបឋមសិក្សា ☐ កម្រិតអនុវិទ្យាល័យ ☐ កម្រិតវិទ្យាល័យ

☐ កម្រិតបរិញ្ញាប័ត្រ ☐ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ☐ កម្រិតបណ្ឌិត

៤. នៅមុនពេលធ្វើជានាយកសាលាសព្វថ្ងៃ តើលោក/លោកស្រីធ្លាប់ធ្វើជានាយកសាលាពីមុនមកទេ?

☐ បាទ ចាស/ធ្លាប់ ☐ ទេមិនធ្លាប់ទេ

៥. តើលោក/លោកស្រីមានបទពិសោធន៍ធ្វើជានាយកសាលារយៈពេលសរុបប៉ុន្មានឆ្នាំហើយ?

☐ ក្រោម៥ឆ្នាំ ☐ ៦ - ១០ ឆ្នាំ ☐ ១១ - ១៥ ឆ្នាំ ☐ ១៦ - ២០ ឆ្នាំ

☐ ២០ - ២៥ ឆ្នាំ ☐ ចាប់ពី២៦ឆ្នាំឡើងទៅ

៦. តើលើក/លោកស្រីធ្វើជានាយកសាលាសព្វថ្ងៃបានរយៈពេលប៉ុន្មានឆ្នាំហើយ?

☐ក្រោម៥ឆ្នាំ ☐៦ - ១០ ឆ្នាំ ☐១១ - ១៥ ឆ្នាំ ☐១៦ - ២០ ឆ្នាំ

☐២០ - ២៥ ឆ្នាំ ☐ចាប់ពី២៦ឆ្នាំឡើងទៅ

**ផ្នែក ខ៖ អំពីសាលារបស់អ្នក**

៧. ក្នុងរយៈពេលបីឆ្នាំចុងក្រោយជាមធ្យមតើសាលារបស់អ្នកមានអត្រាបោះបង់ការសិក្សាប៉ុន្មានភាគរយ ..................%

៨. ក្នុងរយៈពេលបីឆ្នាំចុងក្រោយជាមធ្យមតើសាលារបស់អ្នកមានអត្រាត្រួតថ្នាក់ប៉ុន្មានភាគរយ?.................%

៩. ក្នុងរយៈពេលបីឆ្នាំចុងក្រោយជាមធ្យមតើសាលារបស់អ្នកមានអត្រាឡើងថ្នាក់ប៉ុន្មានភាគរយ?.................%

១០. ស្ថិតិសិស្ស គ្រូក្នុងឆ្នាំសិក្សា ២០២១ - ២០២២.........................................................................

**ផ្នែក គ៖ ការគ្រប់គ្រងនិងដឹកនាំ**

១១. តើលោក លោកស្រីបានរៀបចំតុបតែងទីចាត់ការ បានសមរម្យគ្រប់គ្រាន់កម្រិតណាដែរ ដូចជារចនាសម្ព័ន្ធគ្រប់គ្រង ស្ថិតិ ថ្នាក់រៀន គ្រូ សិស្ស ...?ចូរបញ្ជាក់មូលហេតុ។

…………………………………………………………………………………………………………….

១២.តើលោក លោកស្រីបានរៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនយ៉ាងណាដែរ?

………………………………………………………………………………………………

១៣.តើលោក លោកស្រី បានចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនយ៉ាងដូចម្តេចដែរ?

.......................................................................................................................

១៣.១.បើ *មិនមិនបានចុះទាល់តែសោះ ឬបានចុះតែមិនបានតាមផែនការ* សូមបញ្ជាក់មូលហេតុបន្ថែមផង

.........................................................................................................................

១៤.តើ គ្រូបង្រៀនបានធ្វើកិច្ចតែងការ និងយកមកឱ្យលោក លោកស្រី ត្រួតពិនិត្យ ដោយចុះហត្ថលេខា គ្រប់គ្រាន់មុននឹងបង្រៀនបានកម្រិតណាដែរ?.......................................................

១៥.តើគ្រូបង្រៀន តុបតែងថ្នាក់តាមបែបបទរដ្ឋបាលថ្នាក់បានកម្រិតណាដែរ?ចូរបញ្ជាក់មូលហេតុ។

.......................................................................................................................................

១៦.តើគ្រូបង្រៀន បានរៀបចំឱ្យមានសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូបានកម្រិតណាដែរ? ចូរពន្យល់។

.....................................................................................................................................

១៧.តើគុណភាពនិងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់យ៉ាងណាដែរពីមួយឆ្នាំទៅមួយឆ្នាំ ?

..........................................................................................................................................

..........................................................................................................................................

១៨.តើសាលារៀន លោក លោកស្រី មានការចូលរួមគាំទ្រពីសហគមន៍ ឬសាធារណៈជនកម្រិតណាដែរ ?ចូរពន្យល់។

..........................................................................................................................................

១៩.តើនៅសាលារៀន លោក លោកស្រី មានទទួលចំណាត់ថ្នាក់សាលារៀនល្អ ឬនាយកល្អ ឬទទួលប័ណ្ណសរសើរពីថ្នាក់ដឹកនាំដែរឬទេ ? បើទទួលមានកម្រិតណា ?

..........................................................................................................................................

## ផ្នែក ឃៈ ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន

សូមលោក លោកស្រី ផ្តល់មតិយោបល់ទាក់ទងនឹងអត្ថប្រយោជន៍ និងគុណតម្លៃនៃការអនុវត្តការគ្រប់គ្រងរបស់អ្នក

២០. តើលោកនាយកបាននិងកំពុងធ្វើសកម្មភាពអ្វីខ្លះក្នុងការដឹកនាំ និងគ្រប់គ្រងលើដំណើរការបង្រៀន និងរៀននាពេលបច្ចុប្បន្ន ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................

២១. ក្នុងការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា តើលោកនាយកបានធ្វើសកម្មភាពអ្វីខ្លះ ?

..........................................................................................................................................

..........................................................................................................................................

...............................

២២. តើលោកនាយកបានធ្វើសកម្មភាពដូចម្តេចខ្លះក្នុងការជម្រុញគ្រូបង្រៀនឱ្យធ្វើការបង្រៀនដោយប្រើវិធីសាស្ត្រសម្បូរបែប និងភាពផ្សេងៗគ្នា ?

..........................................................................................................................................

..........................................................................................................................................

...............................

២៣. តើលោកនាយកយល់យ៉ាងណាចំពោះសកម្មភាពសិក្សាបែបសិស្សមជ្ឈមណ្ឌល ?ចូរពន្យល់។

..........................................................................................................................................

..........................................................................................................................................

.............................

២៤. តើការរៀបចំបរិស្ថានសិក្សាមួយដែលមានសុវត្ថិភាព និងសុខភាពល្អមានសារៈសំខាន់ដែរឬទេ?ចូរពន្យល់។

..........................................................................................................................................

..........................................................................................................................................

................................

២៥. តើការគោរពលក្ខណៈផ្សេងៗគ្នារបស់អ្នកសិក្សាមានសារៈសំខាន់ដែរឬទេ?ចូរពន្យល់។

..........................................................................................................................................

..........................................................................................................................................

...............................

២៦. តើលោកនាយកបានធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនជាប្រចាំដែរឬទេ?ចូរពន្យល់។

..........................................................................................................................................

..........................................................................................................................................

................................

២៧. តើការដឹកនាំ និងគ្រប់គ្រងដំណើរការបង្រៀន និងរៀនបានល្អផ្តល់សារៈសំខាន់ ព្រមទាំងអត្ថប្រយោជន៍ដូចម្តេចខ្លះ?

..........................................................................................................................................

..........................................................................................................................................

២៨. តើមានចំណុចអ្វីខ្លះដែលជាបញ្ហាប្រឈមខ្លាំងរាំងស្ទះដល់ការអនុវត្តការគ្រប់គ្រងលើការបង្រៀន និងរៀន?

..........................................................................................................................................

ឧបសម្ព័ន្ធ(ខ) សំណួរសម្ភាសសម្រាប់គ្រូបង្រៀន

## គម្រោងស្រាវជ្រាវស្តីពី

## ការបំពេញតួនាទី និងទំនួលខុសត្រូវរបស់នាយកសាលាលើដំណើរការបង្រៀននិងរៀន នៅកម្រិតមធ្យមសិក្សាក្នុងខេត្តត្បូងឃ្មុំ

- ការធ្វើគារវកិច្ច និងការជជែកគ្នាលេងមិននឹងចាប់ផ្តើមកិច្ចសម្ភាសន៍
- ការណែនាំអំពីគោលបំណងនៃការស្រាវជ្រាវ (១)ស្វែងយល់ពីទួនាទីភារកិច្ច និងទំនួលខុសត្រូវរបស់នាយកសាលាក្នុងការគ្រប់គ្រងដឹកនាំការបង្រៀន និងរៀន (២) អត្ថប្រយោជន៍ និងសារសំខាន់នៃការបំពេញតួនាទីបានគ្រប់ជ្រុងជ្រោយរបស់នាយកសាលាឈានទៅដល់ការលើកកម្ពស់គុណភាពអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ

### ផ្នែកទី១ ៖ អំពីព័ត៌មានទូទៅ

សូមលោក លោកស្រី ផ្តល់ទិន្នន័យទូទៅតាមលម្រងសំណួរដោលំដាប់លំដោយដូចខាងក្រោម៖

១. ភេទ ☐ ស្រី ☐ ប្រុស

២. អាយុ ☐ ក្រោម៣០ឆ្នាំ ☐ ៣០-៣៩ ☐ ៤០-៤៩ ☐ លើសពី ៥០ឆ្នាំ

៣.គ្រូបង្រៀនឯកទេស( សូមសរសេរតាមទម្រង់ ឧ. **ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ** )

........................................................................................................................................

៤.តើលោក លោកស្រីមានបទពិសោធន៍ ក្នុងការបង្រៀន អាជីពជាគ្រូបង្រៀន ប៉ុន្មានឆ្នាំ?

ក.០១ឆ្នាំដល់១០ឆ្នាំ ខ.១១ឆ្នាំដល់២០ឆ្នាំ គ.២១ឆ្នាំដល់៣០ឆ្នាំ ឃ.៣១ឆ្នាំដល់៤០ឆ្នាំ ង. ៤១ឆ្នាំឡើង

៥.ឈ្មោះសាលារៀន.............................................................................................

៦.តើពីផ្ទះឬកន្លែងស្នាក់នៅទៅសាលារៀនរបស់លោក លោកស្រីមានចម្ងាយប៉ុន្មានគីឡូម៉ែត្រ?

៦.១.ការធ្វើដំណើរបំពេញការងាររបស់លោក លោកស្រីជួបការលំបាក ឬងាយស្រួលយ៉ាងដូចម្តេច?

........................................................................................................................................

៧.កម្រិតជំនាញវិជ្ជាជីវៈ

ក.ក្រោមបរិញ្ញាបត្រ ខ.បរិញ្ញាបត្រ គ.បរិញ្ញាបត្រជាន់ខ្ពស់ ឃ.បណ្ឌិត ង.ផ្សេងៗ

៨.តើលោក លោកស្រី ធ្លាប់បានចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលាទាក់ទងនឹងមុខវិជ្ជារបស់ខ្លួន ឬការអប់រំនានាខ្លះឬយ៉ាងណា?

..............................................................................................................................................

**ផ្នែកទី២៖ការគ្រប់គ្រងនិងដឹកនាំការបង្រៀន និងរៀន**

១២.តើសាលាលោក លោកស្រីបានរៀបចំតុបតែងថ្នាក់រៀន និងហេដ្ឋារចនាសម្ព័ន្ធនានារបស់សាលារៀនឱ្យមានលក្ខណៈសមរម្យបានកម្រិតណាដែរ ?

..............................................................................................................................................

១២.១. សូមបង្ហាញពីការប្រឈមបញ្ជាក់៖

..............................................................................................................................................

១២.២.តើការរៀបចំបន្ទប់រៀន និងហេដ្ឋារចនាសម្ព័ន្ធនានាទាំងនោះមានអ្វីខ្លះ?

..............................................................................................................................................

១៣.តើលោក លោកស្រីបានឃើញលោកនាយករៀបចំផែនការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនបានញឹកញ៉ាប់យ៉ាងណាដែរ?

..............................................................................................................................................

១៣.១.បើ ***មិនបានរៀបចំចុះអធិការកិច្ចអចិន្ត្រៃយ៍ទាល់តែសោះ*** សូមបញ្ជាក់មូលហេតុ

..............................................................................................................................................

១៤.តើលោក លោកស្រី បានទទួលព័ត៌មានស្តីពីការចុះអធិការកិច្ចអចិន្ត្រៃយ៍ថ្នាក់រៀនពីនាយកសាលាយ៉ាងដូចម្តេចដែរ?

..............................................................................................................................................

១៤.១.បើ ***មិនបានទទួលព័ត៌មានអ្វីពីការចុះអធិការកិច្ចអចិន្ត្រៃយ៍ទាល់សោះឬបានចុះដែរតែមិនបានតាមផែនការ***សូមបញ្ជាក់មូលហេតុ៖

..............................................................................................................................

១៥.តើលោក លោកស្រីបានចូលរួមប្រជុំបច្ចេកទេសក្នុងសាលារៀនបានកម្រិតណាដែរ?

..........................................................................................................................................

១៥.១.បើ *មិនបានកែលម្អទាល់តែសោះ ឬ បានតិចជាង៥០%* សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **បានអនុវត្តលើ៥០%** សូមបញ្ជាក់ចំណុចគោលៗដែលបានធ្វើផង

..........................................................................................................................

១៦.តើ លោក លោកស្រី បានធ្វើកិច្ចតែងការ និងបានយកមកឱ្យនាយក ត្រួតពិនិត្យ ដោយចុះហត្ថលេខាគ្រប់គ្រាន់មុននឹងបង្រៀនបានកម្រិតណាដែរ?

..........................................................................................................................................

១៦.១.បើ ***មិនបានអនុវត្តទាល់តែសោះ ឬ បានតិតជាង៥០%*** សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **បានអនុវត្តលើសពី៥០%** សូមបញ្ជាក់ចំណុចគោលៗនៃការអនុវត្តល្អបន្ថែមផងដែរ៖

..........................................................................................................................................

១៨.តើលោក លោកស្រី បានរៀបចំឱ្យមានសៀវភៅនានាតាមបែបបទរដ្ឋបាលគ្រូបានកម្រិតណាដែរ?

...............................................................................................................

១៨.១.បើ ***បានតិតជាង៥០% ឬ មិនបានអនវុត្តទាល់តែសោះ*** សូមបញ្ជាក់មូលហេតុបន្ថែមផង ហើយបើ **បានអនុវត្តលើសពី៥០%** សូមបញ្ជាក់ចំណុចគោលៗនៃការអនុវត្តល្អបន្ថែមផងដែរ៖

..........................................................................................................................................

១៩.តើគុណភាព និងលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់យ៉ាងណាដែរពីមួយឆ្នាំទៅមួយឆ្នាំតាមឯកទេសរបស់លោកគ្រូអ្នកគ្រូផ្ទាល់?

..........................................................................................................................................

១៩.១.បើ ***មិនកើនទាល់តែសោះឬ កើនតិចជាង៥០%*** សូមបញ្ជាក់មូលហេតុ៖

..........................................................................................................................................

២០.តើសាលារៀន លោក លោកស្រី មានការចូលរួមពីសហគមន៍កម្រិតណាដែរលើដំណើរការបង្រៀន និងរៀន?

..................................................................................................................................

២០.១.បើ *ខ្សោយ ឬ ក្រោមមធ្យម* សូមបញ្ជាក់មូលហេតុបន្ថែមផង

..........................................................................................................................................

## ផ្នែកទី៣.ការយល់ឃើញរបស់គ្រូបង្រៀន

សូមលោក លោកស្រី ផ្តល់មតិយោបល់ទាក់ទាន់នឹងអត្ថប្រយោជន៍ និងគុណតម្លៃនៃការបំពេញតួនាទីនិងទំនួលសុខត្រូវរបស់នាយកតាមសំណួរដោបន្តបន្ទាប់ដូចខាងក្រោម៖

២៥.តើការគ្រប់គ្រងដំណើការបង្រៀនរបស់នាយកបានជួយដល់ការអភិវឌ្ឍការងាររដ្ឋបាលគ្រូ និងរដ្ឋបាលថ្នាក់ របស់លោក លោកស្រី ព្រមទាំងសាលារៀនកម្រិតណា ?

ក.អភិវឌ្ឍខ្លាំងណាស់ ខ.អភិវឌ្ឍល្អ គ.អភិវឌ្ឍខ្លះ មិនអភិវឌ្ឍខ្លះ ឃ.គ្មានជួយដល់ការអភិវឌ្ឍទេ

២៥.១.បើ***អភិវឌ្ឍខ្លះ មិនអភិវឌ្ឍខ្លះ*** ឬ***គ្មានជួយដល់ការអភិវឌ្ឍ*** សូមបញ្ជាក់ពីមូលហេតុចម្បងៗបន្ថែមផង ហើយបើមាន***ការអភិវឌ្ឍ*** សូមលើកផ្នែកគោលៗមកបញ្ជាក់ផង

..........................................................................................................................................

២៦.តើលោក លោកស្រី បានអនុវត្តការងាររបស់ខ្លួន និងការងាររបស់សាលារៀនតាមការណែនាំរបស់លោកនាយកបានប៉ុន្មានភាគរយ ?.................................

២៦.១.បើ***ក្រោម៥០%*** ឬ***មិនបានអនុវត្តទាល់តែសោះ***សូមបញ្ជាក់ពីមូលហេតុចម្បងៗបន្ថែមផង ហើយបើបានអនុវត្តចាប់ពី៥០%ឡើងលើ សូមមកបញ្ជាក់ថា ***បានអនុវត្ត***

..........................................................................................................................................

២៧.តើលោក លោកស្រីអាចសន្និដ្ឋានបានទេថា សាលារៀនរបស់លោក លោកស្រី មានការអភិវឌ្ឍលើដំណើការបង្រៀននិងរៀនស្ថិតក្នុងកម្រិតណា ?

..........................................................................................................................